D24373

ទេពគង់សាវ៉ាត, [illegible]

17 [illegible] 1999

[illegible]

ឃុំ [illegible], [illegible]

[illegible]



(រូបថតៈគាត់)

[illegible]

D24373

# បទសំភាសសន៍ជាមួយ នេត សាវ៉ាត នៅស្រែអូរច្បារ ភូមិពាមជីមៀត
# ឃុំណាងឃីលឹក ស្រុកកោះញែក ខេត្តមណ្ឌលគីរី
# ដោយ ទ៉ាន់ថាន់ ពៅដារ៉ា, សឹម សុរិយ៉ា និង យិន នាន
# ថ្ងៃទី១៧-១២-៩៩

**ចារ៉ា:** *អញ្ចឹងលោកអ៊ំឈ្មោះអីដែរ?*

**សាវ៉ាត:** ***នេត សាវ៉ាត*** ។

**ចារ៉ា:** ***នេត សាវ៉ាត****?*

**សាវ៉ាត:** *ឈ្មោះកំណើត  ឈ្មោះកំណើតហេ?*

**ចារ៉ា:** *ឈ្មោះកំណើត?*

**សាវ៉ាត:** ***នេត ថា*** ។

**ចារ៉ា:** *ហៅ* ***នេត ថា*** *អញ្ចឹង?*

**សាវ៉ាត:** *បាទ!  ឈ្មោះថ្មីទេ គេដាក់* ***នេត សាវ៉ាត*** ។

**ចារ៉ា:** *ឈ្មោះថ្មីៗឥឡូវហ្នឹង?*

**សាវ៉ាត:** *អត់ទេផ្លាស់តាំងពីសម័យជំនាន់តស៊ូមក* ។

**ចារ៉ា:** *បាទ! តាំងពីជំនាន់តស៊ូអ៊ំប្រើឈ្មោះ...?*

**សាវ៉ាត:** ***នេត សាវ៉ាត*** ។

**ចារ៉ា:** ***នេត សាវ៉ាត****? ដល់ពេលឥឡូវប្រើឈ្មោះ* ***នេត ថា*** ។

**សាវ៉ាត:** *អត់ទេ! ឥឡូវអត់ប្រើ* ***នេត ថា*** *ទេ* ***នេត ថា*** *តាំងពីកើតមក* ។

**ចារ៉ា:** *តាំងពីកើតមកគឺដាក់* ***នេត ថា****?  ហើយអាយុប៉ុន្មានឆ្នាំហើយអ៊ំ?*

**សាវ៉ាត:** *អាយុប្រហែល ៥៩ទៅហើយ* ។

**ចារ៉ា:** *៥៩?*

**សាវ៉ាត:** *បាទ! ឆ្នាំម្សាញ់* ។

**ចារ៉ា:** *ឆ្នាំម្សាញ់?  អ៊ំស្រុកកំណើតៗ?*

**សាវ៉ាត:** *ស្រុកកំណើតបើរៀបរាប់វែងឆ្ងាយណាស់ វាវែងដែរ* ។

ចារ៉ា: កន្លែងកើត?

សារ៉ាត: កន្លែងកើតវាឆ្ងាយដែរ ។

ចារ៉ា: នៅណាទៅអ៊ឹ?

សារ៉ាត: សុវណ្ណខែត ។

ចារ៉ា: កើតនៅសុវណ្ណខែត? ខេត្ត?

សារ៉ាត: បានបាក ភូមិណា! ភូមិបាក ។

ចារ៉ា: ភូមិបាក? ឃុំអីគេដែរ?

សារ៉ាត: ឃុំណាំណោ ។ (ណាំជាភាសាឡាវថាទឹក, ណោជាភាសាឡាវថាស្អុយ) ។

ចារ៉ា: ណាំណោ? ទឹកស្អុយ?

សារ៉ាត: អត់ទេ!

ចារ៉ា: ហើយស្រុក?

សារ៉ាត: កេងកង ។

ចារ៉ា: កេងកង? ខេត្ត?

សារ៉ាត: សុវណ្ណខែត ។

ចារ៉ា: ខេត្តសុវណ្ណខែត? ប្រទេសអីទៅ?

សារ៉ាត: ប្រទេសឡាវ ។

ចារ៉ា: ប្រទេសឡាវ? អញ្ចឹងអ៊ឹមកនៅស្រុកខ្មែរតាំងពីឆ្នាំណា?

សារ៉ាត: មកនៅស្រុកខ្មែរ និយាយទៅតាំងពីអាយុ១០ឆ្នាំ ។

ចារ៉ា: អាយុ១០ឆ្នាំ មកនៅស្រុកខ្មែរ? អាយុ១០ឆ្នាំ ប្រហែលជានៅក្នុងឆ្នាំណាហ្នឹ? លោកអ៊ីចាំទេ?

សារ៉ាត: ឥឡូវ វាអាយុ ៥៩ ។

ចារ៉ា: អញ្ចឹង! ពេលអ៊ឹមកនៅស្រុកខ្មែរ មកនៅស្រុកខ្មែរមុនដំបូង មកនៅក្នុងស្រុកអី? ភូមិអី?

សារ៉ាត: ភូមិពាមជីមៀត ។

ចារ៉ា: មកពីស្រុកឡាវក្លាម មកនៅស្រុកខ្មែរ គឺនៅភូមិពាមជីមៀតយើងហ្នឹងហ្នឹ?

សារ៉ាត: បាទ!

ចារ៉ា: ហើយបន្ទាប់មកទៀតមានទៅនៅណា?

**សារ៉ាត:** បន្ទាប់មកណឹង ក៏វាមានសង្គ្រាម មានបញ្ហារឿងសង្គ្រាម តស៊ូសង្គ្រាម ។

**ចារ៉ា:** សង្គ្រាមជាមួយអ្នកណាដែរ?

**សារ៉ាត:** សង្គ្រាមចលនាតស៊ូ ។

**ចារ៉ា:** តស៊ូប្រឆាំងជាមួយអ្នកណាដែរ?

**សារ៉ាត:** កាលនោះតស៊ូប្រឆាំង លន់ ណុល ។

**ចារ៉ា:** លន់ ណុល? ហើយអ៊ំចូលរួមនឹងគេដែរ?

**សារ៉ាត:** បាទ! ជាមួយ **ដាន ឃោន** ជាមួយគ្នានោះដែរ ។

**ចារ៉ា:** ហើយអ៊ំអាចនិយាយរៀបរាប់ពីទំនាក់ទំនងអ៊ំជាមួយ **ដាន ឃោន** បានទេ?

**សារ៉ាត:** ចឹមិនបាន ។

**ចារ៉ា:** ត្រូវជាយ៉ាងម៉េច? ហើយស្គាល់គ្នាពីអង្កាល់? ហើយធ្លាប់ធ្វើការអីខ្លះជាមួយគ្នា?

**សារ៉ាត:** បាទអាណឹងបើនិយាយទៅម្យ៉ាង ក៏ជាខ្សែសាច់ញាតិដែរ ។

**ចារ៉ា:** សាច់ញាតិយ៉ាងម៉េចទៅ?

**សារ៉ាត:** សាច់ញាតិបងប្អូនជីដូនអីទៅ វាឆ្ងាយគ្នាដែរណា ក៏ប៉ុន្តែបើនិយាយថា ខុះខាតអ៊ី យើងពឹងពាក់លើគ្នាបានណា! មកដល់សម័យ តាំងពី៦០ថ្វាយមកណឹង តាំងពីនយោបាយប្រទេសជាតិយើងណឹងណា មានចលនាតស៊ូអាចឹកំបាំង ក្នុងសុខទុក្ខជាមួយគ្នាដែរ ។

**ចារ៉ា:** **ដាន ឃោន** ណឹង បានទៅតស៊ូទៅជាមួយអ៊ំដែរ?

**សារ៉ាត:** ទៅជាមួយគ្នា ។

**ចារ៉ា:** ហើយក្រោយមកទៀត?

**សារ៉ាត:** ហើយក្រៅពីនោះ ក៏ច្រើនដែរណា បើនិយាយវែងឆ្ងាយទៅវាទូទាំងស្រុកអ្នកភូមិ ពិសេសខេត្តរតនគិរីណឹងទាំងអស់ កាលណឹងអញ្ចឹង។ ដល់មកឆ្នាំ៦៨ហ្នឹង ក៏បែកបាក់ភូមិ ព្រាត់ប្រាស់ចូលព្រៃ ។

**ចារ៉ា:** បែកបាក់ភូមិ ភូមិណា?

**សារ៉ាត:** ភូមិជីមៀត ឃុំម្ទើល បើនិយាយខេត្តរតនគិរីយើងហ្នឹង ស្រុកកោះញែកយើង បែកបាក់ចូលព្រៃ ទៅរស់នៅក្នុងព្រៃ អត់បាយក្រហាយទឹក មិនថាអត់តាំងបាយ អត់តាំងទឹកទៀត ។

**ចារ៉ា:** ហើយកាលតស៊ូ អ្នកណាជាមេនាំតស៊ូទៅ?

**សារ៉ាត:** ដំបូងណឹង ក៏ឃើញថាវៀតណាមជាមួយខ្មែរយើង ក៏សហករណ៏គ្នាដែរកាលណោះដំរាបជូនគ្រន់ សហការណ៏វៃចក្រពត្តិអាមេរិកនោះ ហើយ លន់ ណុល ជាបរិវា ។

**ចារ៉ា:** ចុះក្រែងចេញតស៊ូៗ របៀបអញ្ចឹងហេ៎ របៀបតស៊ូប្រឆាំងជាមួយ លន់ ណុល?

**សារ៉ាត:** ណឹងហើយ ប្រឆាំងជាមួយអាមេរិកដែលឈ្លានពានទឹកដី អញ្ចឹង ។

**ចារ៉ា:** តើអ៊ំអាចដឹងអ្នកណាដឹកនាំអ៊ំទេ ពេលចលនាតស៊ូណឹង?

**សារ៉ាត:** អាណឹងក៏វាដឹងខ្លះដែរ មិនថាមិនដឹងទេ ។

**ចារ៉ា:** បាទៗ! អាចរៀបរាប់បានទេ?

**សារ៉ាត:** អ្នកឃើញមុខណឹង ក៏ឃើញដែរ ប៉ុនគេផ្លាស់ឈ្មោះថ្មី ។

**ចារ៉ា:** ឈ្មោះពីមុនឈ្មោះអី?

**សារ៉ាត:** ឈ្មោះ... តាមួយណឹង តា**ឌុច** ។

**ចារ៉ា:** តា**ឌុច**?

**សារ៉ាត:** បាទ!

**ចារ៉ា:** អ៊ំធ្លាប់ស្គាល់មុខទេ? ធ្លាប់ជួបមុខទេ?

**សារ៉ាត:** ធ្លាប់រួមដំណើរគ្នាដែរ ។

**ចារ៉ា:** ហើយនរណាទៀត?

**សារ៉ាត:** តា**ឌុច** ប៉ុន្តែដំបូង ខ្ញុំភ្លេច អាណឹងវាឆ្ងងហើយ ដំបូងគេឈ្មោះ តា**គុណ** ។

**ចារ៉ា:** តា**គុណ**?

**សារ៉ាត:** បាទ!

**ចារ៉ា:** តា**គុណ** ហើយហៅម៉េចទៅ **គុណ**?

**សារ៉ាត:** **គុណ** ។

**ចារ៉ា:** មានឈ្មោះក្រៅទេ?

**សារ៉ាត:** ដឹង បើខ្ញុំធ្លាប់ហៅតែបង **គុណ**ៗ ។

**ចារ៉ា:** អូ តា**គុណ**!

**សារ៉ាត:** ចាប់ពេលនោះមក គាត់ផ្លាស់ ដល់សម័យរំដោះ៧០ហ្នឹង ផ្លាស់មកជា **ឌុច** វិញ ។

**ចារ៉ា:** ឈ្មោះ **ឌុច** វិញ?

**សារ៉ាត:** បាទ

**ចាន់:** ផ្លាស់មក **ធុច**?

**សារ៉ាត:** បាទ! ផ្លាស់មក **ធុច** វិញ ។ ហើយមួយទៀតណឹង **តាយ៉ា** ។

**ចាន់:** យ៉ា?

**សារ៉ាត:** បាទ!

**សុរិយ៉ា:** យ៉ា មានឈ្មោះអីផ្សេងទេ?

**សារ៉ាត:** **តាយ៉ា** នៅដល់៧០ហើយ គេផ្លាស់ឈ្មោះមក **តាឈឿន** ។

**ចាន់:** តាឈឿន?

**សុរិយ៉ា:** ចុះមានស្អីទៀតទេ?

**ចាន់:** ក្រោយមកទៀត មានផ្លាស់ឈ្មោះទៀតទេ?

**សារ៉ាត:** ទេ! អត់ទេ ខាងក្រោយមកគេចាប់ ចាប់គាត់មកក្រចេះឆ្នាំ៧៧, ៧៨ ទូង៧៩ ។

**ចាន់:** ចាប់ យ៉ា ណឹង?

**សារ៉ាត:** ចាប់ យ៉ា ហើយត្រូវជាយកប្អូនខ្ញុំទៀត ។

**សុរិយ៉ា:** យ៉ា ណឹងត្រូវប្អូនថ្លៃ?

**សារ៉ាត:** បាទ!

**ចាន់:** យ៉ា ណឹងត្រូវប្អូនថ្លៃរបស់អ៊ំ?

**សារ៉ាត:** បាទ!

**ចាន់:** អញ្ចឹងប្រពន្ធ យ៉ា ឈ្មោះអីអញ្ចឹង?

**សារ៉ាត:** អាណឹង យ៉ា ណឹង ឈ្មោះកំណើត ធំម៉ា ។

**ចាន់:** យ៉ា ណឹងឈ្មោះកំណើត?

**សារ៉ាត:** អត់ទេ! ប្រពន្ធ ។

**ចាន់:** ប្រពន្ធ? អូ!

**សារ៉ាត:** ធំម៉ា ។

**សុរិយ៉ា:** ធំម៉ា!

**សារ៉ាត:** នេត ធំម៉ា ឪពុកណាអ្នកណា ។

**ចាន់:** ធំម៉ា? ហើយពេលចាប់ទៅ ឥឡូវប្រពន្ធនៅរស់ទេ?

**សារ៉ាត:** អត់ទេ! ស្លាប់អស់ហើយ កាល៧០ណឹង ខ្ញុំជាប់ដែរ ។ ៧៥ ជាប់នៅភ្នំពេញជាប់នៅក្រចេះ គាត់មកកាន់ភូមិភាគឥសាន ។

**ចាន់ា:** អញ្ចឹងត្រឡប់មករឿងទំនាក់ទំនងអ៊ំ និង **ដាន យោន** វិញ?

**សារ៉ាត:** មកដល់នេះមានអ្នកស្គាល់ណោះ ហើយ **តាយ៉ែម** ក៏ស្គាល់ដែរ ។

**ចាន់ា:** អញ្ចឹងអ៊ំនិយាយតទៅទៀតពីរឿងអ៊ំស្គាល់ **ដាន យោន** ហ្នឹង? ដល់ពេលក្រោយមកម៉េចទៅ?

**សារ៉ាត:** ដល់ណោះ ក៏រួមចលនាគ្នាចូលព្រៃទាំងអស់ណា តស៊ូមករំដោះជាតិស្រុកហើយ ក៏គាត់ធ្វើការទៅ ... គាត់ឈរជើងនៅក្រចេះណា ។

**ចាន់ា:** គាត់ឈរជើងនៅក្រចេះឆ្នាំណា?

**សារ៉ាត:** ឆ្នាំ តាំងពី ៧១, ៧២ មក ។

**ចាន់ា:** ៧១, ៧២ **ដាន យោន** ឈរជើងនៅក្រចេះ?

**សារ៉ាត:** បាទ ។

**ចាន់ា:** មានតំណែងជាអ្វីដែរ?

**សារ៉ាត:** តំណែងខាងពាណិជ្ជកម្ម សេដ្ឋកិច្ចពាណិជ្ជកម្ម ប៉ុនតំណែងរបស់គេ វាកម្មាភិបាលដែរនោះ

**ចាន់ា:** ហើយក្រោយមកទៀត?

**សារ៉ាត:** ហើយ... គាត់ក៏នៅតែ នៅធ្វើការខាងពាណិជ្ជកម្មជាប់នៅណឹងហើយ ។

**ចាន់ា:** ជាប់រហូតហ្នឹងហ៎?

**សារ៉ាត:** ជាប់រហូត ។

**ចាន់ា:** ដល់ឆ្នាំណា?

**សារ៉ាត:** ដល់ឆ្នាំ៧៧ហើយណឹង មហឹកយើង ឆ្នាំ៧៧ណឹង ត្រូវគេធ្វើ ចាប់គាត់ ។

**ចាន់ា:** នៅក្នុងចន្លោះដែលគាត់ធ្វើការពី៧២ ដល់ ៧៧ ធ្វើការជាពាណិជ្ជកម្មហ្នឹង តើគាត់ កិច្ចការគាត់ធ្វើអ្វីខ្លះ? អ៊ំមានដឹងទេ?

**សារ៉ាត:** អត់ទេ អត់ដឹង ខ្ញុំដឹងតែថាធ្វើពាណិជ្ជកម្ម ។

**ចាន់ា:** ចុះអ៊ំដឹងថាធ្វើពាណិជ្ជកម្មតាមរយៈអីដែរទៅ បានដឹង?

**សារ៉ាត:** ពាណិជ្ជកម្មណឹងវា....

**ចាន់ា:** ហេតុអីបានអ៊ំដឹងថា **ដាន យោន** ហ្នឹងធ្វើការខាងពាណិជ្ជកម្ម? ហេតុអីបានអ៊ំដឹង?

**សារ៉ាត:** អូ! ដឹងហើយ ព្រោះការចាត់តាំងវាអញ្ចឹង បាទ! តំបន់ចាត់តាំង ទទួលការងារពាណិជ្ជកម្មមក ពីមជ្ឈិមមកណា មជ្ឈិមផ្តល់អោយគាត់ គាត់ណឹងដឹកពីភ្នំពេញមកដល់ក្រចេះ គាត់មាន ការកិច្ចទាក់ទងជាមួយមជ្ឈិម ខាងមជ្ឈិម ។

**សុរិយ៉ា:** អ៊ំឃើញគាត់ដឹកហ្នឹង? ឃើញគាត់ដឹកឥវ៉ាន់ ដឹកអី យកមកចែកប្រជាជន?

**សារ៉ាត:** និយាយមិនឃើញម៉េច! សួរក្មួយទាំងអស់ទៅ ។

**សុរិយ៉ា:** អញ្ចឹងបានយើងដឹងខាងពាណិជ្ជកម្ម?

**សារ៉ាត:** បាទ! អាណឹងជាក់ស្តែងអញ្ចឹង ការចាត់តាំងក៏អញ្ចឹងដែរ ។

**ចារ៉ា:** នៅក្នុងចន្លោះដែល....

**សារ៉ាត:** សួរប្រជាជនទាំងអស់ទៅ ។

**ចារ៉ា:** បាទ! ក្នុងពីចន្លោះ៧២ ដល់ ៧៧ ណឹង អ៊ំធ្វើអីដែរ?

**សារ៉ាត:** ខ្ញុំ?

**ចារ៉ា:** បាទ!

**សារ៉ាត:** ខ្ញុំធ្វើសេដ្ឋកិច្ចដែរ ។

**ចារ៉ា:** សេដ្ឋកិច្ចៗជាមួយអ្នកណា?

**សារ៉ាត:** សេដ្ឋកិច្ចនៅក្នុងតំបន់ ។

**ចារ៉ា:** នៅក្នុងតំបន់?

**សារ៉ាត:** ជាមួយ **ខាំ ភួន** ។

**ចារ៉ា:** តំបន់អីគេ?

**សារ៉ាត:** តំបន់១០៥ ។

**ចារ៉ា:** តំបន់១០៥? សេដ្ឋកិច្ចៗណឹងម៉េចទៅ?

**សារ៉ាត:** ទទួលខាងស្រូវអង្ករ គោ ក្របី ពី ៧០មក ។

**ចារ៉ា:** ហ៊ី អ៊ំមានឋានៈអីដែរ សេដ្ឋកិច្ចណឹង ជាប្រធានក្រុម ឬប្រធានអី?

**សារ៉ាត:** អឺ ជាប្រធាន គ្រប់គ្រងមួយអង្គភាពអញ្ចឹងណា ។

**ចារ៉ា:** គ្រប់គ្រងមួយអង្គភាព?

**សារ៉ាត:** បាទ! អង្គភាព ២០, ៣០នាក់ ប៉ុណ្ណឹងទេ ។

**ចារ៉ា:** អង្គភាពអីគេទៅអ៊ំ?

**សាវ៉ាត:** អន្តភាពសេដ្ឋកិច្ច ទទួលភារកិច្ច ស្រូវ អង្ករ គោ ក្របី មាន់ ទា ណឹងណា មិនមែនគណៈតំបន់ទេ មិនមែនទេ បំរើការងារសេដ្ឋកិច្ចតាមដោយផ្នែកណឹងណា ។

**ចាវ៉ា:** ហើយកិច្ចការសេដ្ឋកិច្ចណឹងគេបែងចែកម៉េចទៅ? ឥឡូវឧទាហរណ៍ថា អ៊ំធ្វើខាងសេដ្ឋកិច្ចចុះការទាក់ទងរវាងអ៊ំទៅលើ ទៅអី ទាក់ទងម៉េចទៅ?

**សាវ៉ាត:** ខ្ញុំទាក់ទងជាមួយតា **ខាំ ភូន** ។

**ចាវ៉ា:** អញ្ចឹង?

**សាវ៉ាត:** បាទ! តា **ខាំ ភូន** ណឹង គេគណៈតំបន់ ១ គេទទួលផ្នែកខាងសេដ្ឋកិច្ចអញ្ចឹងណា ស្អីនៅលើគេទាំងអស់ ពាណិជ្ជកម្មនៅលើគេ ស្អីនៅលើគេទាំងអស់ គណៈតំបន់ណឹងបាទ ។

**ចាវ៉ា:** ពាល់កិច្ចការ **ខាំ ភូន** ត្រូវធ្វើអី ទាក់ទងមកខាងអន្តភាព អ៊ំអញ្ចឹងទៅ ទាក់ទងរបៀប ម៉េច?

**សាវ៉ាត:** អាណឹង បើគាត់មានផែនការណ៍អ៊ីៗណឹងណា ដូចជាឧទាហរណ៍ គេមកស្នើអង្ករ ស្នើអី ។

**ចាវ៉ា:** អ្នកណាគេមកស្នើ ឧទាហរណ៍?

**សាវ៉ាត:** ឧទាហរណ៍ថា កងទ័ព ឬក៏ខាងប្រជាជន ត្រូវការស្អី ស្រូវពូជ ស្រូវធារមានស្អីៗទាក់ទងខ្ញុំ ។

**ចាវ៉ា:** ហើយអ៊ំធ្វើម៉េចទៀត?

**សាវ៉ាត:** ខ្ញុំ ក៏បញ្ចេញអោយគេ ។

**សុរិយ៉ា:** គេសរសេរសំបុត្រមក ឬក៏អោយនិរសាមកប្រាប់ ឬមួយក៏ម៉េច?

**សាវ៉ាត:** និរសាក៏មាន សំបុត្រក៏មាន ។

**សុរិយ៉ា:** មិនដែលមកប្រាប់ផ្ទាល់ទេហ៎?

**សាវ៉ាត:** មកចុះផ្ទាល់ក៏ចុះដែរ ។

**ចាវ៉ា:** ពេលរត់សំបុត្រមកអញ្ចឹង អ្នកណាគេអ្នករត់សំបុត្រ? មានចុះហត្ថលេខា មានចុះអីដែរសំបុត្រ?

**សាវ៉ាត:** អឺ សម័យណឹង ក៏តាមណឹងដែរណា តាមទម្លាប់របស់គេអញ្ចឹងដែរ ។

**ចាវ៉ា:** ទម្លាប់គេធ្វើម៉េចទៅ?

**សាវ៉ាត:** គេសរសេរសំបុត្រមកថា ឥឡូវអន្តភាព យោធានេះគេទៅស្នើអង្ករណា សុំសមមិត្តជួយដោះស្រាយផងណា ។

**ចាវ៉ា:** អញ្ចឹងអ៊ំអាចឧទាហរណ៍សំបុត្រណាមួយដែលអ៊ំបានឃើញហើយចាំដល់ពាល់ថ្ងៃទេសំបុត្រដែលគេថាស្នើសុំយ៉ាងម៉េចៗ អ៊ំឧទាហរណ៍សំបុត្រណាមួយច្បាស់បានទេ?

**សារ៉ាត:** អត់ទេ សំបុត្រផ្ញើតាមធម្មតា ។

**ចារ៉ា:** ធម្មតា ប៉ុន្តែចង់អញ្ចេះ ចង់និយាយថា ខ្លឹមសារសំបុត្រណឹង អ៊ំមានចាំ អ៊ំលើកឧទាហរណ៍សំបុត្រណាមួយដែលអ៊ំចាំច្បាស់ ឧទាហរណ៍ថា គេស្នើសុំអង្ករម៉េចៗណឹងណា សំបុត្ររបស់អ្នកណាមួយបានទេ? មានចាំទេ ?

**សារ៉ាត:** កាលនោះវាក៏មានដែរ វាថាស៊ីយអីនោះឯង គាត់ស្នើ ·ឧទាហរណ៍ទៅណា គាត់ខានយោធាខានអង្ករ សូម មេត្តាស្រាយជួយផង ជួនណាមានអន្តភាពណាមួយទៀត តាសុភា តាអីអញ្ចឹងណា អាណឹងខានយោធាទេ ។

**ចារ៉ា:** គេសរសេរសំបុត្រមកទេអញ្ចឹង?

**សារ៉ាត:** គេសរសេរសំបុត្រមក ។

**ចារ៉ា:** សំបុត្រណឹងដាក់ក្នុងស្រោមបិទជិត ហ្អីកាន់?

**សារ៉ាត:** អត់ទេ ប៉ុន្តែបិទៗ **ជួន**កាលបិទជិតទៅ **ជួន**ណាក៏បិទធម្មតាទៅ ក៏វាមិនឆ្ងាយគ្នាវាជិតៗគ្នាក្នុងម៉ារុន្ទ័ណឹង ។

**ចារ៉ា:** ដល់ពេលគេសរសេរមក អ្នកដែលស្នើណឹងគេមានចុះឈ្មោះ? ចុះហត្ថលេខា ចុះអីដែរ?

**សារ៉ាត:** បាទ! ចុះដែរ ។

**ចារ៉ា:** ដល់ពេលអ៊ំឃើញទៅ.... ។

**សារ៉ាត:** បើសិនជា **ខាំ ភួន** គេក៏ចុះហត្ថលេខា **ខាំ ភួន** ។

**ចារ៉ា:** អ៊ំបើកអោយគេទៅ?

**សារ៉ាត:** បាទ!

**ចារ៉ា:** ហើយអ៊ំមានដឹងអីទៀត ពី **ដាន ឃោន** ណឹងទេ?

**សារ៉ាត:** អត់ទេ ដឹងតែគេធ្វើពាណិជ្ជកម្ម ។

**ចារ៉ា:** អ៊ំដឹងចាប់ពីឆ្នាំណាមក អ៊ំដឹងថាគាត់ធ្វើពាណិជ្ជកម្ម?

**សារ៉ាត:** អាណឹងរៀបចំពីឆ្នាំណាទេ រៀបចំពី៧០ (... គាត់និយាយភាសាឡាវ) ពី៧១, ៧២មក ។

**ចារ៉ា:** ពី៧២, ៧២ ដល់ឆ្នាំណា?

**សារ៉ាត:** បានគាត់ គេៗចាប់គាត់ ពី៧១, ៧២ មកទល់នឹង៧៧

**ចារ៉ា:** កាលចាប់ **ដាន ឃោន** អ៊ំមានដឹងរឿងរ៉ាវខ្លះទេ?

**សារ៉ាត:** អត់ទេ ក៏គេចាប់ពួកខ្ញុំមុន ដាក់ក្នុងគុក ដាក់៨០នាក់ ។

**ចារ៉ា:** ដាក់គុកណា?

**សារ៉ាត:** ដាក់គុកនៅភ្នំក្រោល ។

**ចារ៉ា:** នៅភ្នំក្រោល?

**សារ៉ាត:** គុកណឹងមិនមែនផ្ទះគេធ្វើហា... ផ្ទះ២ជាន់ៗ ផ្ទះ សាលារៀន ទាហានកម្មាភិបាល ពេលណាកម្មាភិបាលកោះអញ្ជើញមកប៉ុន្មានៗ គេមករៀននៅនេះ ។ ក្រោយមកធ្វើជាគុកបណ្ដាយពួកខ្ញុំ អាជាន់ទីក្រោម អាជាន់ពីលើប៉ុន្មាននាក់ ទាំងឪពុកគាត់ណឹង អ្នកដែលគេហៅថ្នាក់លើពីពួកខ្ញុំគេដាក់ពីលើ ពុកែគេដោះខ្នោះ ពុនោមប្រួចៗដាក់កន្ទោរ ។

**ចារ៉ា:** ពេលចាប់ ដាក់ខ្នោះទេ?

**សារ៉ាត:** ពួកនៅលើដាក់ខ្នោះ ពួកខ្ញុំអត់ដាក់ទេមានតែចងស្លាបសេក ចងជើង ។

**ចារ៉ា:** នៅលើដាក់ខ្នោះពេលហ្នឹង អីពុសូរអីបានអីជីងដាក់ខ្នោះ?

**សារ៉ាត:** ពុសូរគេកាស់ស្នៀតខ្នោះ ។

**ចារ៉ា:** ខ្នោះធ្វើពីអី តាមអីពុសូរ?

**សារ៉ាត:** ធ្វើពីឈើ ។

**ចារ៉ា:** ឈើធ្វើខ្នោះយ៉ាងម៉េចទៅ?

**សារ៉ាត:** ឈើអញ្ចឹងគេលាក់ ហើយសិកជើង ហើយដាក់ពីលើវៃដែកគោលដ្អិបៗ រួចហើយគេធ្វើស្នៀត

**ចារ៉ា:** ពួកថ្នាក់លើត្រឹមណា ដែលគេយកដាក់គុកនៅជាន់លើហ្នឹង? ចាប់ពីកំរិតណា?

**សារ៉ាត:** ចាប់ពីជួរស្រុកពីដើមគេ ហៅលេខាស្រុក ។

**ចារ៉ា:** ពេលដាក់អីមានជីងនរណានៅលើខ្លះទេ?

**សារ៉ាត:** ជីងខ្លះៗ ឈ្មោះ **វ៉ា**, ថា, កាចាន់ ពីណាទៀត......

**ចារ៉ា:** ចុះ **ផាន ឃោន** ហ្នឹងអីមានជីងទេនៅលើ?

**សារ៉ាត:** **ផាន ឃោន** ហ្នឹងពេលចាប់ពួកខ្ញុំ គាត់ក៏ចូលមកមានមេក្រូតូចមួយគាត់ចូលមកប្រកាស ។

**ចារ៉ា:** **ផាន ឃោន** ហ្នឹងអ្នកប្រកាស?

**សារ៉ាត:** **ផាន ឃោន** ហ្នឹងអ្នកប្រកាស ។

**ចារ៉ា:** ប្រកាសនៅកន្លែងណា?

**សារ៉ាត:** ប្រកាសនៅជាន់ក្រោម កន្លែងពួកខ្ញុំ ។

**ចារ៉ា:** ថាយ៉ាងម៉េចខ្លះ?

**សាវ៉ាត:** ប្រកាសហ្នឹង គាត់ថា និយាយតាមពាក្យគាត់ណា សូមគោរពបងប្អូនជនរួមជាតិ ជាទីគោរព ជាទីស្នេហា ខ្ញុំសូមប្រកាសជូនអោយបងប្អូនបានជ្រួតជ្រាបទាំងអស់ បញ្ហាបងប្អូនគឺមូលហេតុមកពីអា**ទាំភូន** ខ្លាចបងប្អូនភិតភ័យ បានជាឃាត់ខ្លួន ហើយគាត់គាងតាមជាគណៈតំបន់ ។

**ចារ៉ា:** អញ្ចឹងមានន័យថា **ដាន ឃោន** ហ្នឹងជាអ្នកចាប់ប្រជាជនយកទៅដាក់គ្រង់ហ្នឹង?

**សាវ៉ាត:** អត់ទេ គេអ្នកចាប់ ប៉ុន្តែ ។

**ចារ៉ា:** ប៉ុន្តែម៉េចទៅ?

**សាវ៉ាត:** គាត់ជាអ្នកប្រកាស ។

**ចារ៉ា:** ប្រកាសដើម្បីអីទៅ?

**សាវ៉ាត:** ដើម្បីកុំអោយយើងភិតភ័យ ។

**ចារ៉ា:** កុំអោយអ្នកដែលជាប់ឃុំភិតភ័យ ?

**សាវ៉ាត:** បាទ ! ខ្លាច់រត់តាពីសតាពាសអញ្ចឹងទៅណា កាលប៉ុន្មានថ្ងៃក្រោយមកណឹង**គុណ**ខ្ញុំមីនៅផ្ទះខាងកើត វានៅក្រមុំដែរនៅនារី ពួកអានេះក៏បញ្ជូនទៅបត់ជើង ។

**ចារ៉ា:** បញ្ជូនអ្នកណាគេ?

**សាវ៉ាត:** **គុណ**ខ្ញុំចង់បត់ជើង ដូច្នេះគេក៏បើកទ្វារអោយចេញទៅបង់ជើង តែគេតាមជាប់ដែរគេការពារជាប់ ដូច្នេះមីនេះវានិយាយហើយដឹងវានិយាយថាម៉េចទេ វាថានិយាយពីរឿងអ៊ំ **ដាន ឃោន** វាហៅអ៊ំ១ អាការពារចាំបាច់ហៅថា អ៊ំធ្វើអីអាក្បត់ វាថាញ្ចឹងណា អានេះបានដឹងថាពេលមកដល់គេអង្គុយជិតគ្នាគេខ្សិបទៅមើលឥឡូវ តា**ជួន** គេចាប់បាត់ទៅហើយ ។

**ចារ៉ា:** តា**ជួន** ជាអ្នកណា?

**សាវ៉ាត:** តា**ជួន** ហ្នឹងគឺ **ដាន ឃោន** ។

**ចារ៉ា:** មានដឹងអីទៀតទេ?

**សាវ៉ាត:** អត់ទេ ។

**ចារ៉ា:** ចុះ**គុណ**អ៊ំអាចដឹងរឿងហ្នឹងទេ?

**សាវ៉ាត:** វាអត់ដឹងអីទេ ។

**ចារ៉ា:** អ៊ំដឹងតាមរយៈអញ្ចឹងតាមរយៈ**គុណ**មកវិញនិយាយ?

**សាវ៉ាត:** បាទ! ណឹងហើយ ដល់វាចេញបានជាងកន្លះខែ ក៏គេដោះលែងពួកខ្ញុំ ។

**ចារ៉ា:** ទៅនៅគុកហ្នឹងបានជាងកន្លះខែ?

**សារ៉ាត:** *ដាំងកន្ទះខែ នៅក្នុងចំណាំងក្នុងគុក ។*

**ចារ៉ា:** *ចង់រហូត?*

**សារ៉ាត:** *បាទចង់រហូត ដល់វែងមកវិញបានដឹងថាគ្រោះថ្នាក់ ។*

**ចារ៉ា:** *ដឹងម៉េចទៅ?*

**សារ៉ាត:** *ដឹងពិតថាគេចាប់* **ផាន ឈោន** *មែន ។*

**ចារ៉ា:** *ដឹងតាមរយៈអ្នកណា?*

**សារ៉ាត:** *ដឹងតាមគេឯងនៅហ្នឹងណា វាមិនអាចសម្គាត់បានទេ ។*

**ចារ៉ា:** *គេនិយាយតៗគ្នា?*

**សារ៉ាត:** *និយាយតៗគ្នា ថា* **ផាន ឈោន** *ក្បត់ ។*

**ចារ៉ា:** *គេចោទថាក្បត់អញ្ចឹង? ចុះបើតាមអ៊ំស្គាល់ អ៊ំដឹងថាតើអំពើទាំងប៉ុន្មានដែល* **ផាន ឈោន** *ធ្វើជាអំពើក្បត់ ដូចដែលពួក ប៉ុល ពត ចោទប្រកាន់ដែរឬអត់?*

**សារ៉ាត:** *អត់ដឹងដែរ និយាយអោយត្រង់ បើអត់ឃើញគេទេ បើឱ្យបខ្សៀវពីនាយអាយ ក្រោយមកដូចអត់ពុ ។*

**ចារ៉ា:** *ពេលទៅដល់គុក ដឹងថាគេចាប់តែម្តង?*

**សារ៉ាត:** *បាទ!*

**ចារ៉ា:** *ចាប់ហើយគេចោទ...?*

**សារ៉ាត:** *ទេគ្រាន់តែពុដំណឹងទេ មិនឃើញនឹងភ្នែកទេ ។*

**ចារ៉ា:** *ខ្ញុំចង់សួរអ៊ំ កាលពីពេលគេមកចាប់អ៊ំ តើនរណាមកចាប់?*

**សារ៉ាត:** *ដំបូងគេដាក់សំបុត្រមកអោយទៅប្រជុំ ។*

**ចារ៉ា:** *អ៊ំមានបានឃើញសំបុត្រហ្នឹងទេ?*

**សារ៉ាត:** *សំបុត្រហ្នឹងរបស់* **តាឡាំង** *ហៅ តាហម ។*

**ចារ៉ា:** *សរសេរមកអ៊ំឃើញផ្ទាល់ភ្នែកតែម្តង?*

**សារ៉ាត:** *ផ្ទាល់ភ្នែកហើយ សរសេរមកដាក់ថា ឥឡូវម៉ោង ២អញ្ជើញខ្ញុំអោយទៅប្រជុំនៅ ក-១៧ ។*

**ចារ៉ា:** *នៅ ក-១៧?*

**សារ៉ាត:** *បាទ! ខ្ញុំនឹកភ័យក្នុងចិត្តបន្តិចដែរ វាប្លែកព្រោះកាលមុនអត់បានទៅប្រជុំនៅណាំងទេ ។*

**ចារ៉ា:** *វាល់ដងទៅប្រជុំនៅឯណា?*

**សារ៉ាត:** ប្រជុំនៅក្រៅ នៅមន្ទីរពេទ្យ អង្គភាពពេទ្យ ដល់មានការប្រែប្រួលទៅគាត់ថា ទៅប្រជុំនៅ ក-១៧ ខ្ញុំធ្លាក់ទឹកចិត្តគុក ។

**ចាន់:** គ្រាន់តែឃើញសំបុត្រហ្នឹង ?

**សារ៉ាត:** ពេលឃើញសំបុត្រ ប៉ុន្តែខ្ញុំនឹកឃើញថា មិនច្បាស់អ្នកណាទេ ខ្ញុំគ្មានទស្សនៈច្បាស់ ហើយខ្ញុំទៅ ។

**ចាន់:** អ៊ំទៅ? ទៅរបៀបម៉េច?

**សារ៉ាត:** គេយកឡានមក មកយក ដំបូងគេអោយមើល ទទួលខុសត្រូវ មើលគេធ្វើក្បួនដាក់ម៉ាស៊ីនទឹកណា ដូច្នេះខ្ញុំក៏ប្រាប់អ៊ំៗ ឥឡូវថា អ៊ំមើលគេធ្វើការ ធ្វើក្បួនធ្វើអីខ្ញុំមានការអោយទៅប្រជុំ នៅ ក-១៧ ។

**ចាន់:** អ៊ំហ្នឹងឈ្មោះអី?

**សារ៉ាត:** ឈ្មោះ **សំ** មេជាង គាត់ថាអត់អីទេទៅក៏ទៅចុះ ហើយខ្ញុំដើរទៅផ្ទះខ្ញុំ ទៅដល់ផ្ទះខ្ញុំៗក៏ចងអង្រឹងដេកខោអាវអាថ្មីអត់ស្លៀកទេ ស្លៀកអាល្អម អាចាស់បន្តិចណឹងណាគិតយកអាថ្មីនៅ ក្នុងថង់មកស្លៀកពាក់ក៏អត់ទេ ដល់នេះក៏ចងអង្រឹងដេកផ្ងារដាក់ដៃអញ្ចឹងស្រាប់មួយភ្លែតមោឡានគេមកវិញ ។

**ចាន់:** ឡានម៉ាកអីដែរអ៊ំ អាចចាំបានទេ?

**សារ៉ាត:** ឡានហ្នឹងគាត់កាត់ៗចិន ដល់ម្នាក់ណឹង អ្នកបញ្ជាគេ ភ្លេចហើយ ។

**ចាន់:** មានចាំឈ្មោះទេ?

**សារ៉ាត:** ឈ្មោះ ភាគ ។

**ចាន់:** មាននាទីជាស្អីភាគ?

**សារ៉ាត:** ភាគធ្វើការជាមួយគ្នាទេណឹង ធ្វើប្រធានដែរគ្រប់គ្រងអង្គភាព

**ចាន់:** អ្នកដែលយកឡានមកអកអ៊ំណឹង?

**សារ៉ាត:** បាទ នៅក្នុងអង្គភាពហ្នឹងគាត់ធ្វើជាប្រធានពួកខ្ញុំសមាជិក ប្រធានគ្រប់គ្រងអង្គភាពពេទ្យតំបន់ ប៉ុន្តែមិនមែនគណៈតំបន់ទេ គណៈតំបន់គេផ្សេង ប៉ុន្តែគាត់ជាប្រធានគ្រប់គ្រងអង្គភាពមន្ទីរពេទ្យ ដល់ឡានមកដល់មុខផ្ទះឡានឈប់ អ៊ំអើយចុះមកទៅ ខ្ញុំក៏ចុះមកជិះឡាន ជិះឡាន ទៅមុខទៅយកម្នាក់ទៀត គាត់ហ្នឹងជាអនុរបស់ **តាជាត** ឈ្មោះ **ប៊ូឡៃ** ទៅទាំងប្តីទាំងប្រពន្ធ, អាប្តីដាក់ជាន់លើប្រពន្ធដាក់ក្រោម ។

**ចាន់:** អ៊ំទៅម្នាក់ឯងទេ អត់បានកូនចៅទៅទេ?

**សារ៉ាត:** អត់ទេ ខ្ញុំទៅតែឯង ។

**ចារ៉ា:** អឺចាំទេ ពេលមកហៅនៅថ្ងៃណា ខែណា ឆ្នាំណា?

**សារ៉ាត:** មកហៅឆ្នាំ១៩៧៧ ថ្ងៃ១ ខែ១១ ថ្ងៃគេចាប់ កាលណុងឡានគេបើកវូចូលទៅហៅទៅ ក-១៧ អាតៃកុងឡានវាមិនដឹងស្មានថា ដឹកពួកខ្ញុំធ្លាប់ទៅធ្វើការ ក៏មានខ្ទមតូចមួយ ខ្ទមសំលាប់ អា**ហម** គេអ្នកធ្វើការប្រធានតំបន់វាក៏បត់ឡានចូលទៅ ស្រាប់តែ**ផាន ឃោន**គេឈរនៅហ្នឹង គេបត់ដៃ ។

**ចារ៉ា:** ឈរនៅកន្លែងណា?

**សារ៉ាត:** ឈរនៅខ្ទមមិនមែនទេ ព្រោះពីខ្ទមទៅចំងាយប្រហែលបង្គោលភ្លើងណឹងដែរ ប្រហែលជា ៥០ម៉ែត្រ ដល់គេស៊ីញ៉ូវដៃគេទប់ឡាន ឡានវាប្រុងបត់មកខាងនេះ ចូលផ្ទះ**ហម** កន្លែងធ្លាប់ធ្វើការ ព្រោះវាធ្លាប់ដឹកមកធ្វើការរហូតមកអញ្ចឹងពេលមុនៗ ដល់អញ្ចឹងទៅគេស្រែកស៊ីញ៉ូដៃឲ្យឡានបត់ទៅខាង ខាងសាលាគុក ។

**ចារ៉ា:** **ផាន ឃោន** អ្នកធ្វើដៃបត់ទៅសាលាគុក?

**សារ៉ាត:** បាទ! **ផាន ឃោន** ឈរទីនោះគេទុកឡានឈប់អញ្ចឹងហើយគេស៊ីញ៉ូដៃអោយចូលទៅតាមណោះ ដល់ចូលដល់ខាងនោះក៏ផ្ទះថ្មនោះវាធំទូលាយដល់ឡាន ឈប់ ឈប់ត្រង់ណឹង ម្នាក់ជិះនៅកាប៊ីនវាមិនទាន់ចុះផុត ស្រាប់តែអាមួយកងពលវាបញ្ជាចុះមក វាដាក់សំដីរាងធ្ងន់បន្តិច ប៉ុន្តែអត់ភ័យទេក្នុងខ្លួនអត់ទេ ។

**ចារ៉ា:** មួយដែលបញ្ជាណឹងកងពលលេខប៉ុន្មាន?

**សារ៉ាត:** អាណឹងកងពលលេខប៉ុន្មាន... គេហៅកងពល តាសាន ខ្ញុំថាកុំអាលអោយអ្នកនៅកាប៊ីន ចុះសិន គេបិទទ្វារចាំខ្ញុំចុះ ដល់គេណឹងចេញទៅខ្ញុំគេបិទទ្វារចូលមកខ្ញុំក៏ជាន់អាទ្វារឡាន ចុះទៅ ឃើញតា**សុភា** ចេញក្លែតមក គាត់អត់មានសំដីតូចធំអីទេ ។

**ចារ៉ា:** តា**សុភា** មានឋានៈជាស្អីដែរ?

**សារ៉ាត:** តា**សុភា** កាលណុងឋានៈកងអនុសេនាធំដែរនៅក្នុងជួរតំបន់ខ្ញុំក៏ចូលទៅអាម្នាក់ណឹងក៏សុំចាប់ ។

**ចារ៉ា:** ម្នាក់ណាអ៊ំ?

**សារ៉ាត:** អាម្នាក់ណឹងស្លាប់ហើយឈ្មោះ **ធាង** សុំចាប់ ។

**ចារ៉ា:** មាននាទីជាស្អីដែរ?

**សារ៉ាត:** ជាទាហាន ប៉ុន្តែ **សុភា** ណឹងអត់រវល់ស្អីទេ គាត់ថាចូលមកគាត់បត់ដៃអោយចូល អាចាប់វានៅខាងក្នុងឥឡូវសុំចាប់, ចាប់ក៏ចាប់ទៅ ខ្ញុំអង្គុយអោយចង ។

**ចារ៉ា:** យកអីចង?

**សាវ៉ាត:** យកខ្មែរអង្គ្រើន ដោះយកនាឡិកា ម៉ាកម៉ូឌីយ៉ា ប៉ុន្តែ **ដាន យោន** អត់ចូលទេគោលការណ៍ ទាល់តែថ្ងៃប្រកាសទេបានចូល ។

**ចាវ៉ា:** ពេលចាប់អីហើយយកទៅណាទៀត? ពេលចាប់ចងហើយ?

**សាវ៉ាត:** ពេលចងហើយគេអោយទៅនៅកៀនម្នាងចងជាប់ អង្គុយតំរៀបគ្នាជាវង់ ។

**ចាវ៉ា:** ចងជាប់នឹងស្អី?

**សាវ៉ាត:** ចងជាប់ជាមួយគុ គេដាក់បៀតជញ្ជាំង ដល់ថ្ងៃក្រោយបានយកប្រពន្ធខ្ញុំទៅដោយប្រាប់ថាឥឡូវ យើងទៅបុណ្យ ។

**ចាវ៉ា:** រំលងប៉ុន្មានថ្ងៃអីមានចាំទេ?

**សាវ៉ាត:** ថ្ងៃនេះខ្ញុំ ថ្ងៃស្អែក ប្រាប់ថាធ្វើបុណ្យ ធ្វើស្អី ដឹកទាំងឡាន ។

**ចាវ៉ា:** ដឹកទាំងអីស្រីទៀត?

**សាវ៉ាត:** ណឹងហើយ ថ្ងៃក្រោយមកដឹកគាត់ទៀត ។

**ចាវ៉ា:** តែអីស្រីទេ មានកូនចៅដែរ?

**សាវ៉ាត:** មាន ទៅទាំងអស់ មីបងគេនោះចង ខ្ញុំចងម៉ែគេចងមីងបង......(ចប់ ៗ)

**ចាវ៉ា:** អញ្ចឹងម៉ាក្រុមគ្រួសារ អីមានប៉ុន្មាននាក់ដែរ?

**សាវ៉ាត:** ក្រុមគ្រួសារខ្ញុំមាន ខ្ញុំ ម្តាយគេ, **វុធ, វ៉ាត, ហៀង, វាន, ជាតិ** ដឹកយកទៅមន្ទីរពេទ្យយក ទៅចាប់ ។

**ចាវ៉ា:** អញ្ចឹង ៧នាក់ ហើយចងប៉ុន្មាននាក់?

**សាវ៉ាត:** ៣នាក់ ។

**ចាវ៉ា:** ដាក់នៅកន្លែងណា?

**សាវ៉ាត:** ដាក់នៅជាន់ក្រោមទាំងអស់គ្នា ។

**ចាវ៉ា:** បន្ទាប់មកទៀត?

**សាវ៉ាត:** ប្អូនម្នាក់ ហើយបងម៉ាក្រុមគ្រួសាររបស់គាត់ ។

**ចាវ៉ា:** បងរបស់អី?

**សាវ៉ាត:** បាទ! បងបង្កើត ។

**ចាវ៉ា:** ហើយអ្នកណាទៀត?

**សាវ៉ាត:** ហើយក្រៅពីនោះ ក៏មានដែរ បងជីដូនមួយ ហើយនិងអ្នកដទៃខ្លះ ៨០នាក់ ។

**ឆារ៉ា:** ក្នុងមួយបន្ទប់ក្រោម?

**សារ៉ាត:** បាទ ជាន់ក្រោម ព្រោះជាន់ក្រោម អត់ធ្វើបន្ទប់ទេ ទូលាយទាំងអស់ ។

**ឆារ៉ា:** អ៊ំមានដឹងថា អ្នកទាំងអស់នោះមានកំហុសអីបានគេចាប់?

**សារ៉ាត:** គេចោទថា ខ្សែរយៈវៀតណាម ហើយ **ខាំ ភូន** ក្បត់ព្រោះ ភូន ក៏ខ្សែរយៈវៀត ណាម ដល់ពួកខ្ញុំទៀត ។

**ឆារ៉ា:** អញ្ចឹងមានន័យថា អ៊ំធ្វើការនៅពីក្រោម **ខាំ ភូន** ហើយពេលដែលគេចោទ **ខាំ ភូន**ជាវៀតណាម គេចាប់ក្រុមខ្សែ **ខាំ ភូន** ទៀត សាច់រឿងអញ្ចឹង?

**សារ៉ាត:** បាទសាច់រឿង វាអញ្ចឹង ។

**ឆារ៉ា:** ពេលរស់នៅក្នុងគុកចងរហូតអត់អោយចេញទៅណាទេ?

**សារ៉ាត:** ចងរហូតអោយដែរទៅបត់ជើង ប៉ុន្តែគេបណ្តើរអញ្ចឹងហើយស្រាយជើង អោយដើរទៅបត់ជើង ហើយគេបណ្តើរយើងទៅហើយកាំភ្លើងគេ ។

**ឆារ៉ា:** អ្នកបណ្តើរស្លៀកពាក់យ៉ាងម៉េចដែរ?

**សារ៉ាត:** ស្លៀកពាក់ខ្មៅ ទាហានកងពល ។

**ឆារ៉ា:** មានកាំភ្លើងទៀត?

**សារ៉ាត:** មានគ្រប់ដៃ គេប្រកាន់អញ្ចឹងហើយណា គេការពារអ្នកទោស បើទឹកមិនដឹងប៉ុន្មានថ្ងៃទេបាន ខ្ញុំបានងូតទឹក ។

**ឆារ៉ា:** អ៊ំមានចាំទេ ប៉ុន្មានថ្ងៃបានងូតទឹកម្តង?

**សារ៉ាត:** ខ្ញុំភ្លេចដែរ ជាងមួយអាទិត្យមិនដឹង ១០ថ្ងៃមិនដឹងបានៗងូតទឹក ។

**ឆារ៉ា:** ទឹកហ្នឹងងូតយ៉ាងម៉េច?

**សារ៉ាត:** គេធ្វើទំនប់រៀងល្អក់បន្តិចដែរ ស្រាយតែជើងបណ្តើរទៅហើយគេក៏ដើរទៅ ។

**ឆារ៉ា:** ចុះដៃនៅជាប់ទេ ពេលងូតទឹក?

**សារ៉ាត:** អត់ទេ ដល់កន្លែងទឹកស្រាយដែរ គេអន្ទុយជុំវិញការពារយើង ពេលងូតទឹករួចរាល់ហើយស្លៀកពាក់ហើយចងទៀតបានបណ្តើរមកគុក ។

**ឆារ៉ា:** ចុះដល់ពេលហូបចុកធ្វើម៉េចទៅ?

**សារ៉ាត:** អើយពេលហូបចុកដាំបាយអោយហូបដែរ ពេលមួយខែហូបបន្លែល្ពៅ ។

**ឆារ៉ា:** មានដាក់សាច់អីដែរ?

**សារ៉ាត:** ដាក់ដែរ ឃើញមួយចានមាន ២-៣ដុំ ។

**ចារ៉ា:** ចុះអ៊ំមានដឹងថា នៅជិតអ៊ំ៨០នាក់ណឹង មានបាត់មនុស្សខ្លះទេ? ឬក៏គេអាចយកទៅណាផ្សេងទៀតទេ?

**សារ៉ាត:** មានយកទៅ ពេលគេជំលៀស ប៉ុន្តែភាគតិចគេជំលៀសទៅលិច ។

**ចារ៉ា:** ទៅលិចទៅខាងណា?

**សារ៉ាត:** ទៅខាងក្រចេះ នោះភាគច្រើនត្រឹមណោះ គេដឹកពីនោះមកដាក់ត្រឹមណោះ ដាក់ពួកខ្ញុំគេហៅថាដាក់ការដ្ឋាន ។

**ចារ៉ា:** ដាក់ការដ្ឋានអី?

**សារ៉ាត:** ការដ្ឋានណាងឃីលឹក ។

**ចារ៉ា:** កាលជំនាន់នោះគេហៅ ណាងឃីលឹក តែម្តង?

**សារ៉ាត:** បាទ អាណឹងវាប្រវត្តិត្រពាំង ត្រពាំងហ្នឹងវាមានដើមដង្ហិតដុះនៅក្នុងត្រពាំង បានឡាវមានពាក្យថា ណាងឃីលឹក ។

**ចារ៉ា:** ណាងៗ ភាសាឡាវ?

**សារ៉ាត:** ណាងៗ គឺត្រពាំង ។

**ចារ៉ា:** ជាភាសាឡាវណាងៗ?

**សារ៉ាត:** បាទ! ជាភាសាឡាវ ដង្ហិតហ្នឹងភាសាឡាវគេថា គុកណាងឃីលឹក ខ្មែរថា ដើមដង្ហិតកាលមុនវាដុះណែនត្រពាំងណឹង ឥឡូវមិនសូវសំបូរប៉ុន្មានដែរ ។

**ចារ៉ា:** ដល់ពេលអញ្ចឹងគេដាក់ឈ្មោះណាងណាងឃីលឹកទេ? រហូតដល់សព្វថ្ងៃ?

**សារ៉ាត:** បាទរហូតដល់សព្វថ្ងៃ ។ មកដាក់ត្រង់នេះរហូត ។

**ចារ៉ា:** ចុះដល់អញ្ចឹងខាងជាន់លើអ៊ំ យ៉ាងម៉េចទៅ?

**សារ៉ាត:** ជាន់លើពួថា ដឹកទៅលិច ប៉ុន្តែអាណឹងមិនដឹងដឹកទៅណា អត់ដឹងទេ ប៉ុន្តែយើងពួល្បៀងៗមក ថាមិនរស់ទេ មិនដឹកទៅលិច ដឹងដល់លិច ឬមិនដល់ ។

**ចារ៉ា:** ពេលដែលអ៊ំជួប **ដាន ឃោន** ដែលគាត់និយាយមេក្រូ បន្ទាប់ពីណឹងមកយ៉ាងម៉េចទៀតទៅអ៊ំ?

**សារ៉ាត:** អត់មានស្អីទេ ជួបតែមួយថ្ងៃ ។

**ចារ៉ា:** ជួបតែមួយថ្ងៃ មុនដំបូងដែល **ដាន ឃោន** មកប្រកាសណឹង?

**សារ៉ាត:** បាទ ហើយក៏ចេញទៅ ។

**ឆារ៉ា:** គាត់ដើរចេញទៅ?

**សារ៉ាត:** ដើរចេញទៅ ។

**ឆារ៉ា:** មិនមែនបានន័យថា គេចាប់ទេ?

**សារ៉ាត:** អត់ទេ អត់ចាប់ នៅកន្លែងណឹងទេ ខ្ញុំឮថា ចាប់នៅឯណោះ ឮបញ្ជូនទៅខាងភ្នំពេញបន្តិច ។

**ឆារ៉ា:** ឮយ៉ាងម៉េចដែរ?

**សារ៉ាត:** អត់ដឹងដែរ ភ្នែកមិនឃើញ ។

**ឆារ៉ា:** កាលពីគាត់ប្រកាសមេក្រូអ៊ីមានដឹងថា គាត់មានតំណែងស្អីដែរ បានជាមានសិទ្ធិប្រកាសមេក្រូ?

**សារ៉ាត:** គាត់ថា ជំនួសគណៈតំបន់ ។

**ឆារ៉ា:** ជំនួសគណៈតំបន់ណឹងឈ្មោះអី?

**សារ៉ាត:** **ខាំ ភួន** ណឹងក្បត់ហើយ គាត់ជំនួស ជំនួសតា **ហម សារិន** ។

**ឆារ៉ា:** អ៊ីមានដឹងពីទំនាក់ទំនងរវាង **ខាំ ភួន** ជាមួយ **ហម**, ឈ្មោះ **ឡាំង** មានដឹងទំនាក់ទំនងគ្នាយ៉ាងម៉េចទេ? មនុស្ស២នាក់ហ្នឹង?

**សារ៉ាត:** អូ អាណឹង បើនិយាយប្រវត្តិពីដើមគេហ្នឹងស្និតគ្នាមែនទែន ។

**ឆារ៉ា:** ស្និតយ៉ាងម៉េច?

**សារ៉ាត:** ធ្វើការងារជាមួយគ្នាដូចជាបងប្អូន ។

**ឆារ៉ា:** ចុះក្រោយមកយ៉ាងម៉េចទៅ?

**សារ៉ាត:** ទុកចិត្តថ្មើមគ្នាសំបើមមែនទែនណាស់ នេះមិនមែនស្តាប់គេនិយាយទេណា គឺឃើញផ្លាប់រួមប្រា-ស្រ័យគ្នាធ្វើការងារក្នុងជួរកម្មាភិបាលទុកចិត្តលើ ២នាក់ហ្នឹងទុកចិត្តគ្នាមែនទែនតែម្តង ។

**ឆារ៉ា:** រហូតដល់ឆ្នាំណា?

**សារ៉ាត:** រហូតដល់ឆ្នាំ៧៧ ។

**ឆារ៉ា:** ដែលនៅជិតស្និតនឹងគ្នា?

**សារ៉ាត:** ឆ្នាំ៧៧ អាណឹងបានឮដំណឹងថា គេវៃគ្នានៅភ្នំពេញគេសំលាប់គ្នានៅភ្នំពេញ អា**ភួន** និងអា**ហម** ។

**ឆារ៉ា:** ឈ្មោះ **ឡាំង**ណឹង? ឮតាមអ្នកណា អ៊ីដឹងតាមអ្នកណា?

**សារ៉ាត:** ឈ្មោះ **ឡាំង** ឮគេនិយាយមិនដឹងពីណាៗនិយាយ ។

**ចាន់:** ពុថាវ៉ៃគ្នា? វ៉ៃគ្នាដល់ថ្នាក់ណាទៅ?

**សារ៉ាត:** ណឹងហើយ គេថាចាប់ **ខាំ ភូន** ព្រោះ **ខាំ ភូន** ក្បត់ ។

**ចាន់:** គេណឹងអឺសំដៅលើអ្នកណាគេ?

**សារ៉ាត:** ពុគេនិយាយទូទៅ គេនិយាយពាសវាលពាសកាលទៅណា ។

**ចាន់:** ថាម៉េច?

**សារ៉ាត:** គេចាប់ **ខាំ ភូន** នាំយកទៅភ្នំពេញ ប៉ុន្តែទៅភ្នំពេញអត់ទៅដល់កន្លែងទីពទេ នៅពាណិជ្ជកម្ម ខាង ១០៥ មន្ទីរពាណិជ្ជកម្ម ១០៥នេះតាមដំណឹងគេនិយាយណា មិនមែនឃើញនឹងភ្នែកទេ ដល់នេះទៅក៏នាំគ្នាដេកថ្ងៃ **ខាំ ភូន** ក៏យកដែកវ៉ៃ**ឡាំង**ងាប់ ហើយយកកាំភ្លើងខ្លី **ឡាំង** បាញ់ថែមទៀត គាត់បាញ់ខ្លួនគាត់ទៀតងាប់ជាមួយគ្នា អញ្ចឹងណា ប៉ុន្តែការពិតមិនដឹងមែន ឬ មិនមែន ខ្ញុំក៏អត់ដឹងដែរណា ។

**ចាន់:** អ៊ំគ្រាន់តែដឹងតាមគេតាមឯងមក?

**សារ៉ាត:** ដឹងតាមគេតាមឯងណឹងណា ។

**ចាន់:** ហើយក្រោយមក អ៊ំមានដឹងដំណឹង **ផាន ឃោន** យ៉ាងម៉េចទេ?

**សារ៉ាត:** អត់មានដឹងទេ ។

**ចាន់:** ចុះចំពោះអ៊ំផ្ទាល់ ដែលគេដោះលែងពីគុកនៅភ្នំក្រោល ពេលក្រោយមកទៀត?

**សារ៉ាត:** គេដោះលែង ហើយគេដឹកឡានយកមកដាក់នេះ ។

**ចាន់:** ដឹកឡានដដែល?

**សារ៉ាត:** បាទ! ទាំងអស់គ្នា ឡានចិន ដឹកដាក់ត្រង់នេះ ហើយក៏គេអោយច្រូតស្រូវអី ដាំចេក ដាំអីទៅ បាន១ឆ្នាំ វៀតណាម ចូលរំដោះ ។

**ចាន់:** មកនៅណងណងឃីលីក បានតែមួយឆ្នាំ?

**សារ៉ាត:** បានតែ១ឆ្នាំ វៀតណាមចូលមកដល់ ប៉ុន្តែចូលមកខែច្រូតអញ្ចឹង ។

**ចាន់:** មកខែច្រូត?

**សារ៉ាត:** បាទ! ដល់ខែច្រូតណឹងត្រូវរត់ វៀតណាមចូលមករំដោះទៀត នាំគ្នារត់ទៅភាសខ្លួនដល់អូរ ទឹងឡាំង ម្តងនេះវិទ្យុគេប្រកាសថា រំដោះភ្នំពេញហើយបកមកវិញ ។

**ចាន់:** នៅពេលដែលគេដឹកអ៊ំមកដាក់ណងណងឃីលីកណឹង គេមាននិយាយប្រាប់ថាម៉េចទេ? នរណា ដឹកមកអ៊ំ?

**សារ៉ាត:** តា ***សុភា*** គាត់ខាងទាហាន ។

**ចារ៉ា:** ដឹកមកហើយ គាត់និយាយថាម៉េចតា ***សុភា***?

**សារ៉ាត:** ដឹកមកហើយ គាត់ក៏ប្រកាសថា ឥឡូវអត់អោយមានសិទ្ធិដើរហើរទៅខាងកោះញែកមានសិទ្ធិដើរហើរទៅខាងទន្លេ ។

**ចារ៉ា:** ខាងទន្លេខាងអី?

**សារ៉ាត:** ទឹកដីយើងដែរ ទន្លេហ្នឹងជិតទេណា ។

**ចារ៉ា:** ទន្លេហ្នឹងទន្លេអី?

**សារ៉ាត:** ទន្លេស្រែពក រកស៊ីរកចុកអីណឹងទៅ អោយបងប្អូនកែប្រែខំកសាងខ្លួន ។

**ចារ៉ា:** មានរឿងរ៉ាវអីផ្សេងកើតឡើងទៀតទេ ពេលដែលអ៊ំមករស់នៅណងណងឃីលីក?

**សារ៉ាត:** អត់ទេ អត់មានទេ ។

**ចារ៉ា:** មានដែលមានរឿងរ៉ាវថា មានជនក្បត់អី ដុតស្រូវដុតអីណា?

**សារ៉ាត:** អត់មានទេ អាណឹងវារឿង រឿងដុតស្រូវណឹងមកពីវៀតណាម គេវៃសំរុកចូលមកអាចំពអាពត វាចាញ់ហើយវារត់ចោលដុតចោល កុំអោយពីណាបានស៊ី គោលការណ៍វាអញ្ចឹងណា ម្ដុំ អត់បានដុតទេ បងមកវិញបានខ្ញុំបែនយកស្រូវ ទៅនៅជិតកោះញែក ។

**ចារ៉ា:** ខ្ញុំសុំបកមកសួរកន្លែងភ្នំក្រោល តើនៅភ្នំក្រោលមានមន្ទីរអីខ្លះរបស់ពួក ប៉ុល ពត អ៊ំមានដឹងទេ?

**សារ៉ាត:** ដឹង មន្ទីរ ក-១៧ ជាកន្លែងរបស់ ***ឡាំង***, មន្ទីរ ក-១១ កន្លែងរបស់ ***សុភា***, មន្ទីរ ក-២០ នៅស្រែសង្គម អាហ្នឹងតាម៉ីនៅ មន្ទីរកន្លែងខ្ញុំ មន្ទីរ ក-២១ជុំវិញភ្នំក្រោល ។

**ចារ៉ា:** ពូមានអាចដឹងទេថា ហេតុអីបានជាគេដាក់ ក-១១, ក-១៧, ក-២១? ចង់សំដៅលើអី?

**សារ៉ាត:** អាណឹងវាមិនដឹងដែរ ឲ្យចំណាំលេខមន្ទីរ ។

**ចារ៉ា:** អត់មានន័យអីផ្សេងទេ?

**សារ៉ាត:** អត់ទេ ។

**ចារ៉ា:** ជួនកាលវាមានដល់ ម-ប ?

**សារ៉ាត:** ដូចជា រ-៣, ស្រុកប៉ុន្មានគេដូរសព្វាំងអស់ រ-៣, រ-៤, រ-២ ស្រុកពេជ្រចិន្តា, កែវសីម៉ា, អូរាំងផ្លាប់ពីកំណើតមកណា គេដូរសព្វាំងអស់ ។

**ចារ៉ា:** ចុះអ៊ំមានដឹងទេស្រុក រ-៣ សំរាប់ស្រុកអីពីដើម? រ-៣ ជំនាន់ ប៉ុល ពត ត្រូវអីពីដើម?

**សារ៉ាត:** ចង់ភ្លេចខ្លះ ពេជ្រចិន្តា ។

**ចារ៉ា:** ចុះ រ-១?

**សារ៉ាត:** រ-១ កោះញែក ។

**ចារ៉ា:** រ-២?

**សារ៉ាត:** រ-២ វាភ្លេចដែរក្មួយ វាយូរហើយ ។

**ឆាន:** ចុះរ-៤ អ៊ំ?

**សារ៉ាត:** កែវសីម៉ា ។

**ចារ៉ា:** អញ្ចឹងសម័យ ប៉ុល ពត នៅតែក្នុងវង្វង់ខេត្តមណ្ឌលគិរីណឹងទេ?

**សារ៉ាត:** បាទ!

**ចារ៉ា:** អត់មានទៅកន្លែងណាផ្សេងទេ?

**សារ៉ាត:** ទៅដែរ ទៅភ្នំពេញម្តង ។

**ចារ៉ា:** ទៅភ្នំពេញធ្វើអីអ៊ំ?

**សារ៉ាត:** ទៅដេកពេទ្យ ។

**ចារ៉ា:** អ៊ំឈឺអីកាលណឹង?

**សារ៉ាត:** វាឈឺ បើតាមពេទ្យគឺរាគ ។

**ចារ៉ា:** ការព្យាបាលរបស់ពេទ្យយ៉ាងម៉េចទៅ?

**សារ៉ាត:** បានធូរខ្លះ ប៉ុន្តែ ចេះតែថ្មែអញ្ចឹងទៅទៀតម្តង ក្មួយស្គាល់ **ជួន ជឿន** ទេ? **ជួន ជឿន** ខ្មែរក្រហម ចូលខ្មែរក្រហម ។

**ចារ៉ា:** ចុះនៅភ្នំក្រោល អ៊ំមានឃើញសភាពការណ៍អីផ្សេងទៀតទេ?

**សារ៉ាត:** ក្រោយៗមានដែរ ចាប់ប្អូនថ្លៃខ្ញុំចាប់យកទៅដាក់ភ្នំក្រោល ហើយមានច្រើនគេទៅទៀត ។

**ចារ៉ា:** គេយកទៅដាក់ភ្នំក្រោលណឹង?

**សារ៉ាត:** បើមិនយកទៅដាក់នៅហ្នឹងដាក់នៅឯណា ចាប់ហើយយកទៅភ្ជាមសម្លាប់ចោល ។

**ចារ៉ា:** ហ៊ី រាល់ថ្ងៃមានដំណឹងអីដែរបងប្អូន?

**សារ៉ាត:** អត់ អាប្អូនថ្លៃទាំងប្តី ទាំងប្រពន្ធ ទាំងកូន ទាំងចៅបាត់រហូត អាប្អូនខ្ញុំក៏អញ្ចឹងដែរ ប្អូនខាងខ្ញុំណា បាត់រហូត ។

**ឆារ៉ា:** អ៊ំអាចចាំបានទេ ថាតើម៉ាជំនាន់ដែលគេចាប់អ៊ំយកទៅដាក់នៅភ្នំក្រោល តើបងប្អូនអ៊ំប៉ុន្មាននាក់ដែលគេចាប់ទៅ? ហើយប៉ុន្មាននាក់រស់ និងប៉ុន្មាននាក់ដែលបាត់ ឬ ក៏ស្លាប់?

**សារ៉ាត:** ចាំបាន បើខាងប្អូនថ្លៃខ្ញុំកូន ២ ឪពុកម្តាយ បើខាងខ្ញុំគេចាប់នៅក្រចេះ ដំបូងចាប់តែប្តីទេ តា **យ៉ា** គាត់ធ្វើប្រធានភូមិភាគឥសាន ប្រពន្ធមកម៉ាហឹកនេះ គឺថាសម័យវៀតណាមចូលមកហើយបែកភូមិ មិនដឹងជាគេយកទៅសំលាប់នៅកន្លែងណា ចំណែកប្អូនស្រី និងកូនពីរនាក់ កូនប្រុសទាំងពីរ ។

**ឆារ៉ា:** ឥឡូវអត់ដឹងដំណឹង?

**សារ៉ាត:** ដឹងដំណឹងគឺថា គេស្លាប់ ។

**ឆារ៉ា:** ហើយបាត់អ្នកណាទៀត?

**សារ៉ាត:** បងប្អូនខ្ញុំតែប៉ុណ្ណឹង ប៉ុន្តែខាងណោះមានព្រោះខេត្តគេផ្សេង ។

**ឆារ៉ា:** ខេត្តគេផ្សេងតែបងប្អូនអ៊ំដែរ?

**សារ៉ាត:** បាទ

**ឆារ៉ា:** ប៉ុន្មាននាក់ទៀតទៅ?

**សារ៉ាត:** បងប្អូនខ្ញុំខាងភូមិស៊ីដាណឹងវា កូនបងពីរនាក់ អាម៉ាហឹក វៀតណាមរំដោះហើយ ទ័ពវាចូលមកឆ្នាក់ម្តងៗចាប់សំលាប់ កូនគាត់២នាក់ ។

**ឆាង:** ហើយអ្នកទាំងអស់គ្នាសុទ្ធតែជាប់នៅណឹងត្រូវគេសម្លាប់ ឬមួយក៏នៅមានរស់ខ្លះ អ្នកដែលអ៊ំនិយាយអម្បាញ់មិញ មាននៅរស់ខ្លះ?

**សារ៉ាត:** គេដាក់ជាប់នៅភ្នំក្រោល ។

**ឆាង:** នៅរស់ ឬស្លាប់ទាំងអស់?

**សារ៉ាត:** បងប្អូនខ្ញុំអាស្លាប់ៗ អារស់ៗ ។

**ឆាង:** មាននៅរស់ប៉ុន្មាននាក់? ឈ្មោះអីខ្លះ?

**សារ៉ាត:** មានតែបងប្អូន ។

**ឆាង:** អ្នកជាប់នៅភ្នំក្រោល ហើយនៅរស់មកវិញមានអ្នកណាខ្លះ?

**សារ៉ាត:** ច្រើនដែរណឹងណា (សើច) និយាយម៉ាក្រុមគ្រួសារខ្ញុំទាំងអស់តែម្តង ហើយនិងបងខ្ញុំម៉ាក្រុមគ្រួសារគាត់ទាំងអស់ ហើយប្អូនខ្ញុំតែម្នាក់វាទេ នៅដល់សព្វថ្ងៃ ហើយបាត់ប្អូនថ្លៃ ប៉ុន្តែប្អូនថ្លៃគេចាប់ក្រោយទេ អត់បានចាប់ម៉ាស្រុករខ្ញុំទេ ។

ចាន់: អ៊ំអាចដឹងពីគោលការណ៍គេចាប់យ៉ាងម៉េចទៅ? គោលការណ៍ចាប់មនុស្ស? របស់ពួកខ្មែរក្រហម?

សារ៉ាត: គោលការណ៍គេចាប់គេថា តា **ទាំ ភួន** ក្បត់ ពួកខ្ញុំនៅក្រោមការដឹកនាំរបស់គាត់ជាខ្មែរសាច់ញាតិ បងប្អូនគាត់ខ្លះអញ្ចឹងណា ប៉ុន្តែខ្ញុំក៏ជាខ្មែរសាច់ញាតិខាងខ្ញុំដែរ ខាងប្រពន្ធគាត់ទេ ។

ចាន់: ប្រពន្ធ **ទាំ ភួន** ឈ្មោះអីដែរអ៊ំ?

សារ៉ាត: ប្រពន្ធតា **ទាំ ភួន** ឈ្មោះ **ឡាប់** អាណឹងដែរទ្រាំនិងគេសម្លាប់មីងប្រពន្ធខ្ញុំបង្កើត ហើយកូនគាត់ម្នាក់ទៀត ។

ចាន់: ឈ្មោះអី?

សារ៉ាត: ឈ្មោះ **ទាំ** ។

ចាន់: អ៊ំមានដឹងទេថា ពេលគេមកចាប់ណឹងចាប់អ៊ំទៅជាប់ខ្សែខាង **ទាំ ភួន** ហើយអ្នកណាគេបញ្ជាមកចាប់?

សារ៉ាត: អានេះវាមានអ្នកធំគេដែរ មកពីអ្នកធំគេបញ្ជាបន្តបន្ទាប់មកណាកាលណឹងមានតា **សារុន** ។

ចាន់: តា **សារុន** គាត់មានតំណែងអីទៅ?

សារ៉ាត: ប្រធានខេត្ត ។

ចាន់: ប្រធានខេត្ត ជំនាន់ណឹងគេហៅអីទៅ?

សារ៉ាត: ប្រធានតំបន់ គេហៅលេខាតំបន់ ក៏ស្លាប់ទៅតា**ឡាំង**ហើយណា ស្លាប់តា**ភួន** ទៅមានតែតា **សារុន** ទេ ។

ចាន់: តា **សារុន** លេខាតំបន់អី?

សារ៉ាត: តំបន់១០៥ ។

ចាន់: ហើយគាត់មានសិទ្ធិត្រឹមណា លេខាតំបន់១០៥?

សារ៉ាត: សិទ្ធិគេវាទូទាំងខេត្តហើយណា បើយើងថាឥឡូវចៅហ្វាយខេត្ត ។

ចាន់: ហើយគាត់ធ្វើអីស្រេចតែចិត្តគាត់ ឬក៏អាចមានទទួលផែនការពីថ្នាក់លើ អីទៀត ដូចជាមជ្ឈិមអី?

សារ៉ាត: អត់ដឹងដែរ (សើច) ។

ចាន់: ពូមានដែលឮពាក្យមជ្ឈិមទេ?

សារ៉ាត: ថីមិនឮ ។

ចាន់: មជ្ឈមណ្ឌលគេចង់សំដៅថាម៉េច?

សារ៉ាត: ពីសម័យណឹងគេហៅមជ្ឈិមៗ គណៈមជ្ឈិមៗ ។

ចាន់: នៅពេលដែលអ៊ំឮពាក្យថាមជ្ឈិម អ៊ំមានអារម្មណ៍យ៉ាងម៉េចទៅ? មានអារម្មណ៍ថាធំ ប៉ុយ៉ាងណា?

សារ៉ាត: មជ្ឈិមវាធំដូចតា ហ៊ុន សែន សព្វថ្ងៃហើយណា ។

ចាន់: អូ! អោយតែឮពាក្យមជ្ឈិមគឺធំតែម្តង?

សារ៉ាត: ធំហើយ អូនមិនយល់ទេ សម័យកុម្មុយនិស្ត ព្រោះថានៅឡាវ គេហៅមជ្ឈិម ។

ចាន់: អ៊ំមានអីបន្ថែមទៀតទេ ដែលអ៊ំអត់បាននិយាយ? ក្រែងលចាំរឿងរ៉ាវអីផ្សេងទៀត?

សារ៉ាត: អត់មានទេ ។

ឆាង: អញ្ចឹងខ្ញុំសូមសួរបន្តិច ព្រោះកន្លងមកខ្ញុំមិនទាន់ឮសំណួរថា អ៊ំធ្វើខាងសេដ្ឋកិច្ចពីឆ្នាំណាទៅឆ្នាំណា? កាលពីកាន់ខាងសេដ្ឋកិច្ច ?

សារ៉ាត: តាំងពី៧០ មកដល់ ៧៥ ពី ៧៥មក គេសារខ្ញុំមកដាក់សេដ្ឋកិច្ចពេទ្យក្របខ័ណ្ឌវាតូចទេ កាលនោះសេដ្ឋកិច្ច តំបន់វាទូទាំងខេត្ត ដូចជាបុគ្គលិកបំរើការងារទេ មិនមែនខ្ញុំជាគណៈទេ បុគ្គលិកសំរាប់ខាងស្រូវអង្ករ គោ ក្របី ទៅណា ក្រោយមកនៅខាងពេទ្យ ឆ្នាំ១៩៧៥មក ។

ឆាង: រហូតមកដល់ធ្វើប្រធានឃុំ នៅឆ្នាំណាដែរ?

សារ៉ាត: ធ្វើប្រធានឃុំពីឆ្នាំ១៩៨៩ ។

ឆាង: មុន៨៩ អ៊ំធ្វើអី?

សារ៉ាត: អត់មានធ្វើអីទេ ។

សុរិយ៉ា: អ៊ំថា យ៉ាណឹង អ៊ំនិយាយកាលពីឈ្មោះ **ធុច** ឈ្មោះអីកាលពីនាំប្រជាជនតស៊ូដំបូង វៃជាមួយលន់ ណុល អ៊ំនិយាយដំបូង ចាប់ពីឆ្នាំណាមកដែលមានគេមកនាំតស៊ូ?

សារ៉ាត: អូ អាណឹងវាពីឆ្នាំ១៩៦៨ ។

សុរិយ៉ា: ដំបូងគេមកឃោសនាមកអីតាមរយៈអ្នកណា?

សារ៉ាត: តាមរយៈតា **ឡាំង** ។

សុរិយ៉ា: តា **ឡាំង** ឈ្មោះមួយទៀតហៅថាអី?

សារ៉ាត: ហម ។

សុរិយ៉ា: តែប៉ុណ្ណឹង អត់មានអីក្រៅពីណឹងទេ?

**សាវ៉ាត:** បាទ

**សុរិយ៉ា:** តា **ឡាំង** មកតែម្នាក់ឯង ឬមាននរណាទៀត?

**សាវ៉ាត:** បើនិយាយទៅវាច្រើន (សើច) អន្តរក្សរបស់គេដែរនោះ ។

**សុរិយ៉ា:** អូ មានអន្តរក្សតា **ឡាំង** ទៀត? តា **ឡាំង** ណឹងផ្សេងទេ ?

**សាវ៉ាត:** និយាយតាមឃើញ **តា ទី** ពីដើម ។

**សុរិយ៉ា:** គេហៅ**តា ទី** ដែរ? **តា ទី** ផ្សេងទៀត?

**សាវ៉ាត:** **តា ទី** ពុកអាស្ទីទេ មកពីកំពង់ចាម ។

**សុរិយ៉ា:** **តា ទី** មកពីកំពង់ចាម ប៉ុន្តែតា **ឡាំង** មកមុន?

**សាវ៉ាត:** អត់ទេ **តា ទី** ហើយចាស់ទុំមុនគេ រឿងនយោបាយគេពីដើម ។

**សុរិយ៉ា:** បន្ទាប់មកតា **ឡាំង**?

**សាវ៉ាត:** តា **ឡាំង** ទើបតែក្រោយទេ ។

**សុរិយ៉ា:** អញ្ចឹង **តា ទី** មកឆ្នាំណា?

**សាវ៉ាត:** ឆ្នាំ៦០ប្លាយ ។

**សុរិយ៉ា:** ៦០ប្លាយណាង មិនដឹងហុកម៉ានទេ ប៉ុន្តែ ៦៨ តា **ឡាំង** មក?

**សាវ៉ាត:** តា **ឡាំង** ជាមួយ **តា ទី** ហើយ ។

**សុរិយ៉ា:** អូ ជាមួយគ្នាតែម្តង ?

**សាវ៉ាត:** ជាមួយគ្នា ។

**សុរិយ៉ា:** តា **ឡាំង** មកពីខាងណាមក?

**សាវ៉ាត:** តា **ឡាំង** ភូមិកំណើតគាត់នៅទីនេះហើយ ។

**សុរិយ៉ា:** តា **ឡាំង** ភូមិកំណើតនៅនេះតែម្តង?

**សាវ៉ាត:** បាទ ស្រុកកំណើតគាត់នៅនេះហើយតា **ឡាំង** ។

**សុរិយ៉ា:** **តា ទី** នៅកំពង់ចាម?

**សាវ៉ាត:** បាទ!

**សុរិយ៉ា:** តា **ឡាំង** មានសំបុរ រាងរៅយ៉ាងម៉េចដែរ?

**សាវ៉ាត:** រាងខ្មៅបន្តិចដែរគាត់ ។

**សុរិយ៉ា:** ខ្មៅ មាឌធំទេ?

**សារ៉ាត:** អត់ទេ អត់សូវធំទេ រាងស្តើង ។

**សុរិយ៉ា:** ខ្ពស់ ឬទាប?

**សារ៉ាត:** ខ្ពស់ សំបុរខ្មៅជាងខ្ញុំ ។

**សុរិយ៉ា:** អញ្ចឹងខ្មៅស្រអែមរាងស្តើង ដូចអីអញ្ចឹង?

**សារ៉ាត:** បាទ!

**សុរិយ៉ា:** កំពស់ប្រហែលអីដែរ?

**សារ៉ាត:** បាទ ខ្ពស់ជាងខ្ញុំបន្តិច ។

**សុរិយ៉ា:** ប្រហែល ១,៦៥ម៉ែត្រ?

**សារ៉ាត:** ប្រហែលប៉ុណ្ណឹង ខ្ញុំ ១,៥០ម៉ែត្រ ។

**សុរិយ៉ា:** គាត់ច្រើនគាត់សក់ខ្លី ឬវែង?

**សារ៉ាត:** សក់ខ្លី ។

**សុរិយ៉ា:** ចុះ**តា ទី** យ៉ាងម៉េចដែររាងពេ?

**សារ៉ាត:** **តា ទី** ស ធាត់មិនធាត់ ស្គមមិនស្គមល្មម ។

**សុរិយ៉ា:** ចុះកំពស់ណាដែរ?

**សារ៉ាត:** ខ្ពស់ជាងតា **ឡាំង** ។

**សុរិយ៉ា:** ខ្ពស់ជាងតា **ឡាំង** អញ្ចឹងប្រហែលជា ១,៧០ម៉ែត្រ?

**សារ៉ាត:** ប្រហែល ១,៧០ម៉ែត្រ គាត់នោះវៀតណាមចេះប្រិល ។

**សុរិយ៉ា:** អញ្ចឹងពីរនាក់ណឹង តា **ឡាំង** នៅនេះទេ ហើយ**តា ទី** មកពីណោះមក មានដឹងថា មូលហេតុអី បាន**តា ទី** មកទេ?

**សារ៉ាត:** គេដឹកនាំចលនាតស៊ូ ។

**សុរិយ៉ា:** ចុះអីកាលណឹងគាត់ទំនាក់ទំនងយ៉ាងម៉េចបានឮដល់អី? អីដឹងតាមរយៈណាដែរ?

**សារ៉ាត:** គាត់មកតាមរយៈតា **ទាំ ភូន** ។

**សុរិយ៉ា:** គាត់មកតាមរយៈតា **ទាំ ភូន**?

**សារ៉ាត:** អើ ។

**សុរិយ៉ា:** គាត់ណឹងមកទំនាក់ទំនងជាមួយតា **ទាំ ភូន** ដែរអញ្ចឹង....?

**សារ៉ាត:** តា **ទាំ ភូន** តា **សារុន** តាស្អី គេចេះតែក្តោបក្តាប់ទៅតៗទៅ ។

**សុរិយ៉ា:** ហើអ៊ំមានទំនាក់ទំនងជាមួយតា **ខាំ ភួន** ក៏ដឹងពួនឹងគេទៅ?

**សារ៉ាត:** ណឹងហើយៗ គាត់ចេះតែក្តាប់យើងទៅក្តាប់ប្រជាជនទៅ ។

**សុរិយ៉ា:** កាលណឹងគាត់និយាយថាម៉េចបានជាអ៊ំយល់ព្រមចូលរួមជាមួយខបមាថាគេបបួលអ៊ំរកស៊ីអញ្ចឹង ទាល់អ៊ំចំណេញបានអ៊ំចូលរួមជាមួយ តើគេនិយាយយ៉ាងម៉េចបានជាអ៊ំសុខចិត្តចូលរួមជាមួយតស៊ូជាមួយគេ?

**សារ៉ាត:** គេថាឥឡូវចក្រពត្តិឈ្លានពានប្រទេសជាតិយើងនិយាយត្រឹមកម្ពុជាណាដើម្បី សេរីភាពគេហ៊ាន អញ្ចឹង ។

**សុរិយ៉ា:** អញ្ចឹងទៅអ៊ំក៏ចូលជាមួយទៅ?

**សារ៉ាត:** ៦-១ ថាវៃចក្រពត្តិឈ្លានពាន ៦-២ តាមទារសិទ្ធិសេរីភាព ។

**សុរិយ៉ា:** ម៉េចបានអ៊ំដឹងថា ចក្រពត្តិពិតជាឈ្លានពានមែន ពិតជាធ្វើបាបប្រជាជនខ្មែរយើងមែន អ៊ំដឹងពួតាមរយៈអី? អ៊ំឃើញផ្ទាល់ភ្នែក ឬក៏ពួគេថា ហើយជឿចូលតែម្តង ឬមួយអ៊ំឃើញមានសកម្មភាពអី ពួកណឹងធ្វើអីប្រជាជនយើងខ្លះបានអ៊ំជឿ?

**សារ៉ាត:** អាណឹងថាតាំងគេ តាំងឯងទៅណា (សើច) ខ្ញុំម្នាក់ក៏មិនមែនដែរ វាជាចលនាទៅ ។

**សុរិយ៉ា:** ចលនាចេះតែជឿទៅ? ប៉ុន្តែអត់មានឃើញអាមេរិកាំងមក ចក្រពត្តិមកធ្វើអីៗប្រជាជនអត់ឃើញទេ? អត់ដែលបានឃើញទេ?

**សារ៉ាត:** អត់ឃើញទេ អត់ដែលបានឃើញអាមេរិកាំងទេ ខ្ញុំ ។

**សុរិយ៉ា:** ចុះអ៊ំមានដែលបានឮសូរអីគ្រុងគ្រាំងអីទេ អត់ទេ?

**សារ៉ាត:** អាគ្រុងគ្រាំងកាលណឹងមិនទាន់ពួទេ ។

**សុរិយ៉ា:** មិនទាន់ពួទេ ៦៨អីណឹង?

**សារ៉ាត:** អត់ ។

**សុរិយ៉ា:** អញ្ចឹង **ឡាំង** ដី មកទំនាក់ទំនងជាមួយ **ខាំ ភួន** អីអញ្ចឹងទៅអ៊ំនៅជាមួយ **ខាំ ភួន**ដែរ ក៏ចាប់ផ្តើមចូលរួមជាមួយគេទៅ កាលគេមកណឹងអ៊ំធ្វើជាប្រជាជនធម្មតា ឬក៏អ៊ំជាប្រធានភូមិ ប្រធានឃុំ?

**សារ៉ាត:** ជាប្រជាជនធម្មតា ។

**សុរិយ៉ា:** ហើយតា **ផាន ឃោន** អីណឹង?

**សារ៉ាត:** តាណឹងក៏ធម្មតាដែរ ធ្វើស្រែ ធ្វើចំការស៊ី ទាក់ដរី រកត្រី រកសាច់ ។

**សុរិយ៉ា:** អញ្ចឹងដល់ពេលឆ្នាំ៦៨ ចាប់ផ្ដើមតស៊ូនៅក្នុងភូមិមួយ ឬមួយក៏ចេញទៅណាក្រៅពីភូមិដែរ?

**សារ៉ាត:** ដំបូងវាក្នុងភូមិ ។

**សុរិយ៉ា:** ចុះ៦៩?

**សារ៉ាត:** ៦៨តស៊ូនៅក្នុងភូមិ តស៊ូវាចាប់ចង្កា ចាប់ចងមិនបានរត់ព្រាត់ប្រាស់ចូលព្រៃហើយ ។

**សុរិយ៉ា:** គេតាមចាប់?

**សារ៉ាត:** ណឹងហើយ មិនចាប់យ៉ាងម៉េច ប៉ូលីសទាហាន ។

**សុរិយ៉ា:** ទាហាន លន់ ណុល?

**សារ៉ាត:** អើ ទាហាន លន់ ណុល ។

**សុរិយ៉ា:** តាមចាប់ក៏រត់ចូលក្នុងព្រៃទៅ?

**សារ៉ាត:** បាញ់ម្នាក់ចោលនៅកៀនបន្ទាយ ថាពួកអានេះ......

**សុរិយ៉ា:** រត់ចូលព្រៃ ព្រៃខាងណា?

**សារ៉ាត:** ព្រៃខាងអូលាវ អូតាង ។

**សុរិយ៉ា:** អូលាវ អូតាង នៅក្នុងខេត្តណា?

**សារ៉ាត:** ខេត្តរតនគិរី ក៏ត្រូវដែរ ។

**សុរិយ៉ា:** អញ្ចឹងពួកណឹងអត់មាននិយាយអីច្រើន ប៉ុន្តែអ៊ីស្គាល់តាមគេទេ តាមរយៈ**ខាំ ភូន** អីណឹង ក៏ចូលរួមជាមួយគេនៅឆ្នាំណា?

**សារ៉ាត:** ជាមួយភូមិគាត់ចូល ។

**សុរិយ៉ា:** ទាំងអស់តែម្ដង?

**សារ៉ាត:** ទាំងអស់ម៉ាភូមិដីមៀត ។

**សុរិយ៉ា:** ឆ្នាំណាបានចាប់ផ្ដើមរត់ចូលព្រៃ គេតាមបាញ់តាមអីអញ្ចឹង ឆ្នាំណាបានរត់ចូលព្រៃ?

**សារ៉ាត:** ៦៨ ចោលផ្ទះសំបែង គោក្របី ទ្រព្យសម្បត្តិអីទាំងអស់ ។

**សុរិយ៉ា:** អញ្ចឹងចាប់ផ្ដើមភ្លាមរត់ចូលព្រៃភ្លាម?

**សារ៉ាត:** អូអាណឹង តាំងពី៦១, ៦២មក ។

**សុរិយ៉ា:** ចូលតាំងពី៦១, ៦២ មកវិញគេមកផ្ទើនយោបាយ?

**សារ៉ាត:** បាទគេផ្ទើនយោបាយ ។

**សុរិយ៉ា:** មកដើរប្រាប់ដើរអីណឹង?

**សារ៉ាត:** បាទ

**សុរិយ៉ា:** ដើរប្រាប់តាមរយៈនរណាគេ? គេមកប្រាប់ប្រធានភូមិ ឬមកប្រាប់អី ឬហៅទៅប្រជុំ?

**សារ៉ាត:** អត់ទេ កាលណោះតាមពួកតា **ខាំ ភួន** គេធ្វើសម្ងាត់ណា ភូមិ ឃុំ មានទៅដឹងអី បើភូមិឃុំដឹងនោះ គេចាប់បាត់ទៅហើយ ដោយសារគេចាប់ណឹងហើយបានមានចលនារត់ ។

**សុរិយ៉ា:** **ខាំភួន** សនគឺ **ខាំភួន**មិនមែន**ស៊ុម ខាំភួន**ផ្សេងនោះទេ? ចុះដល់ពេលរត់ចូល រត់ចូលឆ្នាំ៦៨ ចាប់ផ្ដើមឆ្នាំ ៦៨ចាប់ផ្ដើមរត់ចូលព្រៃ? ចូលព្រៃខាង?

**សារ៉ាត:** បាទ ចូលព្រៃអូលាវ អូតាង ខេត្តរតនគិរី ។

**សុរិយ៉ា:** ស្រុកណា?

**សារ៉ាត:** ស្រុកបខាំ ។

**សុរិយ៉ា:** រតនគិរីមានស្រុកបខាំដែរ?

**សារ៉ាត:** ម៉ារតនគិរីរត់ទាំងអស់ ។

**សុរិយ៉ា:** ជិៈទៅខាងលាវ ឬជិតទៅខាងវៀតណាម?

**សារ៉ាត:** ជិៈខាងវៀតណាម ប្រជាជនវៀតណាមក៏នៅអញ្ចឹងទៅប្រជាជនកម្ពុជាក៏នៅអញ្ចឹងទៅ ទៅលាវមិនឆាយទេឆ្ងាយណាស់ ។

**សុរិយ៉ា:** គ្នាប្រហែលប៉ុន្មានពាន់នាក់ដែលពេលរត់ទៅណឹង?

**សារ៉ាត:** មិនដឹងប៉ុន្មានដែរខ្ញុំ អត់ដល់មួយពាន់ទេ បើខាងរតនគិរីរាប់ពាន់ សម័យណឹង ។

**សុរិយ៉ា:** ខាងយើងប្រហែល១០០០នាក់?

**សារ៉ាត:** អត់ដល់ទេ ពីភូមិអត់ដល់ទេ ភូមិគំញ៉ើល និងភូមិពាមជីមៀត ។

**សុរិយ៉ា:** ភូមិពាមជីមៀត និងភូមិគំញ៉ើលរត់ទៅជាមួយគ្នា អញ្ចឹងទៅមាននរណាតាមទេ មានប៉ូលីសខាងលន់ ណុល តាមទេ តាមទៅធ្វើបាបទេ?

**សារ៉ាត:** អត់ទេ តែរត់ផុតភូមិហើយអត់តាមទេ ប៉ុន្តែក្រោយមកគេចេញទៅល្បាតបន្តិចទៅបាញ់ស្លាប់ម្នាក់នៅអូតាង ។

**សុរិយ៉ា:** ឈ្មោះអីស្លាប់ណឹង?

**សារ៉ាត:** ណួយៗ ។

**សុរិយ៉ា:** ណួយ អ្នកតស៊ូដែរ?

**សារ៉ាត:** បាទ ប្រជាជនមិនថាគេថាឯងតស៊ូដែរ ប្រជាជនគេអោយធ្វើចំរូងដើម្បីដាក់ផ្លូវដាក់អី ។

**សុរិយ៉ា:** នៅរហូតដល់៧៥តែម្តង ឬមួយមានប៉ះទង្គិចជាមួយទ័ព លន់ ណុល ខាំងក្លាទៅឆ្នាំណា ដែរ?

**សារ៉ាត:** អត់ទេ ដល់ណឹងក៏នៅក្នុងព្រៃ ២ឆ្នាំ ។

**សុរិយ៉ា:** អញ្ចឹង ២ឆ្នាំ ពី ៦៨ ដល់ ៧០?

**សារ៉ាត:** សម័យ លន់ ណុល ធ្វើរដ្ឋប្រហារអញ្ចឹង ។

**សុរិយ៉ា:** មិញ ៦៨ មិនទាន់ លន់ ណុល ទេណា ៦៨ សីហនុ នៅឡើយ?

**សារ៉ាត:** អត់ទេ ចាំខ្ញុំនិយាយណា៧០ លន់ ណុល ធ្វើរដ្ឋប្រហារ រដ្ឋប្រហាររំលំសម្តេចឪ ពេលនោះកង ទ័ពវៀតណាមហូរចូលតែម្តងសហការណ៏កម្ពុជា ។

**សុរិយ៉ា:** ពេល៧០ណឹង អំនៅជាមួយអ្នកតស៊ូ នៅកន្លែងរត់ទៅនៅឡើយ មិនទាន់មកចូលភូមិវិញទេ?

**សារ៉ាត:** ៧០ល្មម រដ្ឋប្រហារព្រឹប ឥសានគេរំដោះបាន ៥ខេត្ត ។

**សុរិយ៉ា:** អ្នកណាគេរំដោះបាន ?

**សារ៉ាត:** កងទ័ពវៀតណាមជាមួយកងទ័ពកម្ពុជា គេសហការណ៏គ្នារំដោះយកបានពួកខ្ញុំចូលមកនៅឃើញ ទេ ។

**សុរិយ៉ា:** ចូលមកនៅបាន?

**សារ៉ាត:** បាទឆ្នាំ១៩៧០ ពីលន់ ណុល រត់មកនៅកោះញែក ខ្ញុំក៏ទៅនៅស្រែសង្គមឆ្នាំ១៩៧៩ អាភូមិ ចាស់នេះអត់បានមកនៅទេ ។

**សុរិយ៉ា:** អញ្ចឹងកាលមុនលន់ ណុល ធ្វើរដ្ឋប្រហារ ឆ្នាំ៦៨ ណឹងអ៊ំរត់ទៅដល់ឆ្នាំ៧០ លន់ ណុល ធ្វើរដ្ឋ ប្រហារ?

**សារ៉ាត:** អានេះចលនាតស៊ូពីលុងខាំ ទៅតំបន់ ទៅរកចាប់ទៅរកចង បន្ទាប់ពី លន់ ណុល ។

**សុរិយ៉ា:** កាលណោះ លន់ ណុល នៅជាមួយ សីហនុ នៅឡើយទេ ?

**សារ៉ាត:** ណឹងហើយ ពីណាធ្វើខ្មែរក្រហមត្រូវចាប់ ។

**សុរិយ៉ា:** ចុះដល់ពេល លន់ ណុល ធ្វើរដ្ឋប្រហារ?

**សារ៉ាត:** ដល់ចាប់រត់ចូលព្រៃណា ដល់ចូលព្រៃ ដល់៧០លន់ ណុល ធ្វើរដ្ឋប្រហារវៀតណាមជាមួយ កម្ពុជា ខ្មែរក្រហមជាមួយវៀតណាមវៃ លន់ ណុល ដណ្តើមបាន៥ខេត្តនៅភូមិ ភាគឥសាន មណ្ឌលគិរី, រតនគិរី ក្រចេះ, ស្ទឹងត្រែង, ព្រះវិហារ ៧០ ដូច្នេះ ពួកខ្ញុំចូលមកបានហើយ ។

**សុរិយ៉ា:** ពេលណុងប្រឆាំងជាមួយ លន់ ណុល វិញ?

**សារ៉ាត:** ណឹងហើយ មកនៅឯកោះញែករហូតចាប់ពី៧០ មកទល់ ៧៧ បានគេចាប់ខ្ញុំមកដាក់ការដ្ឋាន

នេះ វៀតណាមចូលមកម្តងនេះ ប៉ុល ពតជាមួយទៀតណា វ៉ៃគ្នាទៀតទៅដល់អូទីងឡាំង គេប្រកាស ថាឥឡូវរំដោះកម្ពុជា ភ្នំពេញបានហើយណា ។

**សុរិយ៉ា:** ប៉ុល ពត ទាស់ជាមួយវៀតណាមឆ្នាំណា? ក្រែងឆ្នាំ៧០ វៀតណាម ជួយប៉ុល ពត វ៉ៃបាន ៥ខេត្ត នៅឥសាន ដល់ពេលឆ្នាំ៧៧ ទាស់គ្នា ប៉ុល ពត ជាមួយវៀតណាមទាស់គ្នា រឿងអី?

**សាវ៉ាត:** មិនដឹងរឿងអី ឃើញគេចូលមកវ៉ៃគ្នា ។

**សុរិយ៉ា:** ទាស់គ្នាធ្វើម៉េចទៅ អាពតដេញវៀតណាមចេញ?

**សាវ៉ាត:** មិនដឹងរឿងអី ឃើញតែមកបាញ់ ប៉ុល ពតៗ ។

**សុរិយ៉ា:** ឆ្នាំ៧៧?

**សាវ៉ាត:** ហ្នឹងហើយមករកបាញ់ ប៉ុល ពតៗ ។

**សុរិយ៉ា:** ចុះអ៊ំក្មួសូរឈ្មោះ **ធុច** ដែរ? **ធុច** ហ្នឹងជានរណា?

**សាវ៉ាត:** **ធុច** ហ្នឹង ប៉ុន្តែឃើញមុខគ្នាណា ។

**សុរិយ៉ា:** គាត់ធ្វើការអីដែរ **ធុច** ណឹង?

**សាវ៉ាត:** គាត់ធ្វើជាប្រធានភូមិភាគ ។

**សុរិយ៉ា:** ឆ្នាំណា?

**សាវ៉ាត:** ឆ្នាំក្រោយ៧០ប៉ុន្មានមក ប៉ុន្តែ៧០ណឹងខ្ញុំឃើញ ក្រោយ៧០ អត់ឃើញទេ ។

**សុរិយ៉ា:** ប៉ុន្តែដឹងថាឆ្នាំ៧០ ធ្វើប្រធានភូមិភាគ ?

**សាវ៉ាត:** កាលណុងមិនទាន់ធ្វើទេ ក្រោយ៧០មកបានធ្វើប្រធានភូមិភាគ ។

**សុរិយ៉ា:** តែមិនដឹងឆ្នាំណា? ដឹងតែក្រោយ៧០?

**សាវ៉ាត:** បាទ!

**សុរិយ៉ា:** គាត់មកក្រោយ **យ៉ា** ឬ មុន **យ៉ា**?

**សាវ៉ាត:** គាត់មកក្រោយ **យ៉ា** ទេ ។

**សុរិយ៉ា:** អូ **ធុច** មិញ ធ្វើប្រធានភូមិភាគខត្តរទេ?

**សាវ៉ាត:** ខត្តរ ។

**សុរិយ៉ា:** មិនមែនឥសានទេ?

**សាវ៉ាត:** មិនមែនទេ ។

**នាន:** មានឈ្មោះអីផ្សេងទៀតទេ **ធុច** ហ្នឹង?

**សារ៉ាត:** ដំបូងឈ្មោះ**គុណ** កាលបានជួបមុខគ្នា ដល់យូរមករំដោះ៧០ អត់ជួបមុខទេ ឮថាគេហៅ **ធុច** ។

**សុរិយ៉ា:** មនុស្សផ្សេងគ្នាទេហី?

**សារ៉ាត:** អត់ទេតែមួយ តា**ធុច** ជាមួយគ្នា តាឃោន ស្គាល់គ្នាទីងធ្លាប់ធ្វើដំណើរជាមួយគ្នារហូត

**ឆាន:** បើតាមខ្ញុំឮឈ្មោះ **ធុច** ហ្នឹង គេច្រើនហៅគាត់ កុយ ធួន?

**សារ៉ាត:** មិនដឹងដែរ ។

**ឆាន:** អញ្ចឹងអត់ដឹងទេ?

**សារ៉ាត:** បាទ!

**សុរិយ៉ា:** **យ៉ា** ឡើងមកឥសានទៅឆ្នាំណា?

**សារ៉ាត:** ខ្ញុំឃើញនៅឆ្នាំ៦៧ ។

**សុរិយ៉ា:** ៦៧ ក្នុងនាទីជាស្អី?

**សារ៉ាត:** អត់មាននាទីអីទេកាលណឹង ។

**សុរិយ៉ា:** ៦៧ អត់មាននាទីជាស្អីទៀត អត់មានធ្វើអីសោះ?

**សារ៉ាត:** កាលនោះគ្មានការចាត់តាំងអីទេ តែគ្រាន់ក្តោបក្តាប់ភូមិ ឃុំឃោសនាអប់រំ ។

**សុរិយ៉ា:** អត់មានតួនាទីអីសោះ?

**សារ៉ាត:** អត់មានទេ ។

**សុរិយ៉ា:** អត់មានឬ ក៏អឹងអត់ដឹង?

**សារ៉ាត:** អត់ដឹងទេ ពីណាដឹងទេ ។

**សុរិយ៉ា:** គ្រាន់តែដឹងថា ធ្វើធំដែរ ព្រោះឃើញឃោសនាហៅប្រជុំអីដែរ?

**សារ៉ាត:** ណឹងហើយ ហៅប្រជុំគ្នាគេណឹងណា ។

**សុរិយ៉ា:** មានស្គាល់ឈ្មោះអីផ្សេងទៀតទេ ឈ្មោះ យ៉ា ណឹងមានហៅឈ្មោះអីផ្សេងទៀតទេ?

**សារ៉ាត:** **ឃឿន** ។

**សុរិយ៉ា:** ហើយអីទៀត?

**សារ៉ាត:** តែប៉ុណ្ណឹង ។

**សុរិយ៉ា:** អ៊ីដែលឮស្គាល់ម្នាក់ឈ្មោះ នៃ **សារ៉ាន់** អ៊ីធ្លាប់ឮទេ?

**សារ៉ាត:** ជនជាតិអី?

**សុរិយ៉ា:** នៃ **សារ៉ាន់** ហ្នឹង ខ្មែរធម្មតា អ៊ីឮ យ៉ា ហ្នឹងបាត់ខ្លួនពីឆ្នាំណា?

**សារ៉ាត:** ៧៧

**សុរិយ៉ា:** បាត់នៅឯណា?

**សារ៉ាត:** ៧៦ នៅក្រចេះ ។

**សុរិយ៉ា:** បាត់ណឹង ដោយសារអីទៅ ។

**សារ៉ាត:** គេថាក្បត់គេ ។

**សុរិយ៉ា:** ក្បត់គេចាប់ ខាងណាចាប់?

**សារ៉ាត:** ប៉ុល ពត

**សុរិយ៉ា:** មកពីថ្នាក់ស្រុក ថ្នាក់តំបន់ ឬថ្នាក់មជ្ឈិមចាប់?

**សារ៉ាត:** អត់ដឹងតែមកពីគេពីភ្នំពេញចាប់ទៅ ។

**សុរិយ៉ា:** អ៊ំដឹងតាមរយៈអីដែរ? បានដឹងថាគេចាប់គាត់ដោយសារគាត់បាត់ខ្លួនឥឡូវនេះអត់ឃើញ ឬក៏មានគេឃើញមកប្រាប់អ៊ំ ឬក៏ម៉េចដែរ?

**សារ៉ាត:** អូអាណឹងវាពុកវាដឹង ។

**សុរិយ៉ា:** ចេះតែពុកៗ?

**សារ៉ាត:** បាទ

**សុរិយ៉ា:** ប៉ុន្តែអត់ដឹងអ្នកណាខ្លះនិយាយ?

**សារ៉ាត:** ណឹងហើយ ដើរមកប្រាប់យើងទៅ ។

**សុរិយ៉ា:** មិនដឹងនរណាខ្លះទេ ភ្លេចមុខអស់ហើយគ្រាន់តែពុកៗ?

**សារ៉ាត:** ណឹងហើយគ្រាន់តែពុកៗ ប៉ុន្តែគេក៏អូ កាលណឹងគឺថាកាលណាកាំបិទក៏គេដេញទៅហើយគ្មានស្លាត់ទេ មកតែកងតាឃី តាស៊ួចេះតែពុកទាំងអស់ ។

**សុរិយ៉ា:** អ៊ំអត់មានដឹងថា **យ៉ា** បានកាន់នាទីជាអីខ្លះអត់ទេ? គ្រាន់តែនឹកឃើញថា បានមកប្រជុំមកអីអញ្ចឹង?

**សារ៉ាត:** កាលដំបូង ។

**សុរិយ៉ា:** ណឹងហើយ!

**សារ៉ាត:** បាទ

**សុរិយ៉ា:** ចុះពេលក្រោយមកទៀត?

**សារ៉ាត:** ពេលក្រោយណឹង ហើយបានដឹងថា គាត់រំដោះ ៧៥ គាត់ប្រធានមន្ទីរភូមិភាគឥសាន ។

**សុរិយ៉ា:** អត់ដឹងថា គេយក **យ៉ា** ហ្នឹងទៅណាៗអីអត់ដឹងទេ?

**សារ៉ាត:** អត់ដឹងទេ ព្រោះគេចាប់នៅក្រចេះ ប៉ុន្តែប្អូនខ្ញុំវាធ្វើសំបុត្រប្រាប់ខ្ញុំដែរថា ចង់គាត់មកនៅខាង មណ្ឌលគិរី កាលនោះពីណាហ៊ាននិយាយ ខ្ញុំក៏មិនហ៊ានកំរើកមាត់ដែរ ។

**សុរិយ៉ា:** អ៊ំមិញថា **យ៉ា** ជាប្អូនថ្លៃផងមិញ?

**សារ៉ាត:** បាទ គាត់យកប្អូនខ្ញុំ ។

**សុរិយ៉ា:** ប៉ុន្តែអ៊ំអត់ដឹងច្បាស់ថា គាត់ធ្វើអីៗ?

**សារ៉ាត:** ដឹងច្បាស់ថា គាត់ធ្វើប្រធានភូមិភាគឥសាន ។

**សុរិយ៉ា:** ឆ្នាំណា?

**សារ៉ាត:** ឆ្នាំ៧៥ ។

**សុរិយ៉ា:** ធ្វើដល់ឆ្នាំណា?

**សារ៉ាត:** ដល់៧៦ ។

**សុរិយ៉ា:** ធ្វើដល់៧៦, ៧៧ គេចាប់ទៅ?

**សារ៉ាត:** ខ្ទង់៧៦ គេចាប់ទៅ ។

**សុរិយ៉ា:** អ៊ំអត់មានប្រតិកម្មអីពេលគេចាប់ទៅ ប្អូនអ៊ំអត់មានយំស្រែកអីទេ?

**សារ៉ាត:** មិនដឹងដែរ គេនៅក្រចេះឯណោះ គ្រាន់តែឮដំណឹងទេ ប៉ុន្តែខ្ញុំមកពីដេកពេទ្យនៅភ្នំពេញ ៧៥ ខ្ញុំ មកលេងផ្ទះគាត់ណឹងដែរ នៅក្រចេះនោះណា មកឃើញទាំងប្ដី ទាំងប្រពន្ធ ទាំងកូនគាត់ទាំង អស់ ហើយបែកគ្នាតាំងពី៧៥ អត់ដែលជួបមុខទេណា ។

**សុរិយ៉ា:** ផ្ទះគាត់នៅក្រចេះកាលពីជំនាន់ ប៉ុល ពត?

**សារ៉ាត:** អើ ។

**សុរិយ៉ា:** នៅម្តុំណា?

**សារ៉ាត:** ជិតវត្ត ប៉ុន្តែមិនមែនផ្ទះគាត់ផ្ទាល់ទេ កំណើតទេ ។

**សុរិយ៉ា:** នៅជិតវត្តអី?

**សារ៉ាត:** ជិតវត្តជិតប្រសារ ។

**សុរិយ៉ា:** វត្តជិតប្រសារ គេហៅវត្តជិតប្រសារ?

**សារ៉ាត:** បាទផ្សារគេលក់ដូរ ។

**សុរិយ៉ា:** អូ វត្តជិតផ្សារ ?

**សាវ៉ាត:** បាទ!

**សុរិយ៉ា:** ផ្សារក្រចេះណឹងតែម្ដង?

**សាវ៉ាត:** ផ្សារក្រចេះ ។

**សុរិយ៉ា:** ឈ្មោះវត្តអីទៅ?

**សាវ៉ាត:** អត់ដឹងវត្តអីដែរ ។

**សុរិយ៉ា:** ផ្ទះណឹងនៅជល់ផ្លូវទេ បើតាមមើល?

**សាវ៉ាត:** អត់ដឹងតាំងពីនោះមក ខ្ញុំមិនដែលទៅ ។

**សុរិយ៉ា:** ផ្ទះក្បឿង ឬ ក៏ផ្ទះថ្ម?

**សាវ៉ាត:** ផ្ទះថ្ម តាំងពី ៧៥ ខ្ញុំមិនដែលទៅមើលផ្ទះនោះទេ ។

**សុរិយ៉ា:** អ៊ំនិយាយមិញមានឈ្មោះកងពល**តា សាន** ដែរ? កងពលតាសាន កងពលទីប៉ុន្មាន ?

**សាវ៉ាត:** ណឹងហើយដែលថាចាប់ពួកខ្ញុំទាហានកងពលតាសានមិនដឹងកងពលលេខប៉ុន្មានៗអត់ដឹងទេ ។

**សុរិយ៉ា:** **តា សាន** ហ្នឹងឡើងធ្វើកងពលពីអន្លង់ អត់ដឹងទេ?

**សាវ៉ាត:** មិនដឹងពីអន្លង់ទេ ។

**សុរិយ៉ា:** អត់ដឹងលេខប៉ុន្មានទៀត?

**សាវ៉ាត:** អត់ដឹងលេខប៉ុន្មានទៀត ។

**សុរិយ៉ា:** ប៉ុន្តែដឹងថា កងពលនោះនៅប្រចាំការនៅ......

**សាវ៉ាត:** នៅមណ្ឌលគិរី នៅកោះញែកយើងនេះ ។

**សុរិយ៉ា:** ចុះអ៊ំមានធ្លាប់ដឹងពួប្រជាជននៅកោះញែក មណ្ឌលគិរី ក៏ដូចជារតនគិរី មានពួកម្នាកិបាលខ្មែរក្រហមណឹងមានការថ្នាំងថ្នាក់ចិត្តជាមួយកម្មាភិបាលខ្មែរក្រហមអីអញ្ចឹងទៅ នាំប្រជាជនរត់ទៅព្រៃ ឬ ក៏រត់បែកចេញពីពួក ប៉ុល ពត ទៅឡាវ ទៅវៀតណាម អញ្ចឹងអ៊ំមាន ដែលឃើញទេ?

**សាវ៉ាត:** អត់ទេ ។

**សុរិយ៉ា:** នៅជាមួយគ្នារហូតអត់បែកបាក់ទេ?

**សាវ៉ាត:** អត់មានទេ អារឿងចលនាណឹងនោះ ។

**សុរិយ៉ា:** ជំនាន់ ប៉ុល ពត វាស្ងាត់?

**សាវ៉ាត:** ស្ងាត់ ។

**សុរិយ៉ា:** ចុះប្រជាជនផ្ទាល់មានរត់ខ្លួនឯង ឧបមាថា ភ្លាចអាពតអញ្ជើងទៅ ក្នុងអីមានរត់ទេ?

**សារ៉ាត:** មានរត់ខ្លះ លាវម្នាក់ ។

**សុរិយ៉ា:** ដឹងតែម្នាក់ណឹង ក្រៅពីហ្នឹងមានដឹងទៀតទេ?

**សារ៉ាត:** ខ្ញុំដឹងឡានម្នាក់ ប៉ុន្តែរត់ទៅហើយ ។

**សុរិយ៉ា:** សុទ្ធតែប្រជាជនទេឬ?

**សារ៉ាត:** វៀតណាម ដាក់គុកទៀត មកវិញ ។

**សុរិយ៉ា:** សុទ្ធតែប្រជាជន?

**សារ៉ាត:** ប្រជាជន ។

**សុរិយ៉ា:** ចុះខាងកម្មាភិបាលអីអត់មានទេ? ខាងទាហានខាងអីអត់មាននាំប្រជាជនរត់?

**សារ៉ាត:** អត់ទេ ។

**សុរិយ៉ា:** អ៊ីដឹងតែមួយណឹង? ឆ្នាំណាដែរ? គាត់ជនជាតិឡាវ?

**សារ៉ាត:** ជនជាតិឡាវ ។

**សុរិយ៉ា:** គាត់រត់ទៅឆ្នាំណា? ៧៧, ៧៨, ៧៩ ?

**សារ៉ាត:** ប្រហែល ៧៦ ។

**សុរិយ៉ា:** រត់ពីណាទៅ ?

**សារ៉ាត:** រត់ពីស្រែហ៊ុយ ពីភូមិស្រែហ៊ុយ ។

**សុរិយ៉ា:** ក្នុងឃុំអី?

**សារ៉ាត:** ឃុំពីមុនគេហៅ ឃុំអូរ៤ ក្រោមស្រុកកោះញែក ។

**សុរិយ៉ា:** ជនជាតិឡាវម្នាក់ណាងរត់ពីហ្នឹងទៅ?

**សារ៉ាត:** បាទ ។

**សុរិយ៉ា:** រត់ទៅវៀតណាម?

**សារ៉ាត:** បាទ

**សុរិយ៉ា:** មានស្គាល់ឈ្មោះទេ?

**សារ៉ាត:** ឈ្មោះ **ខាំ** ។

**សុរិយ៉ា:** **ខាំ** ទទេ?

**សារ៉ាត:** **ខាំ** ទទេ ប៉ុន្តែអត់ដឹងនាមត្រកូលគាត់ទេ ។

សុរិយ៉ា: ស្រី ឬប្រុស?

សារ៉ាត: ប្រុស ។

សុរិយ៉ា: កាលណឹងប្រហែលអាយុប៉ុន្មានគាត់?

សារ៉ាត: ប្រហែល អាយុ ចូល៦០ហើយ ចាស់ហើយ ។

សុរិយ៉ា: រត់ទៅគេចាប់បាន រត់តែម្នាក់គត់?

សារ៉ាត: រត់តែម្នាក់គត់ ។

សុរិយ៉ា: វៀតណាមចាប់បាន?

សារ៉ាត: គេរកចាប់គាត់ គាត់រត់ ។

សុរិយ៉ា: រត់ទៅវៀតណាម ចាប់បាន?

សារ៉ាត: កាលណឹងដឹងចាប់មិនចាប់ គ្រាន់តែជាដំណឹងយើងមិនឃើញដែរ ។

សុរិយ៉ា: ដំណឹងថាម៉េច?

សារ៉ាត: ថាវៀតណាម ចាប់ដាក់គុកទៀត ។

សុរិយ៉ា: ហើយអ៊ំមានឃើញមកវិញទេ?

សារ៉ាត: មកវិញប៉ុន្តែខ្ញុំឃើញទេ មកវិញដល់ស្រែហ៊ុយ គេអ្នកទៅឃើញ ។

សុរិយ៉ា: ឃើញមកដល់, ស្រែហ៊ុយ វិញ?

សារ៉ាត: បាទមកស្លាប់នៅទីនេះគ្នា ត្រឡប់មកវិញ ។

សុរិយ៉ា: វៀតណាមដាក់គុករួចហើយមកដល់ស្រែហ៊ុយវិញ ។

សារ៉ាត: បាទ

សុរិយ៉ា: មកគេឃើញវិញ ឃើញនៅទីណា?

សារ៉ាត: នៅស្រែហ៊ុយ ។

សុរិយ៉ា: មកទើបតែស្លាប់ឆ្នាំណា?

សារ៉ាត: ដឹងស្លាប់ឆ្នាំប៉ុន្មាន ៨០ ជាង ៨៧ ?

សុរិយ៉ា: គាត់រត់មកវិញតាំងពី៧៩មក?

សារ៉ាត: រត់មកពីវៀតណាមវិញ ខ្ទង់៨៧ ។

សុរិយ៉ា: ស្លាប់៨៧ ណឹងបណ្តោយ?

សារ៉ាត: ស្លាប់ណឹង៨៨...... ៨៧ដែរ មិនយូរប៉ុន្មានដែរទេ ។

**សុរិយ៉ា:** មកដល់ស្លាប់បណ្តោយ?

**សាវ៉ាត:** ហើយម្នាក់ទៀត ឈ្មោះ អា **អួន** ណឹងក៏ចាស់ដែរ រត់ទៅដែរ ។

**សុរិយ៉ា:** ឡាវដែរ?

**សាវ៉ាត:** ជាតិទំពួន ទៅស្លាប់នៅវៀតណាម ។

**សុរិយ៉ា:** ចាស់ដែរហើយ?

**សាវ៉ាត:** ចាស់ដែរហើយ ។

**សុរិយ៉ា:** ប្រុស?

**សាវ៉ាត:** ប្រុស ។

**សុរិយ៉ា:** រត់ទៅស្លាប់នៅវៀតណាម រត់ពីភូមិណាទៅ?

**សាវ៉ាត:** ពីភូមិណឹងដែរ ។

**សុរិយ៉ា:** ភូមិជាមួយគ្នា?

**សាវ៉ាត:** បាទ!

**សុរិយ៉ា:** ឆ្នាំ?

**សាវ៉ាត:** ឆ្នាំទៅមុន ។

**សុរិយ៉ា:** ទៅមុន?

**សាវ៉ាត:** ប្រហាក់ប្រហែលគ្នា ។

**សុរិយ៉ា:** ពូធ្លាប់ឮពាក្យ ហ្វូរ៉ូ មានធ្លាប់ឮសួរទេ?

**សាវ៉ាត:** ឮដែរ ។

**សុរិយ៉ា:** ហ្វូរ៉ូមានន័យថាម៉េច?

**សាវ៉ាត:** ហ្វូរ៉ូ គេជាអ្នកតស៊ូដែរ ។

**សុរិយ៉ា:** អ្នកតស៊ូ អ្នកតស៊ូណឹងជនជាតិអី?

**សាវ៉ាត:** ជនជាតិរដែ ។

**សុរិយ៉ា:** ហើយមានជនជាតិអីទៀតដែរ?

**សាវ៉ាត:** មិនសូវច្បាស់ដែរ ។

**សុរិយ៉ា:** ឮថាពួកហ្នឹងកើតពីជំនាន់ណាមក?

**សារ៉ាត:** ខ្ញុំពួតាំងពីមុនមកដែរ ៦៨ដែរ ខ្ញុំពួម្យ៉ាង ខ្ញុំឃើញអញ្ចេះដែរ ឆ្នាំ៦៣ ខ្ញុំទៅធ្វើចាហានទៅមណ្ឌលគិរី ឃើញគេមកធ្វើជំរំនៅមណ្ឌលគិរីហ្នឹង ពួកហ្នូ៦៣ ។

**សុរិយ៉ា:** ប្រហែលជាប៉ុន្មាននាក់មើលទៅក្នុងជំរំហ្នឹង?

**សារ៉ាត:** ច្រើនដែរមិនតិចទេ រាប់រយ ហើយមើលទៅ ។

**សុរិយ៉ា:** ហើយឃើញតែជនជាតិរដែហ្នឹង?

**សារ៉ាត:** ជនជាតិឡាវដែរ ពីរ បីនាក់ ។

**សុរិយ៉ា:** មណ្ឌលគិរីនៅម្តុំណា? ស្រុកណា ?

**សារ៉ាត:** នៅខេត្ត ។

**សុរិយ៉ា:** នៅក្នុងខេត្តហ្នឹងតែម្តង?

**សារ៉ាត:** តាំងនៅហ្នឹងតែម្តង ។

**សុរិយ៉ា:** អញ្ចឹង៦៣ ជំនាន់ហ្នឹងជំនាន់ សីហនុ មិនអញ្ចឹង ហើយ សីហនុ អត់មានធ្វើអី អត់មានដេញទេ?

**សារ៉ាត:** អត់ទេ អត់មានដេញទេ ។

**សុរិយ៉ា:** អត់មានអ្នកណាចូលរួមទេក្រុមរដែហ្នឹងសុទ្ធតែម្តង?

**សារ៉ាត:** មិនសូវដឹងដែរ មិនច្បាស់ដែរ ពួថាមានឡាវម្នាក់ ។

**សុរិយ៉ា:** ហើយពួកហ្នឹងមានគោលបំណងយ៉ាងម៉េចដែរ? តស៊ូៗប្រឆាំងនរណាគេ?

**សារ៉ាត:** ថាតស៊ូប្រឆាំងជាមួយវៀតណាម ពួកកុម្មុយនិស្ត ។

**សុរិយ៉ា:** ប្រឆាំងហ្នឹង ប្រឆាំងចង់បានអី?

**សារ៉ាត:** ចង់បានប្រទេស ។

**សុរិយ៉ា:** ចង់បានប្រទេសវៀតណាមទាំងមូល?

**សារ៉ាត:** ទេដី ។

**សុរិយ៉ា:** ដីអីគេ?

**សារ៉ាត:** ដីនគរចំប៉ា ។

**សុរិយ៉ា:** ចង់បានដីនគរចំប៉ាវិញ?

**សារ៉ាត:** ប៉ុន្តែយើងអត់បានទៅដឹងពួជាមួយគេទេណា គ្រាន់តែគេនិយាយលិចកើតទៅណា យើងដឹងទៅនាំពួកហ្នឹងតស៊ូដើម្បីទឹកដីនគរចំប៉ា គេហ្នឹងអញ្ចឹង ។

**សុរិយ៉ា:** អញ្ចឹងពូដឹងរឿងហ្នឹងអត់មានដឹងអីផ្សេងទៀតទេ មានទឹកឃើញអីផ្សេងទៀតទេ?

**សារ៉ាត:** គេក៏មកនៅត្រង់ណឹងខ្ញុំឃើញមានវេដែសក្តិ៥ ។

**សុរិយ៉ា:** ចុះថ្មីៗពូមានព្ទសួរអីទៀតទេ?

**សារ៉ាត:** អត់ទេ ។

**សុរិយ៉ា:** ឆ្នាំ៩២, ៩៣ មានព្ទសួរអីទៀតទេ?

**សារ៉ាត:** ឆ្នាំ៩២, ៩៣ សុទ្ធតែនៅតាមហ្នឹងហើយ មុនអ៊ុនគាត់ មិនទាន់ដឹកជញ្ជូន ។

**សុរិយ៉ា:** នៅតាមណា?

**សារ៉ាត:** នៅតាមខែន អូរ ទៅមុខទៀតនោះណា ។

**សុរិយ៉ា:** អូរកែននៅក្នុងស្រុកណា ?

**សារ៉ាត:** អូរកែនវានៅក្នុងដីក្រុបខ័ណ្ឌឃុំណងណងឃីលីកហ្នឹងដែរ នៅជិតព្រំដែនវៀតណាម ខ្មែរ យើង ។

**សុរិយ៉ា:** អូរកែននៅក្នុងឃុំណងណងឃីលីក ស្រុកកោះញែក?

**សារ៉ាត:** ណឹងហើយ ។

**សុរិយ៉ា:** ចុះកាលពី៩២-៩៣ អ៊ុនគាត់យកទៅ?

**សារ៉ាត:** ណឹងហើយ មុនបោះឆ្នោត ជិតបោះឆ្នោត ។

**សុរិយ៉ា:** អ៊ុនគាត់មកចរចាជាមួយអ្នកណាបានយកទៅ?

**សារ៉ាត:** មិនដឹងដែរ ឃើញគេដាក់កប៉ាល់ហោះយកមក ។

**សុរិយ៉ា:** ឃើញឡើងកប៉ាល់ហោះ ឃើញឡើងពីណាទៅ?

**សារ៉ាត:** កន្លែងឡើងហ្នឹងជិតដីអេ ។

**សុរិយ៉ា:** ជិតដីអេ? ដីអេនៅម្តុំណា?

**សារ៉ាត:** ដីអេផ្លូវទៅខេត្ត ហួសកោះញែកបន្តិច ប៉ុន្តែមិនដឹងត្រង់ណា ។

**សុរិយ៉ា:** នៅម្តុំកោះញែកណឹង?

**សារ៉ាត:** មែនទេ នៅម្តុំដីអេ ។

**សុរិយ៉ា:** ដីអេនៅជិតកោះញែក ប្រហែលប៉ុន្មានគីឡូ ពីកោះញែក? ពីសាលាស្រុកកោះញែក?

**សារ៉ាត:** ជាង ៥០គីឡូម៉ែត្រ ។

**សុរិយ៉ា:** ជិតទៅខាងណាវិញ ជិតទៅខាងព្រំដែនវៀតណាម វិញឬក៏...?

**សារ៉ាត:** អត់ទេ នៅជិតទៅខេត្ត ។

**សុរិយ៉ា:** ជិតទៅខេត្ត នៅទីរួមស្រុកមណ្ឌលគិរី?

**សារ៉ាត:** បាទមិនដឹងកន្លែងណា ឃើញតែកប៉ាល់ហោះវាចុះ ។

**សុរិយ៉ា:** ឃើញដឹកទាប្រហែលប៉ុន្មានពាន់ដឹកទៅ?

**សារ៉ាត:** មិនដឹងដែរ (សើច) ។

**សុរិយ៉ា:** អត់មានសល់ទេ ដឹកទៅទាំងអស់?

**សារ៉ាត:** អត់មានសល់ទេ ដឹកទៅទាំងអស់ អ្នកប៉ាល់ហោះវាធំមែន និយាយថាចង់ប៉ុនគោខ្មៅដេក ។

**សុរិយ៉ា:** ពូដឹងថា វាដឹកទៅប៉ុន្មានដើង?

**សារ៉ាត:** មិនដឹងប៉ុន្មានដើង ។

**សុរិយ៉ា:** ពូដឹងថា មូលហេតុអីបានវាដឹកទៅរក? មានអីទាក់ទងគ្នាជាមួយហ្សូរ និងអ៊ុនគាត់?

**សារ៉ាត:** មិនដឹង ។

**សុរិយ៉ា:** អត់ដឹងទេ?

**សារ៉ាត:** បាទ

**សុរិយ៉ា:** ពូមានដឹងនរណាគេដឹកហ្សូរ ឬក៏ធ្លាប់ចូលរួមដូចថា ធ្លាប់ដឹងពុច្រើនទេ? ចាស់ទុំនៅភូមិណឹង? នៅឃុំណងណងឃីលីក របស់ពូ ធ្លាប់ដឹងរឿងច្រើន ធ្លាប់ជួយ ធ្លាប់អី?

**សារ៉ាត:** ពួកខ្មែរក្រហម ។

**សុរិយ៉ា:** ពួកខ្មែរក្រហមធ្លាប់នៅជាមួយពួកហ្សូ?

**សារ៉ាត:** បាទ ។

**សុរិយ៉ា:** អញ្ចឹងពូអរគុណច្រើន !

**សារ៉ាត:** (សើច) កាលណឹងទៅព្រៃទៅអីឃើញវាដើរស្មៀកក្រឡេក្រឡា វាទៅរកបរបាញ់ជួបគ្នានិយាយគ្នា ។

**សុរិយ៉ា:** វាអត់ធ្វើបាបយើង?

**សារ៉ាត:** អត់ទេ

**សុរិយ៉ា:** អរគុណច្រើន!

## សំភាសន៍នេត សាវ៉ាត (ក)
## នៅភូមិពាមជីមៀត ឃុំណងឃីលីក ស្រុកកោះញែក
## ខេត្តមណ្ឌលគីរី, ថ្ងៃ ១៨ ខែធ្នូ ឆ្នាំ ១៩៩៩

**ចារ៉ា:** ឥឡូវ ម៉ោងប៉ុន្មានអ៊ំ ?

**សាវ៉ាត:** ម៉ោង ៤កន្លះ ។

**ចារ៉ា:** ប៉ុន្តែនាឡិការខ្ញុំម៉ោង ៥:១០នាទី !

**សាវ៉ាត:** ម៉ោង ៥:១០នាទី .........

**ចារ៉ា:** អ៊ំឈ្មោះអី?

**សាវ៉ាត:** ឈ្មោះកំណើត **នេត ថា** ។

**ចារ៉ា:** ឈ្មោះឥឡូវ ។

**សាវ៉ាត:** **នេត សាវ៉ាត** ។

**ចារ៉ា:** អ៊ំមានតួនាទីអីដែរ

**សាវ៉ាត:** បច្ចុប្បន្ន នាទីជាមេឃុំណងឃីលីក ស្រុកកោះញែក ខេត្តមណ្ឌលគិរី ។

**ចារ៉ា:** ពីមុនមកអ៊ំមានធ្លាប់ធ្វើអីខ្លះ?

**សាវ៉ាត:** ពីមុនមក ពីសង្គមខ្ញុំក៏បានធ្វើទាហានខ្លះដែរ ធ្វើទាហាន ១ឆ្នាំ ៨ខែ ។

**ចារ៉ា:** ធ្វើទាហានចាប់ផ្តើមពីឆ្នាំណាមក?

**សាវ៉ាត:** ពីឆ្នាំ៦៣ ។

**ចារ៉ា:** ឆ្នាំ៦៣ ជាទាហានអីគេ?

**សាវ៉ាត:** ទាហានរីស្លែវ ។

**ចារ៉ា:** រីស្លែវ ឈ្មោះអញ្ចឹងតែម្តង?

**សាវ៉ាត:** ឈ្មោះអញ្ចឹងតែម្តង ។

**ចារ៉ា:** ក្រោយមក?

**សាវ៉ាត:** ក្រោយមកក៏ធ្វើបដិវត្ត ។

**ចារ៉ា:** អញ្ចឹងធ្វើទាហានរីស្លែវតាំងពីឆ្នាំណាមក?

**សារ៉ាត:** ពីឆ្នាំ ៦៨មក ។

**ចារ៉ា:** ក្រោយមកបានធ្វើបដិវត្ត ធ្វើបដិវត្តចាប់ពីឆ្នាំប៉ុន្មាន?

**សារ៉ាត:** ពីឆ្នាំ១៩៦៨ មក ។

**ចារ៉ា:** ហេតុអីបានអ៊ំចូលធ្វើបដិវត្តន៍? អ៊ំរៀបរាប់ពីដំណើររឿងអ៊ំមក?

**សារ៉ាត:** គេមកក្តោបក្តាប់ ហើយអប់រំដើម្បីតស៊ូ ដើម្បីជាតិមាតុភូមិកម្ពុជារបស់យើង ។

**ចារ៉ា:** ប៉ុន្តែ អ្នកណាដែលចូលមកអប់រំអ៊ំពេលហ្នឹង?

**សារ៉ាត:** ពេលហ្នឹងគឺថា ផ្ទាល់ខ្ញុំនឹងគឺថា... ប៉ុន្តែគេមកចេះតែបន្តបន្ទាប់មកហ្នឹងណា ។

**ចារ៉ា:** បាទ មុនដំបូងបង្អស់?

**សារ៉ាត:** តជាមួយខ្ញុំមានតែ **តាំ ភូន** ។

**ចារ៉ា:** **តាំ ភូន**?

**សារ៉ាត:** ទៅលើទៀត គេផ្សេងដែរណា ។

**ចារ៉ា:** តែអ្នកដែលនាំអ៊ំធ្វើបដិវត្តមុនដំបូងគេបង្អស់ឈ្មោះ **តាំ ភូន**?

**សារ៉ាត:** **តាំ ភូន** ។

**ចារ៉ា:** នៅឆ្នាំណាអ៊ំ?

**សារ៉ាត:** តា **តាំ ភូន** ក៏ក្រោមគេដែរ ។

**ចារ៉ា:** នៅក្រោមគេទៀត?

**សារ៉ាត:** បាទ! នៅក្រោមគេដែរ ឆ្នាំ៦៨ ។

**ចារ៉ា:** ៦៨? ដូចអ៊ំមានប្រសាសន៍កាលនៅមាត់ទន្លេថា ហេតុអីបានអ៊ំជឿគេ ពេលគេនាំអ៊ំធ្វើបដិវត្ត ហ្នឹងណា?

**សារ៉ាត:** រៀបរាប់ទាំងអស់?

**ចារ៉ា:** បាទ!

**សារ៉ាត:** នៅលើ **តាំ ភូន** ហ្នឹងទៅក៏មាន ឈ្មោះគេពីដើមគេហៅ ហម នោះ ប៉ុនឃួរៗមកអ្នក ហ្នឹងគេ ខ្លាចតា **ឡាំង** ទៀត ហើយលើទៅហ្នឹងទៀត ក៏មានធ្វើទៅក៏ឃើញ តាហ្នឹងគេ ហៅ **គុណ**។

**ចារ៉ា:** ឈ្មោះមែនទែនហៅឈ្មោះម៉េចទៅ **គុណ** ហ្នឹង?

**សារ៉ាត:** ផ្លាស់ពី **គុណ** ហ្នឹងមក **ឆុច** ។

**ចារ៉ា:** មក **ឆុច**?

**សារ៉ាត:** បាទ! ហើយមកក៏ឃើញឈ្មោះ **យ៉ាំ** នៃ នៅខាងក្រោយជិត៧៥នេះ គេដូរស់ឈ្មោះទៅ**ឃឿន** ទៅវិញ ។

**ចារ៉ា:** **យ៉ាំ** ហ្នឹងគេដូរស់ឈ្មោះទៅ **ឃឿន**?

**សារ៉ាត:** បាទ! បន្ទាប់មកណឹងក៏ឃើញ **នួន ជា** ។

**ចារ៉ា:** **នួន ជា** យើងឥឡូវហ្នឹង? **នួន ជា** មានឈ្មោះក្រៅទេ?

**សារ៉ាត:** អត់ទេ អត់មានទេ ពុកែ **នួន ជា**ប៉ុណ្ណោះ ហើយក៏ឃើញ **តាអុល**ហើយប្រពន្ធ ប៉ុល ពត ។

**ចារ៉ា:** ប្រពន្ធ ប៉ុល ពត? ឈ្មោះអីដែរប្រពន្ធ ប៉ុល ពត?

**សារ៉ាត:** ប៉ុន្តែកាលនោះអត់ដឹងទេ ប៉ុន្តែតាមគេតាមឯងថា **ខៀវ ប៉ុណ្ណារិ** ។

**ចារ៉ា:** **ខៀវ ប៉ុណ្ណារិ**? ប៉ុន្តែអ៊ីធ្លាប់ជួបមុខផ្ទាល់?

**សារ៉ាត:** ជួបមុខផ្ទាល់ ធ្វើដំណើររួមគ្នាកាត់ព្រៃ ។

**ចារ៉ា:** ធ្វើដំណើររួមគ្នាកាត់ព្រៃពីណាមក?

**សារ៉ាត:** កាត់ព្រៃពីភ្នំទង់ប៉ងមកកោះកាឡែម ។

**ចារ៉ា:** កោះកាឡែម? នៅក្នុងខេត្តណាតំបន់ណឹង?

**សារ៉ាត:** នៅក្នុងឃុំកាលីកនេះហើយ ។

**ចារ៉ា:** អញ្ចឹង! អាភ្នំទង់ប៉ងណឹង នៅក្នុងភូមិណា ឃុំណា?

**សារ៉ាត:** នៅក្នុង... បើនិយាយឥឡូវណា វាទៅទិសខាងឃុំស្រែហ៊ុយ ។

**ចារ៉ា:** ទិសឃុំស្រែហ៊ុយ?

**សារ៉ាត:** បាទ! ទិសខាងកើតឃុំស្រែហ៊ុយ ។

**ចារ៉ា:** នៅក្នុងឃុំណា? តំបន់ភ្នំណឹងវានៅក្នុងឃុំណា?

**សារ៉ាត:** ជិតដេអេ ។

**ចារ៉ា:** ជិតដេអេ? ស្រុកអី?

**សារ៉ាត:** ស្រុកកោះញែក ។

**ចារ៉ា:** ស្រុកកោះញែកយើងណឹង?

**សារ៉ាត:** បាទ! ម្តុំណឹងវាជិតនៅដេអេផង ហើយវាចូលទៅក្នុង ចាពាក់កណ្តាលគ្នាដេអេ និងស្រែហ៊ុយ ព្រំដែនគ្នាណឹង ។

**ចារ៉ា:** ហើយមកកោះកាឡែម?

សារ៉ាត: បាទ!

ចាន់: ហើយកោះកាឡែមណីងនៅឃុំណាងឃីលីក?

សារ៉ាត: បាទ! នៅឃុំណាងឃីលីក ។

ចាន់: ម៉េចទៀតអ៊ឹ?

សារ៉ាត: ពីជីមៀតយើងទៅ តែមួយថ្ងៃដល់ហើយ ។

ចាន់: ពីជីមៀតទៅកោះកាឡែមណីង មួយថ្ងៃដល់?

សារ៉ាត: បាទ!

ចាន់: ហើយម៉េចទៀតអ៊ឹ?

សារ៉ាត: អាណីងក៏បានជាប់អញ្ចឹង ហើយក្រៅពីណីងក៏ឃើញច្រើនដែរ ប៉ុន្តែអត់ចាំឈ្មោះទេ

ចាន់: អ៊ឹខស្សាហ៍ជូនដំណើរគេហ៊ីម៉េច?

សារ៉ាត: បាទ! ខ្ញុំធ្វើនិរសាជូនដំណើរគេ ។

ចាន់: អ៊ឹធ្វើនិរសាសំរាប់ផ្ទាល់អ្នកណាមួយទេ?

សារ៉ាត: មិនថាសំរាប់អ្នកណាទេ អោយតែមានភ្ញៀវ មកដល់កន្លែងខ្ញុំ ខ្ញុំជូនទៅកន្លែងណីងទៅដល់កន្លែងណីងទៅគេតទៅទៀត មិនមែនសំរាប់បុគ្គលណាម្នាក់ទេ ដែលគេជាភ្ញៀវ ។

ចាន់: កន្លែងនិរសារបស់អ៊ឹផ្ទាល់ណីងនៅកន្លែងណា?

សារ៉ាត: ខ្ញុំ ចាប់ពីទងប៉ង មកកាឡែម ។

ចាន់: ចាប់ពីទងប៉ង មកកាឡែម គឺកន្លែងអ៊ឹហ្នឹងហ៎?

សារ៉ាត: បាទ ជាតំណាក់របស់ខ្ញុំ ។

ចាន់: ពេលណីង អ៊ឹមានតួនាទីអីដែរ?

សារ៉ាត: អត់មានតួនាទីអីទេ ។

ចាន់: តែក្នុងនិរសាណីង អ៊ឹមានតួនាទីអីដែរ? ជាប្រធាននិរសា ឬក៏យ៉ាងម៉េច?

សារ៉ាត: ជាប្រធាន គេហៅថា អាដែងគេអោយយុទ្ធជនយើង ជួនកាល២នាក់ ជួនណា៣នាក់ ជួនកាល៥នាក់អញ្ចឹងណា ។

ចាន់: គេអោយយ៉ាងម៉េចអ៊ឹ?

សារ៉ាត: គេអោយយុទ្ធជនដើរតាមយើងណីងណា ជួនណា២នាក់ក៏មាន ជួនណា៥នាក់ក៏មាន ជួនណា៣នាក់ក៏មានអញ្ចឹងណា ។

ចារ៉ា: អញ្ចឹងក្នុងពេលអ៊ំធ្វើនិរសាណឹង អ៊ំធ្លាប់បានជូនដំណើរអ្នកណាខ្លះអ៊ំ?

សារ៉ាត: ជូនដំណើរតា **នួន ជា** ។

ចារ៉ា: **នួន ជា** យើង? ជូនពីណាទៅណា?

សារ៉ាត: ជូនពីទងប៉ង់ មកកាឡេម ។

ចារ៉ា: អ៊ំមានដឹង **នួន ជា** ណឹង មានគោលបំណងធ្វើដំណើរទៅណាបានអ៊ំជូនទៅ?

សារ៉ាត: ប៉ុន្តែអត់ដឹងដែរបំណងណឹង ឃើញតែគេដើរទៅ ឆ្លងទឹកទន្លេហើយ ស្រេចតែគេទៅ ។

សុរិយ៉ា: ទន្លេណា ឆ្លងទឹកទន្លេណាអ៊ំ?

សារ៉ាត: ទន្លេស្រែពក ។

ចារ៉ា: ទន្លេស្រែពកយើងណឹង?

សារ៉ាត: បាទ! កោះកាឡេមណឹងហើយជូន **នួន ជា** ប្រពន្ធតាប៉ុល ពត **តាវ អុល តាយ៉ែម** តាធុច ហើយតា **កង** ។

ចារ៉ា: **តាកង** ណឹងមានឈ្មោះក្រៅទេ?

សារ៉ាត: **កង** ណឹង គ្នាក៏ជាអ្នកទទួលនិរសាដែរ ក្រោយមកគាត់ទៅធ្វើប្រធានខេត្តក្រចេះ ។

ចារ៉ា: នៅក្នុងឆ្នាំណា ដែលទៅធ្វើប្រធាន?

សារ៉ាត: **តាកង**?

ចារ៉ា: បាទ!

សារ៉ាត: នៅក្នុងឆ្នាំ៧២ **យ៉ែម** ក៏ទៅធ្វើប្រធានខេត្តណឹងដែរ ។

ចារ៉ា: ខេត្តក្រចេះដែរ?

សារ៉ាត: ខេត្តក្រចេះដែរ ដក **យ៉ែម** ចេញទីនេះ បានដាក់ កង ។

ចារ៉ា: ដក **យ៉ែម** ចេញពីក្រចេះ បានដាក់ឈ្មោះ កង?

សារ៉ាត: បាទ! ហើយ **យ៉ែម** នោះ បើតាមពត្ដដំណឹងណា គេដកទៅប្រចាំទូតនៅកូរ៉េ ។

ចារ៉ា: **យ៉ែម** ណឹងហ៎?

សារ៉ាត: បាទ!

ចារ៉ា: បើតាមអ៊ំឮដំណឹង ឮតាមអ្នកណាអ៊ំមានចាំឈ្មោះទេ?

សារ៉ាត: (សើច) អាណឹងតាមគេតាមឯងនិយាយណឹងណា ។

ចារ៉ា: ប៉ុន្តែនៅពេលដែលឮណឹងក្នុងឆ្នាំណាអ៊ំ?

**សារ៉ាត:** ក្នុងឆ្នាំ៧៣, ៧៤ណឹងណា ។

**ចារ៉ា:** ៧៣, ៧៤ ដែលឈ្មោះអី?

**សារ៉ាត:** ឈ្មោះ **យ៉ែម** ។

**ចារ៉ា:** ឈ្មោះ **យ៉ែម** ទៅធ្វើទូតនៅកូរ៉េ?

**សារ៉ាត:** បាទ! ធ្វើទូតនៅកូរ៉េ ។

**ចារ៉ា:** តទៀតអី?

**សារ៉ាត:** បាទ! ហើយក៏ ក្រោយពីនោះក៏ដើររដ្ឋប្រហារហើយ ក៏គេវ៉ៃរំដោះបាន៥ខេត្តណឹងណា ។

**ចារ៉ា:** អ្នកណារដ្ឋប្រហារវ៉ៃបាន៥ខេត្ត ?

**សារ៉ាត:** លន់ ណុល ធ្វើរដ្ឋប្រហារអព្យាក្រិត្យ ស្ដេច ក៏ស្ដេចយើងកាន់អព្យាក្រិត្យអញ្ចឹង កាលណឹង លន់ ណុល ធ្វើរដ្ឋប្រហារនិយម ផ្ដួលរំលំទៅក៏រំដោះបាន៥ខេត្ត ភូមិភាគឥសាន យើង ។

**ចារ៉ា:** ខេត្តណាខ្លះទៅ អីអាចរាប់បានទេ?

**សារ៉ាត:** ខេត្តមណ្ឌលគិរី ក្រចេះ រតនគិរី ស្ទឹងត្រែង ព្រះវិហារ ហើយពួកខ្ញុំក៏ចូលមកនៅក្នុងភូមិចាំង អស់ នៅក្នុងអាដែង កោះញែក ភូមិស្រែសង្គម ស្រុកកោះហើយ ហើយម្ដងនេះ បានឃើញ ដល់ ៧២នេះ បានឃើញពួកហ្នឹង ចូលមកធ្វើមិទ្ទិញ ។

**ចារ៉ា:** ធ្វើមិទ្ទិញនៅណាអី?

**សារ៉ាត:** នៅស្រែសង្គម ។

**ចារ៉ា:** ហើយអីបានចូលមិទ្ទិញណឹងដែរ?

**សារ៉ាត:** ចូលតើ ។

**ចារ៉ា:** មិទ្ទិញណឹង និយាយពីស្អីទៅមិទ្ទិញណឹង?

**សារ៉ាត:** និយាយពីរឿងការតស៊ូ ។

**ចារ៉ា:** អីមានចាំខ្លឹមសារខ្លះទេ?

**សារ៉ាត:** មានចាំខ្លះ ។

**ចារ៉ា:** បាទ អីអាចនិយាយបាន?

**សារ៉ាត:** ចាំតិចតួចទៅអញ្ចឹងដែរចាំខ្លះអត់ខ្លះនិយាយពីរឿងការតស៊ូជាមួយអាមេរិកណឹងហើយណា ។

**ចារ៉ា:** មិទ្ទិញធ្វើញឹកញាប់ហ៎អី?

**សារ៉ាត:** អត់ទេធ្វើម្ដង គាត់ក៏ទៅវិញទៅ ។

**ចាន់:** នៅក្នុងឆ្នាំណា?

**សារ៉ាត:** ឆ្នាំ៧២ បំផុសចលនាតស៊ូវៀដប៉ុន អាមេរិក ដែលឈ្លានពានទឹកដីកម្ពុជាយើង ដល់ណឹងក៏... ក្រោយមកណឹង ដែលថាស្គាល់គ្នាណឹងណា តាចាំ ក៏ស្គាល់ដែរ តាឃី សុទ្ធតែខ្មែរ អាមុី វ៉ានៅជាមួយគ្នានៅកោះញែក ទាំងប្រពន្ធគាត់ទៀត ទាំង**គុណ**គាត់ ។

**ចាន់:** ចុះអ៊ំដែលស្គាល់ **ខៀវ សំផន** ទេអ៊ំ?

**សារ៉ាត:** អត់ទេ អត់ស្គាល់ទេ ។

**ចាន់:** អ៊ំអាចនិយាយពីរឿង ដែលអ៊ំនិយាយពីមាត់ទន្លេ ដូចជាការចាប់មនុស្សចាប់អីនោះអ៊ំ?

**សារ៉ាត:** បាទ!

**ចាន់:** គេថាចាប់ទៅ គេមានប៉ុន្មានថ្នាក់អីនោះអ៊ំ?

**សារ៉ាត:** អាណឹងវ៉ា ចាប់មនុស្សវ៉ាចេះតែចាប់បន្តៗគ្នាអញ្ចឹង ដំបូង (សើច) គេចាប់ឯង ឯងចាប់គេទៅ អញ្ចឹងហើយណា បន្តបន្ទាប់គ្នាទៅរហូត វ៉ាមានសភាពអញ្ចឹង ។

**ចាន់:** ហេតុអីបានមានចាប់មនុស្សអញ្ចឹង?

**សារ៉ាត:** គេថា ចោទប្រកាន់ថា ខ្សែទាក់ទងវៀតណាម ដៃជើងវៀតណាម គេចោទអញ្ចឹង ។

**ចាន់:** ដល់គេចោទហើយ គេធ្វើម៉េចទៀត?

**សារ៉ាត:** គេចាប់ណា ឧទាហរណ៍ថា គេចាប់ដូចជាខ្ញុំ មានអ្នកលើខ្ញុំ គេចាប់អ្នកលើខ្ញុំ គេចាប់**ខាំ ភួន**នោះ ឯងគេចាប់ខា ភួនទៅក៏ក្រោមការដឹកនាំរបស់**ខាំ ភួន**គេចាប់មកដូចជា**គុណ**ក្ដួយរបស់ គាត់ដូចជា **វ៉ា** ដូចជាគេពុំបានដឹង **វ៉ា** គាត់ជ្ដាំបួនថ្ងៃមិនដឹង ស្អីមិនដឹង គេចាប់បន្តបន្ទាប់ គ្នាទៅអញ្ចឹង ។

**ចាន់:** តែហេតុអីបានត្រូវចាប់បងប្អូនក្រោមៗមកទៀត បើគេចោទ បើបដិវត្តគេចោទថ្នាក់លើហេតុអីបានគេមកចាប់អាក្រោមធ្វើអី?

**សារ៉ាត:** បញ្ហានេះ គេខ្លាចថាកូនចៅរបស់គេវ៉ាឈឺចាប់ ខ្លាចវ៉ាសងសឹកវិញ ដូច្នេះគេត្រូវចាប់ឲ្យអស់ សម្លាប់ឲ្យអស់ ។

**ចាន់:** នេះជាគោលការណ៍របស់បដិវត្តន៍អីយ៉ាងម៉េច?

**សារ៉ាត:** អាណឹងវ៉ា គោលការណ៍ណឹងវ៉ា បើនិយាយទៅមិនមែនជាគោលការណ៍បដិវត្តទេ គោលការណ៍បុគ្គលណឹងហើយណា ។

**ចាន់:** អាណឹងជាការយល់របស់អ៊ំ?

**សារ៉ាត:** បាទ ជាការយល់របស់ខ្ញុំ ក៏ធ្វើបដិវត្ត ក៏បានរៀនសូត្រខ្លះៗដែរ បញ្ហានយោបាយណា ក្នុងការដឹកនាំនេះ ក៏ទៅតាមតែគេហៅថាកាលៈទេសៈរបស់វាដែរណា ទៅតាមក្រិត្យក្រមរបស់វាដែរណា តាមការភ្ញាក់រលឹករបស់មហាជនអញ្ចឹងដែរ ក៏មិនអាចបន្ទិតបន្ទំ ខ្ញុំយល់ថា បញ្ហានេះវាតាមទស្សនៈបុគ្គលរបស់ថ្នាក់លើម្នាក់ៗ ហើយបើអាចមានការថ្នាំងថ្នាក់គ្នា ក៏អាចមានការហៅថា បក្សពួកសាច់ញាតិខ្ញុំអញ្ចឹងមិនដឹងតាមវិភាគមើលណា សាច់ញាតិបងប្អូនគេ គេជាប្រពន្ធសក្តិបី ប្តីសក្តិបួន គេក៏ទាញសាច់ញាតិរបស់គេ (សើច) គេធ្វើធំណា ប្រហែលអញ្ចឹងតាមខ្ញុំពិនិត្យ បើពីណាអត់សាច់ញាតិច្រើនទៅ ក៏មិនសូវឡើងដូចគេទេ អត់សាច់ញាតិ ។

**ដារ៉ា:** អត់បងប្អូនធ្វើធំ?

**សារ៉ាត:** បាទ អត់បងប្អូនច្រើនណឹងណា ក្នុងជួរ ក្នុងជួរកម្មាភិបាលនោះ អត់បងប្អូនច្រើនណឹងណា ។

**ដារ៉ា:** អត់បានធ្វើធំទេ?

**សារ៉ាត:** អត់បានធ្វើធំច្រើន ហើយគេធ្វើធំដង សាច់ញាតិគេច្រើនទៀតណា បងប្អូនគេច្រើនធ្វើធំតែគ្នាៗដែរ គេទាញគ្នាឡើងណា ។

**សុរិយ៉ា:** មានអីទៀតទេអ៊ំ?

**សារ៉ាត:** ម្យ៉ាងគេ អាដែងគេអ្នកនៅលើណឹងវាទាស់គ្នា គេធ្វើយើងខាងក្រោម យើងនៅក្រោមការដឹកនាំរបស់គេដែរណា ខាងលើយើងវាចាញ់គេហើយ ។

**ដារ៉ា:** គេតាម?

**សារ៉ាត:** ហ្នឹងហើយ ។

**ដារ៉ា:** គេតាមយ៉ាងម៉េច? តាមចាប់ អីតាមសម្លាប់?

**សារ៉ាត:** តាមចាប់ណឹងហើយ ត្រូវសម្លាប់ៗណឹងឯង ។

**ដារ៉ា:** តើប្រភេទណាដែលត្រូវសម្លាប់ ប្រភេទណាដែលត្រូវចាប់ឃុំឃាំង ប្រភេទណាទៀតដែលគេជូនអ៊ំធ្លាប់និយាយប្រាប់ខ្ញុំណឹងណា?

**សារ៉ាត:** បញ្ហានេះ ក៏មុននឹងគេចាប់គេក៏យកឯកសារអោយយើងមករៀនៗឯកសារណឹង ក៏គេចំណែកជាបីប្រភេទ ប្រភេទទី១ណឹង គឺត្រូវកំទេចចោល ប្រភេទទី២ ត្រូវឃុំឃាំង ប្រភេទទី៣ ត្រូវបណ្តេញទៅសហករណ៍ ក្រោយពីរៀនណឹងគឺអនុវត្តន៍បណ្តោយ ចាប់បណ្តោយ ។

**ឆាន:** អញ្ចឹងអ៊ំ គេចាត់ទុកប្រភេទណាជាប្រភេទទី១ មនុស្សដែលចាត់ទុកថាជាប្រភេទទី១?

**សារ៉ាត:** ប្រភេទទី១ណឹង គឺថា អ្នកខ្លះគេធ្វើជាប្រធានស្រុក គណៈស្រុក ឬក៏ប្រធានក្រសួង ក្រសួងសេដ្ឋកិច្ច និងក្រសួងពាណិជ្ជកម្ម ប្រភេទទី១ ត្រូវកំទេចចោលមែន ។

**ចារ៉ា:** ចុះប្រភេទទី២?

**សារ៉ាត:** ប្រភេទទី២ ក៏ជាសមាជិកគេ  សមាជិក បុគ្គលិកបំរើការងារ ប្រភេទជាខ្ញុំចឹងអី មិនធំដុំដូចគេ គេចាត់ទុកជាប្រភេទទី២ ប៉ុន្តែមិនមែនចំពោះខ្ញុំ ក៏មានលាយឡំគ្នាទៀត ដូចកូន ដូចចៅ ដូច ស្រី ដូចប្រុស ប្រពន្ធកូនរបស់ខ្ញុំ បងប្អូនខ្ញុំ ដូចជាអ្នកដទៃដែរ គេចំនែកជាប្រភេទទី២ មាន ចាស់ មានក្មេង ។

**ចារ៉ា:** ដល់ប្រភេទទី៣?

**សារ៉ាត:** ប្រភេទទី៣ណឹងក៏អញ្ចឹងដែរ មានចាស់ មានក្មេង មានស្រី មានប្រុសដែរ ។

**ចារ៉ា:** ប៉ុន្តែជាប់ខ្សែយ៉ាងម៉េចទៅអាប្រភេទទី៣?

**សារ៉ាត:** ប្រភេទទី៣ណឹង វាជាប់ខ្សែដូចជា គេប្អូនថ្លៃខ្ញុំណឹង ថាប្ដីវាក្បត់ សម្លាប់ប្ដីណឹងទៅ ។

**ចារ៉ា:** ប្អូនថ្លៃឈ្មោះអីទៅប្អូនថ្លៃ?

**សារ៉ាត:** ឈ្មី ***ស៊ូ ទី*** ។

**ចារ៉ា:** ***ស៊ូ ទី***?

**សារ៉ាត:** បាទ!

**ចារ៉ា:** ហើយអ៊ំមានធ្លាប់បានរៀនឯកសារណឹងទេ?

**សារ៉ាត:** ឯកសារណា?

**ចារ៉ា:** ឯកសារដែលគេដាក់មុនណឹងចាប់មនុស្សគេអោយរៀនឯកសារណឹងណា?

**សារ៉ាត:** បាទ! បានរៀនដែរណា ។

**ចារ៉ា:** អ៊ំថា នៅ កាលនៅ ហឹ អ៊ំខាងជាអ្នកបង្រៀនគេផង?

**សារ៉ាត:** បាទ ណឹងហើយ គេក៏ប្រគល់ឯកសារមកណឹង ខ្ញុំក៏បង្រៀនអោយគេទៅ ខ្ញុំក៏មិនដឹងដែរ មិន យល់ថា បំណងគេថា ចាប់ខ្លួនឯងដែរ និយាយតាមឯកសារៗណឹងដែរ ។

**ចារ៉ា:** អាឯកសារដែលគេចាប់មនុស្សណឹងហ្នំ?

**សារ៉ាត:** ណឹងហើយ ។

**ចារ៉ា:** ឯកសារណឹងអ៊ំទទួលបានពីណាមកឯកសារណឹង?

**សារ៉ាត:** ឯកសារណឹង ទទួលពីតា **ឡាំង** ។

**ចារ៉ា:** ទទួលផ្ទាល់ដៃហ្នឹង?

**សារ៉ាត:** តា **ឡាំង** ចង់ភ្លេចហើយណា ។ តាភាគ..........

**ចាន់ា:** ហើយនៅលើឯកសារចាប់មនុស្សអ៊ំ មានចុះថ្ងៃខែ មានដាក់ឈ្មោះអ្នកណាជាអ្នកចេញឯកសារ អី មានបោះត្រា មានអីទេអ៊ំ?

**សារ៉ាត:** អត់ទេ ។

**ចាន់ា:** គេដាក់ម៉េចទៅអញ្ចឹង ? ដែលអ៊ំធ្លាប់...

**សារ៉ាត:** ខ្ញុំវាយូរហើយ ខ្ញុំក៏ភ្លេចដែរណឹង (សើច) អារឿងត្រានេះ កាលណឹង សម័យណឹងវាអត់មាន ត្រាទេ កាលនោះ ។

**ចាន់ា:** អត់ប្រើហ្នង?

**សារ៉ាត:** អត់ប្រើត្រាទេ ។

**ឆាន:** សរសេរដៃ អីវ៉ៃអង្គុលីលេខ?

**សារ៉ាត:** គេអូសបណ្តោយ ។

**ចាន់ា:** អូស?

**សារ៉ាត:** បាទ មែនហេ វាមានគេអូសនឹងដែរ ?

**ចាន់ា:** ប៉ុន្តែអត់មានដាក់ចុះឈ្មោះអ្នកណាហេហ្ន៎?

**សារ៉ាត:** អត់មានចុះឈ្មោះ ដូច.... ។

**ចាន់ា:** ដូចលិខិតរដ្ឋបាលឥឡូវហ៎?

**សារ៉ាត:** អត់ទេ អត់មានចុះទេ ។

**ចាន់ា:** មានតែខ្លឹមសារសុទ្ធហ្នង?

**សារ៉ាត:** ហ្នឹងហើយមានតែខ្លឹមសារ ។

**ឆាន:** អញ្ចឹងកាលឆ្នាំអ៊ំ យកឯកសារណឹងមកបង្រៀននៅឆ្នាំណា?

**សារ៉ាត:** នៅឆ្នាំ៧៧ ។

**ចាន់ា:** ឆ្នាំ៧៧?

**សារ៉ាត:** មានអីរៀនសូត្រ ដូចពីរ បីថ្ងៃណឹងគេចាប់បណ្តោយ ។

**ចាន់ា:** ចាប់ទាំងអីទៀត?

**សារ៉ាត:** ចាប់ទាំងខ្ញុំ ទាំងខ្ញុំ ទាំងប្រពន្ធ ទាំងកូន ទាំងបង ទាំងប្អូន ។

**ចាន់ា:** នៅពេលដែលចាប់អ៊ំ អ៊ំធ្លាប់ជាបំរើការឱ្យបដិវត្តដ៏ស្មោះ អ៊ំថា អ៊ំជាមនុស្សស្មោះត្រង់មែនទេ អ៊ំ?

**សារ៉ាត:** បាទ!

**ចារ៉ា:** ហើអីធ្លាប់បំរើបដិវត្តដ៏ស្មោះត្រង់អញ្ចឹង នៅពេលដែលគេចាប់អីអញ្ចឹង អីមានអារម្មណ៍ យ៉ាងម៉េចទៅ?

**សារ៉ាត:** មានអារម្មណ៍ខ្លះដែរ! អារម្មណ៍ខ្លាចគេសម្លាប់ណឹងហើយណា ប៉ុន្តែខ្ញុំនឹកនាថាខ្ញុំគ្មានកំហុសអីទោះបីគេសម្លាប់ក៏សំលាប់ទៅ ។

**ចារ៉ា:** អីគិតអញ្ចឹង?

**សារ៉ាត:** បាទ បើនិយាយមិនហ៊ាន គ្មានសិទ្ធិនិយាយស្អីតវ៉ាអញ្ចឹងទេ ស្រេចតែគេ បើគេអាណិតអាសូរក៏រស់ បើគេគ្មានធម៌គ្មាទេ ក៏ធ្វើម៉េចទេ គិតតែប៉ុណ្ណឹង?

**ចារ៉ា:** តើអីមានស្គាល់ **ផាន ឃោន** ទេ?

**សារ៉ាត:** បាទ ស្គាល់ៗ ។

**ចារ៉ា:** ប៉ុន្តែទំនាក់ទំនង **ផាន ឃោន** ជាមួយថ្នាក់លើអីមានស្គាល់ទេ? មានដឹង **ផាន ឃោន** ទាក់ទងជាមួយអ្នកណាខ្លះទេ?

**សារ៉ាត:** **ផាន ឃោន** ហ្នឹងក៏ពេលណារៀនសូត្រណឹង ក៏ប្រជុំរៀនសូត្រអីជាមួយគ្នាដែរ នៅក្នុងអីសាលាតំបន់ណឹងណា ។

**ចារ៉ា:** តំបន់ប៉ុន្មាន?

**សារ៉ាត:** តំបន់ ១០៥ មណ្ឌលគិរីយើងណឹង រៀនសូត្រប្រជុំជាមួយគ្នាណឹងទៅ ប៉ុន្តែគាត់ណឹងទទួលខាងពាណិជ្ជកម្មៗ ។

**ចារ៉ា:** ហើយអីថា **ផាន ឃោន** ហ្នឹងមានទំនាក់ទំនងជាមួយ ប៉ុល ពត?

**សារ៉ាត:** បាទ!

**ចារ៉ា:** ជិតស្និតទេ?

**សារ៉ាត:** អាណឹង ប៉ុន្តែខ្ញុំក៏មិនបានទៅរួមដំណើរជាមួយដែរ ប៉ុន្តែតាមដំណឹងគេនិយាយណឹងណា ហ៊ីក៏ឱ្ងគាត់ណឹងហើយទៅ មានតែគាត់ណឹងទៅដល់តា ប៉ុល ពត ។

**ចារ៉ា:** នៅជិតស្និតជាមួយប៉ុន្មានឆ្នាំហើយ?

**សារ៉ាត:** តាំងពី៧២, ៧៣មិនដឹង !

**ចារ៉ា:** រហូតដល់ឆ្នាំណា?

**សាវ៉ាត:** រហូតដល់ឆ្នាំ៧៧មិនដឹង ៧៦, ៧៧ណឹង ក៏គេចាប់ៗ៧៧ដែរ ចាប់ពួកខ្ញុំមុន បានចាប់គាត់ក្រោយ ខុសគ្រូវគ្នាមិនដល់១០ថ្ងៃផង ។

**ចាវ៉ា:** ប៉ុន្តែនៅពេលដែលគេចាប់បាន **ផាន ឃោន** ចម្លើយសារភាព ដូចអត់មាននិយាយថា គាត់ធ្លាប់ស្គាល់ ជិតស្និតអីជាមួយ ប៉ុល ពត សោះ អ៊ំយល់យ៉ាងម៉េចដែរ?

**សាវ៉ាត:** មិនដឹងដែរហ្នឹង ។

**ចាវ៉ា:** ប៉ុន្តែអ៊ំបានឮពីគេមកថា **ផាន ឃោន** ណឹងជិតស្និតជាមួយ ប៉ុល ពត?

**សាវ៉ាត:** បាទ

**ចាវ៉ា:** មានអីផ្សេងទៀតទេ?

**សាវ៉ាត:** អត់មាន ។

**ចាវ៉ា:** ចុះត្រឡប់មករឿង **នួន ជា** វិញដែលអ៊ំថាធ្លាប់ឃើញណឹងហា ធ្លាប់ជូនណឹង អ៊ំមានដឹងថា **នួន ជា** កាលអ៊ំជូនណឹងនៅឆ្នាំណា?

**សាវ៉ាត:** ឆ្នាំ ៦៩ ។

**ចាវ៉ា:** ៦៩ ?

**សាវ៉ាត:** បាទ

**ចាវ៉ា:** កាលណឹង **នួន ជា** មានតួនាទីអីដែរ?

**សាវ៉ាត:** មិនដឹងដែរតួនាទីគាត់ទេ អត់ដឹងទេ ។

**ចាវ៉ា:** ប៉ុន្តែអ៊ំធ្លាប់បាននិយាយថា ធ្លាប់បានសែង **ទីវ អុល** នោះយ៉ាងម៉េចដែរអ៊ំ និយាយរឿងណឹងតិចមើល?

**សាវ៉ាត:** កាលណឹងបានសែងគាត់មក ពេលនេះខ្ញុំអត់ឃើញដែរណា ប៉ុនគាត់ធ្វើដំណើរមកខាងខេត្តរតនគិរី អូ! មណ្ឌលគិរី ធ្វើដំណើរមកខាងមណ្ឌលគិរី ខ្ញុំទៅទទួលត្រឹមនេះទេ ត្រឹមជុងអូជីមៀតនេះហើយអូជីមៀតត្រឹមណឹង កាលទទួល**ទីវ អុល** នេះមួយហើយនឹងតា **យ៉ែម**មួយ ពីរនាក់ហើយ ៣នឹងស្រីម្នាក់ ។

**ចាវ៉ា:** ស្រីណឹងអ្នកណាគេអ៊ំ?

**សាវ៉ាត:** ស្រីអត់ដឹងស្គាល់ អត់បានស្គាល់គេទេ អាណឹងឆ្នាំវាជិតចុង៦៨ទៅហើយ វាចូល៦៩ទៅហើយ មិនដឹងកាលទទួលម៉ា តា**យ៉ែម** ណឹង ក៏ឈឺដែរគ្រុនខ្លាំងមែនទែន **ទីវ អុល** មិនទាន់ឈឺទេមិនគ្រុនទេ ខ្ញុំក៏ដងទឹកមកដាំទឹកក្តៅមុជឲ្យគាត់ ហើយម្ហូបអាហារបាយទឹកមក ថ្នាំសន្លូវគេព្យាបាលបន្តិចទៅ គាត់ក៏ជាទៅ តា**យ៉ែម**ណឹងៗ កាលណឹងធ្វើដំណើរផុតពីភ្នំ ចូលមកដើងភ្នំមកហើយ ។

**ចារ៉ា:** ជើងភ្នំអីគេអ៊ំ?

**សារ៉ាត:** ជើងភ្នំខេងម៉ាក ។

**ចារ៉ា:** ខេងម៉ាក ?

**សារ៉ាត:** បាទ ជើងភ្នំខេងម៉ាកមក បន្ទាប់មកដេកយប់ណឹង គាត់ទៅដិះដើរបាន ស្រាប់ក្រោកពីណឹងព្រឹកមក ម្តងណឹងដិះដើរអត់បាន ដិះតែបានតិច បានឆ្ងាយប្រហែល ១គីឡូ, ២ ម្តងនេះដិះដើរមិនបានៗ ហើយក៏ដាក់នាំគ្នាដាក់ធ្មើគ្រែអោយគាត់ដេកៗ ហើយក៏ដាំបាយដាំទឹក មិនថាគាត់មិនថាពួកខ្ញុំទេ ហូបទាំងអស់គ្នាណឹងណា មានថ្នាំពេទ្យ ថ្នាំអីព្យាបាលអោយគាត់ ហើយក៏អោយខ្ញុំ ២ នាក់ណឹងជូន **តាយ៉ែម** ណឹងមកដល់ទន្លេ ដល់កោះកាឡោមណឹង បានជូនមក ដល់ណឹងហើយក៏មានគេនៅប្រចាំនៅទន្លេណឹង ទៅយកពេទ្យមកមិនដឹងយកមកពីណាទេ យកមកពីឯណោះមកណា ។

**ចារ៉ា:** មកពីខាងណា?

**សារ៉ាត:** មកពីខាងនោះមក មកពីខាងជើងនោះមក ឈ្មោះពេទ្យនោះ ឈ្មោះ ដាំ មកៗដិះដើរជាមួយពួកខ្ញុំ ដិះមករហូតដល់កន្លែង **ទីវ អុល** ឈឺ នៅជុងអូស៊ូល ។

**ចារ៉ា:** អូស៊ូល?

**សារ៉ាត:** បាទ! មកជួប **ទីវ អុល** នៅចុងអូស៊ូលណឹង មកហើយមកដិះដើរមិនបានម្តងនេះនាំគ្នាសែងទៀតសែងទាំងអស់គ្នា ហើយទាំងពេទ្យទាំងពួកខ្ញុំសែងៗរហូតដល់ទន្លេណឹងហើយដល់កោះម្ញើលហើយព្រឹកមកឆ្លងទន្លេទៅត្រើយម្ខាង បានជួប**តាយ៉ា** ណឹងឆ្លងត្រើយម្ខាងផុតហើយលែងខ្លាចអីហើយម្តងនេះ ព្រោះខាងណឹងវាគ្មានទាហានគ្មានអីទេ **តាយ៉ា** គេមានពេទ្យ តា**ដាំ** ណឹងចាក់ថ្នាំចាក់អីព្យាបាល សំរាកណឹងប្រហែល ២, ៣យប់ បានគេនាំ **ទីវ អុល** ទៅមុខទៀត ។

**ឆាន:** អញ្ចឹងអ៊ំមានដឹងអាតួនាទី **ទីវ អុល** តួនាទី **តាយ៉ា** ណឹង គាត់ធ្វើអីនៅពេលនោះ?

**សារ៉ាត:** កាលនោះ អត់ដឹងទេ ប៉ុនក្រោយនេះដឹងពួកហ្នឹង ។

**ឆាន:** ហើយអញ្ចឹងអ្នកណាដែលបញ្ជាអោយអ៊ំ ជូនពីភ្នំមករហូតដល់កន្លែងដែលអ៊ំនិយាយអម្បាញ់មិញ អ្នកណាដែលបញ្ជាពីលើអ៊ំ?

**សារ៉ាត:** អ្នកចាត់ចែងណឹង **ឡាំង** ។

**ឆាន:** **ឡាំង**?

**សារ៉ាត:** បាទ

**ចាន់:** អ៊ំអាចរៀបរាប់បានទេ ថាតើតំណាក់ត្រឹមណាអ្នកណាអ្នកនាំ ពេលដើរទៅណាមកណា អ្នកណាអ្នកនាំអ៊ំ? ឧទាហរណ៍ដូច **ឈឹម** អ៊ីចឹងទៅ ?

**សារ៉ាត:** នាំទៅ **នួន ជា** នេះទៅមាន តា**ឌុច** នេះឯង ។

**ចាន់:** ហ៊ាន់ះប៉ុន **នួន ជា** ទាល់តែ តា**ឌុច** បានដូចបាន?

**សារ៉ាត:** បាទ ប៉ុនទទួលខុសត្រូវអមដំណើរណឹង តា**ឌុច** ផ្ទាល់តែម្តង ទទួលខុសត្រូវអមដំណើរ អន្តាល់ **នួន ជា** មកជាមួយ (ប្រពន្ធប៉ុល ពត) ។

**ចាន់:** មក... ហ៊ីឆ្លងកាត់ទន្លេណឹង?

**សារ៉ាត:** បាទ បើ...

**ចាន់:** ហើយចុះដូច ប៉ុល ពត?

**សារ៉ាត:** មិនដឹងដែរអាណឹង អូ! ប៉ុល ពត គេមានតែថា យ៉ា ថា **ឌុច** ណឹងហើយបាទអាណឹង ត្រឡប់ទៅវិញ ដើរតាមឆ្លងទន្លេទៅវិញទៅក្រោមទៅខេត្តកំពង់ធំ ។

**ចាន់:** ឆ្លងទន្លេអីទៅអ៊ំ?

**សារ៉ាត:** ឆ្លងទន្លេស្រែពក ។

**ចាន់:** ត្រង់ម្តុំណាៗ?

**សារ៉ាត:** នេះៗ ម្តុំជួរត្បូង ។

**ចាន់:** ជួរត្បូង?

**សារ៉ាត:** បាទ ជួរត្បូង ។

**ចាន់:** គេហៅជួរទូចអញ្ចឹងអ៊ំហ៎?

**សារ៉ាត:** បាទ ជួរត្បូង ។

**ចាន់:** ឆ្លងទៅណា?

**សារ៉ាត:** ឆ្លងជួរត្បូង ឆ្លងទន្លេ ហើយក៏ឆ្លងផុតហើយ ក៏ដើរតាមផ្លូវឃើលឹក ដែលតាមស្រែខ្ញុំទៅ ឆ្លងកាត់ណឹងទៅ ចាក់ទៅល្វៀក ។

**ចាន់:** ចាក់ទៅណឹងធ្វើអីអ៊ំ?

**សារ៉ាត:** ចាក់ទៅល្វៀកទៅរហូត ទៅដល់ក្រចេះណឹង

**ចាន់:** ល្វៀក?

**សារ៉ាត:** ភូមិល្វៀក ។

**ចាន់:** ភូមិល្មៀក រហូតទៅដល់ក្រចេះ ?

**សារ៉ាត:** ដល់ក្រចេះ ។

**ចាន់:** ហើយដល់ណាទៀតអ៊ី?

**សារ៉ាត:** ក្បែរជួរ អាឆ្លងទន្លេមេគង្គ តាំងពីឆ្នាំ៧១ ។

**ចាន់:** គេដើរ ប៉ុល ពត ធ្វើដំណើរតាមណឹងធ្វើអី? មានបំណងអីដែរអ៊ី?

**សារ៉ាត:** មិនដឹងដែរ ។

**ចាន់:** គ្រាន់អ៊ំឃើញអញ្ចឹងហ្នង?

**សារ៉ាត:** គ្រាន់តែ... អត់ឃើញដែរ គេដឹងថាដំណើរគេទៅណឹងណា ។

**ចាន់:** ដឹងពីដំណើរ?

**សារ៉ាត:** បាទ

**ចាន់:** តែអ៊ំអត់បានឃើញផ្ទាល់ទេ?

**សារ៉ាត:** អត់ឃើញផ្ទាល់ទេ ។

**ចាន់:** ចុះអ៊ំមានដឹងថា រួមដំណើរណឹងមួយអ្នកណាខ្លះ?

**សារ៉ាត:** ប៉ុន្តែដឹងថា ដឹងៗ តា**ធុច** នឹងហើយ **តាយ៉ា** ។

**ចាន់:** **ធុច** ណឹងមនុស្សម៉េចដែរ **ធុច** ណឹង?

**សារ៉ាត:** **ធុច** ណឹងមនុស្សក៏ធំដែរ ធាត់ល្មម, មិនស្គរសប៉ុន្មានទេ ខ្មៅក៏មិនជាខ្មៅប៉ុន្មានដែរ **តាយ៉ា** ណឹងទេស ធាត់ៗជាង **ធុច** ទៀត ។

**ចាន់:** គេ ខានអ៊ំធ្លាប់ទទួល **យួន យ៉ាត** ដែរណាអ៊ំៗធ្លាប់និយាយ?

**សារ៉ាត:** អូ! **យួន យ៉ាត** ។

**ចាន់:** បាទ!

**សារ៉ាត:** **យួន យ៉ាត** នេះឃើញជួបទៅនៅកាឡែម ។

**ចាន់:** នៅកាឡែម?

**សារ៉ាត:** បាទ ទាល់តែ **សេង**មកណឹង ដល់នេះ(សើច) គេឆ្លងទូកទៅៈកន្លែងណឹង ជាកន្លែងតំណាក់ ។

**ចាន់:** កន្លែងតំណាក់?

**សារ៉ាត:** បាទ កន្លែងកោះកាឡែមណឹងតំណាក់, សំរាកឃើញ **យួន យ៉ាត** ។

**ចាន:** ហើយអញ្ចឹងអ៊ំមានដឹងថា **យួន យ៉ាត** ណឹងមានតួនាទីអី?

**សារ៉ាត:** អត់ដឹងដែរ ។

**ធាន:** អត់ដឹង?

**សារ៉ាត:** បាទ ដឹងថាក្មៀវៗណឹង ខ្ញុំមិនដឹងតួនាទីគេអីទេ

**ចាន់:** អ៊ំដឹងពីរចនាសម្ព័ន្ធយោធា រដ្ឋបាលអីរបស់ ប៉ុល ពត ទេអ៊ំ?

**សារ៉ាត:** អត់ដឹង ការងារនេះមិនដឹងទេ ។

**ចាន់:** តែអ៊ំធ្លាប់និយាយនៅមាត់ទន្លេនោះអ៊ំៗនិយាយរឿងអីៗ ***សារុន*** នោះអ៊ំ? ឈ្មោះ ***សារុន*** នោះ?

**សារ៉ាត:** បាទ

**ចាន់:** ថាចេញបញ្ជាចេញអីនោះម៉េចដែរ?

**សារ៉ាត:** អូអានេះ គឺថា ***សារុន*** ណឹងគឺថារបស់ពួក ***ឡាំង*** ពួក ***ខាំភួន*** នោះដែរណឹង គឺមានតែគាត់ណឹង ហើយទទួលប្រធានតំបន់ ។

**ចាន់:** តំបន់?

**សារ៉ាត:** ១០៥ មណ្ឌលគិរី ។

**ចាន់:** អញ្ចឹងគាត់ឈ្មោះ ***សារុន*** ណឹងហ្ន៎ ជាអ្នក អ៊ុំទទួលកិច្ចការផ្ទាល់ពី ប៉ុល ពត អីយ៉ាង ម៉េចបើតាមអ៊ំដឹងណា?

**សារ៉ាត:** បញ្ហានេះ ក៏កាលនោះក៏ឃើញតែគេរកចាប់មនុស្សភិតភ័យនោះឯង ។

**ចាន់:** នរណារកចាប់អ៊ំ ?

**សារ៉ាត:** ពួកកងពលសហការគ្នាជាមួយពួកតំបន់ណឹង ដើរលើកផែនការអ្នកណាត្រូវលេខណឹងវាទៅចាប់ណឹងហើយៗ យកឡានទៅ ចាប់ដាក់ឡានដឹកមកៗ ចូលគុក ។

**ចាន់:** ចូលគុកនៅណាអ៊ំ?

**សារ៉ាត:** គុកនៅភ្នំក្រោល ។

**ចាន់:** អញ្ចឹងអាកន្លែងភ្នំក្រោលជាគុកសំរាប់យ៉ាងម៉េចអ៊ំ? ជាគុកសំរាប់តំបន់នៅ..... ?

**សារ៉ាត:** សំរាប់តំបន់ ។

**ចាន់:** តំបន់ទាំងមូលហ្នឹង?

**សារ៉ាត:** បាទ ដំបូងសាលាបង្រៀនទេៗ របស់តំបន់ ដល់ក្រោយមានសភាពការណ៍អញ្ចឹង ចាប់មនុស្សមកឃុំឃាំងវិញ ។

**ចារ៉ា:** មានការសម្លាប់អីនៅណឹងទេអ៎ី? បើតាមអ៎ីដឹង?

**សារ៉ាត:** ប៉ុន្តែភ្នែកមិនឃើញណា បើតាមលេខរៀងគឺថា មានខ្លះដែរណា មិនសម្លាប់ណឹងទេសម្លាប់តាមផ្លូវទៅក្រចេះ ។

**ចារ៉ា:** សម្លាប់តាមផ្លូវទៅក្រចេះ? ចុះនៅភ្នំក្រោលណឹងអ៎ីមានទេ?

**សារ៉ាត:** នៅភ្នំក្រោលវាអាចមានខ្លះដែរៗណា ។

**ចារ៉ា:** តាមការដឹងអ៎ីហ៎េ?

**សារ៉ាត:** បាទ តាមការវិភាគ តាមល្បៀងគេនិយាយណឹងណា ពុំមានអ្នកនៅចំភ្នំក្រោលទេ វានៅ វាកៀនកោះទៅអញ្ចឹងណា ។

**ឆាន:** អញ្ចឹងភ្នំក្រោលនៅខាងណាកោះញែក?

**សារ៉ាត:** វាគិតទៅម៉ុំវង្ស់កោះញែក ។

**ឆាន:** នៅវង្ស់កោះញែកណឹងហ្មង?

**សារ៉ាត:** បាទ!

**ឆាន:** ហើយគេចាប់ផ្តើមចាប់មនុស្សដាក់ពីឆ្នាំណា?

**សារ៉ាត:** ឆ្នាំ៧៧ ។

**ឆាន:** ៧៧ បានចាប់មនុស្សយកទៅដាក់នៅកន្លែងណឹង?

**សារ៉ាត:** ហ្នឹងហើយ ពីមុនចុង៧៦ ដើម៧៧ ខ្ទង់ចន្លោះនឹងហើយ ។

**ចារ៉ា:** តែអ៊ុំ ឈ្មោះ **សារុន** ណឹងពេលឡើងជំនួស **ឡាំង** ជំនួស **ខាំ ភួន** អីណឹង អ្នកណាជាអ្នកតែងតាំងអ៎ីដឹងទេ?

**សារ៉ាត:** អត់ដឹងដែរ ។

**ចារ៉ា:** តែ...

**សារ៉ាត:** អាណឹងគេតែងតាំងយ៉ាងម៉េច បើខ្ញុំក៏អត់ដឹងដែរ ។

**ចារ៉ា:** គេថា **សារុន**ៗ ហើយយើង ប៉ុល ពត អ៊ឹមានទំនាក់ទំនងគ្នាអីដែរ?

**សារ៉ាត:** មានហើយ មិនមែនគាត់ទេ ។

**ចារ៉ា:** មានយ៉ាងម៉េចទៅអ៎ី?

**សារ៉ាត:** ទំនាក់ទំនងការងារ ស្អីៗទាំងអស់ណឹងណាមិនមិនម៉េច មិនមែនគាត់ទេ គេធំប៉ុណ្ណឹង ។

**ចារ៉ា:** **សារុន** ណឹងមានឈ្មោះក្រៅទេ?

**សារ៉ាត:** *អត់ទេក្រៅណឹង ប៉ុន្តែឈ្មោះកំណើតមាន ។*

**ចារ៉ា:** *ឈ្មោះម៉េចទៅ?*

**សារ៉ាត:** *ឈ្មោះកំណើតណឹង* ***ថៃ*** *។*

**ចារ៉ា:** *ថៃ?*

**សារ៉ាត:** *ទូ ថៃ ។*

**ចារ៉ា:** *ទូ ថៃ?*

**សារ៉ាត:** *គឺឈ្មោះគេធ្វើបដិវត្តណឹង គេថា* ***សារុន*** *។*

**ចារ៉ា:** *សារុន?*

**សារ៉ាត:** *បាទ* ***សារុន*** *។*

**ចារ៉ា:** *តែឥឡូវនៅរស់ទេ មើលទៅ?*

**សារ៉ាត:** *បើតាមដំណឹង គេនិយាយថានៅរស់ ។*

**ចារ៉ា:** *នៅណាអ៊ំ?*

**សារ៉ាត:** *នៅអន្លង់វែង ។*

**ចារ៉ា:** *អន្លង់វែង?*

**សារ៉ាត:** *ប៉ុនផ្អែកគេអត់ឃើញមក ។*

**ចារ៉ា:** *បើតាមអ៊ំមានអាចជឿបានទេដំណឹងនេះ? ដែលថានៅរស់ណឹងណា?*

**សារ៉ាត:** *តាមគេនិយាយនោះក៏គួរជឿដែរណា ។*

**ចារ៉ា:** *អញ្ចឹង អ្នកណាអ្នកនិយាយអ៊ំ?*

**សារ៉ាត:** *មានបងប្អូនគេផ្ដាច់ខ្លួនចូលមក ។*

**ចារ៉ា:** *អញ្ចឹង តើអ៊ំមានស្គាល់ឈ្មោះអ្នកណាមួយអោយបានច្បាស់ទេ?*

**សារ៉ាត:** *ប្អូនថ្លៃខ្ញុំណឹង គាត់មកវិញ ។*

**ចារ៉ា:** *ប្អូនថ្លៃ?*

**សារ៉ាត:** *បាទ*

**ចារ៉ា:** *ឈ្មោះអី ប្អូនថ្លៃណឹង?*

**សារ៉ាត:** *ដែន*

**ចារ៉ា:** *ឈ្មោះ ដែន?*

**សារ៉ាត:** បាទ

**ចារ៉ា:** ប្អូនថ្លៃនៅឯណាកាលថ្ងៃ?

**សារ៉ាត:** អន្លក់ណឹងគាត់ទៅ ស្រែខ្ញុំ ។

**ចារ៉ា:** នៅស្រែ មួយណាប្អូនថ្លៃណឹង?

**សារ៉ាត:** ហ្អេស

**ចារ៉ា:** អូ!

**សារ៉ាត:** អាទេះៗ ទើបដល់ណឹង ។

**ចារ៉ា:** អាទេះទើបដល់?

**សារ៉ាត:** ពួកក្អួយចេញមកណឹង អាទេះដល់ហើយបានចេញមកបណ្តោយ គាត់ចូលស្គម ។

**ចារ៉ា:** ប្អូនថ្លៃអ៊ឹណឹង?

**សារ៉ាត:** បាទ

**ចារ៉ា:** ឈ្មោះអីៗឈ្មោះពេញ ?

**សារ៉ាត:** **ផែន** ។

**ចារ៉ា:** ឈ្មោះ **ផែន** អី **ផែន**?

**សារ៉ាត:** **ជួយ ផែន** ។

**ចារ៉ា:** **ជួយ ផែន**?

**សារ៉ាត:** បាទ

**ចារ៉ា:** ហើយនៅឯណាកាលថ្ងៃ?

**សារ៉ាត:** នេះផ្ទះ នៅហ្នឹងដែរ នៅផ្ទះធំ ។

**ចារ៉ា:** គាត់ណឹងអ្នកនិយាយថា **សារុន** ហៅ **ទូ** អីមិញ?

**សារ៉ាត:** **ទូ សារុន** ។

**ចារ៉ា:** **ទូ បៃ**?

**សារ៉ាត:** អូ **ទូ បៃ** ។

**ចារ៉ា:** **ទូ បៃ** នៅអន្លង់វែង អ៊ឹមានទឹកឃើញរឿងអីផ្សេងទៀតទេអ៊ឹ អ៊ឹចង់និយាយ ដូចនិយាយគ្នាលេងអញ្ចឹងទៅណា?

**សារ៉ាត:** បាទ!

**ចាន់:** ពីប្រវត្តិអ្នកណាមួយ ដូច ប៉ុល ពត ឬក៏ **នួន ជា ឬ ខៀវ សំផន** អី? តាមអ៊ំប្រាប់ខ្ញុំ អ៊ំជាចាស់ទុំជាងគេដែលរស់នៅក្នុងភៀកផ្ទាល់ណឹងកិច្ចការបដិវត្តណឹងណា អ៊ំមានរឿង អីខ្លះ?

**សារ៉ាត:** វាអស់ប៉ុណ្ណឹងដែរ (សើច) មិនដឹងស្អីទេ ។

**ចាន់:** ដូចជារឿងអ៊ំធ្លាប់ជួបអ្នកណាៗមួយ នៅណាអីចឹងអ៊ំ?

**សារ៉ាត:** បាទ អាណឹងខ្ញុំនិយាយអស់ហើយ និយាយតែខ្មែរយើងណឹងៗ

**នាង:** អស់ត្រឹមណឹងហ្នឹង?

**សារ៉ាត:** បាទ

**ចាន់:** មាននឹក...?

**សារ៉ាត:** ថាវៀតណាមមិញ ខ្ញុំនិយាយមិញណឹងណា ខ្ញុំជួបអតីតតា គង់ តាអីទៅណា ។

**ចាន់:** កាលណឹងជួបពីជំនាន់ណាអ៊ំ?

**សារ៉ាត:** ៧០ ។

**ចាន់:** ឆ្នាំ៧០?

**សារ៉ាត:** បាទ!

**ចាន់:** មានរឿងអីបានត្រូវជួបគ្នាជាមួយវៀតណាម?

**សារ៉ាត:** រឿងអីវៀតណាម និងខ្មែរថា ធ្វើបដិវត្តជាមួយគ្នាអញ្ចឹងណាវ៉ៃអាមេរិក ហើយស្តេចធ្វើប្រធានរណសិរ្សរួបរួមជាតិកម្ពុជា ។

**ចាន់:** ហើយអ៊ំថា ឆ្នាំណាដែលស្តេចធ្លាប់មកស៊ឹងត្រែងណឹងណា?

**សារ៉ាត:** អាណឹងខ្ញុំពួគេនិយាយទេ ឆ្នាំ៧៣ ។

**ចាន់:** ទៅតាមណាអ៊ំ?

**សារ៉ាត:** កាលណឹងនិយាយថា ចេញមកពីវៀតណាមក មកឆ្លងនៅស៊ឹងត្រែង ឆ្លងមេគង្គយើងណឹងណា ឆ្លងកាត់ភ្នំអីណឹង ពួតែគេនិយាយទេណា ប៉ុន្តែភ្នែកអត់ឃើញទេ ។

**ចាន់:** ចុះអ៊ំមានបានដឹងពីការបះបោរៗប្រឆាំងជាមួយពួកខ្មែរក្រហមវិញរបស់បងប្អូនជនជាតិទេអ៊ំ?

**សារ៉ាត:** បងប្អូនជនជាតិប្រឆាំងជាមួយខ្មែរក្រហម ?

**ចាន់:** ចុះ ប៉ុល ពត ផ្ទាល់ដែលរើសមនុស្សនៅភៀកខ្ជួន រើសមនុស្សយ៉ាងម៉េចអ៊ំ?

**សារ៉ាត:** អាណឹងច្រើនតែរើសជនជាតិ ។

**ចាន់:** ហេតុអីបានគេរើសជនជាតិ?

**សារ៉ាត:** អត់ដឹងទេ គេថាគេទុកចិត្តជនជាតិ ។

**ចារ៉ា:** ច្រើនជនជាតិអីទៅ?

**សារ៉ាត:** ជនជាតិចារ៉ាយ ជនជាតិទំពួនអីទៅ ជនជាតិខាងខេត្តរតនគិរី កាលណឹង ។

**ចារ៉ា:** មណ្ឌលគិរីអត់សូវទេហ្ន៎?

**សារ៉ាត:** រតនគិរីច្រើន ។

**ចារ៉ា:** គេទុកចិត្តខាងជនជាតិនៅរតនគិរី ?

**សារ៉ាត:** បាទ!

**ឆាន:** ចុះអ៊ំមានដឹងថា អ្នកណាជាអ្នកនាំពួកជនជាតិបះបោរ ហើយរត់ចេញទៅវៀតណាមអ៊ំមានបានដឹងទេ?

**សារ៉ាត:** អូ!

**ឆាន:** អ្នកណាជាអ្នកនាំរត់?

**សារ៉ាត:** អាណឹងខ្ញុំដឹងខ្លះដែរ ប៉ុន្តែតាមគេទេ ដូចដេកពេទ្យអំពេញ តាម **តាយ៉ា** ណឹងហើយតា **ប៊ុនមី**ៗ នោះ កាលណឹងគាត់ធ្វើប្រធានកងសេនាធំ សម័យអាដែងវ៉ៃចលនាទី២ កំពង់ធំ តាំងក្រសាំង តាំងគោក កាលណឹងតា **ប៊ុនមី** ណឹងទទួលប្រធានកងសេនាធំ ហើយដល់ក្រោយ មកក៏ដកតា **ប៊ុនមី** ទៅធ្វើប្រធានស្រុកវើនសៃ តា **យ៉ា** គាត់និយាយ ហើយគាត់ធ្វើៗវើនសៃមកដល់នេះ គាត់នាំប្រជាជនរត់ចូលវៀតណាម (សើច) មានតា **យ៉ា** ។

**ឆាន:** នាំអានទៅច្រើនបន្តិចហេអ៊ី?

**សារ៉ាត:** អេតា **ឡូវ** ក៏ប្រធានតំបន់ដែរ រតនគិរី ដាំច្រើនដាំគិចរបស់គេ វាអត់ឃើញ ។

**ចារ៉ា:** **យ៉ា** ណឹងត្រូវម៉េចមួយអ៊ំ?

**សារ៉ាត:** បើនិយាយទៅ វាប្អូនថ្លៃដែរ វាចាស់ដែរណា គាត់យកប្អូនខ្ញុំ ។

**ចារ៉ា:** ប្អូនអ៊ំឈ្មោះអីទៅ?

**សារ៉ាត:** ប្អូនខ្ញុំកំណើតណឹងឈ្មោះ **ធូ ម៉ា** ។

**ចារ៉ា:** **ធូ ម៉ា**?

**សារ៉ាត:** បាទ ហើយឈ្មោះថ្មីគេណឹង គេដាក់ **វឿន** ។

**ចារ៉ា:** **វឿន**?

**សារ៉ាត:** បាទ!

**ចាន់:** អត់មានគ្រួកូលទេ **វឿន** មួយមាត់អញ្ចឹងហេ?

**សារ៉ាត:** គេដាក់ តែ **ឆូ ម៉ា ធេត វឿន** ដដែលណឹងហើយ ។

**ចាន់:** អញ្ចឹងហេ?

**សារ៉ាត:** បាទ

**ចាន់:** អីមានធ្លាប់បាន នៅក្នុងសម័យបដិវត្តអីមានធ្លាប់ជួបគ្នាទេ?

**សារ៉ាត:** ជួបដែរ ។

**ចាន់:** ជួបញឹកញាប់ហេ?

**សារ៉ាត:** អត់ទេជួបនៅអំពេញម្តង គាត់នៅទួលគោក ។

**ចាន់:** នៅទួលគោក?

**សារ៉ាត:** ហើយបកមក ខ្ញុំបកមកពីអំពេញមកជួបនៅក្រចេះ គាត់នៅផ្ទះ ។

**ចាន់:** កាលណឹងនៅក្នុងឆ្នាំណាទៅជួបខ្ញុំ?

**សារ៉ាត:** អ៊ី ដើម៧៦ ខែ១ ។

**ចាន់:** បាទ ពេលជួបគ្នាមានជួបនឹង យ៉ាទេ?

**សារ៉ាត:** បាទ ជួប ទាំងប្តី ទាំងប្រពន្ធទាំងអស់ ទាំងកូនគាត់ទាំងអស់ ។

**ចាន់:** កូនប៉ុន្មាននាក់?

**សារ៉ាត:** កូន២នាក់ ប្រុសទាំងពីរ អីមានស្គាល់ឈ្មោះដែរ?

**ចាន់:** កូនណា?

**សារ៉ាត:** កូន**យ៉ា** ណឹងណា? អាណឹងឈ្មោះវា **រ៉ំ** ស្រី ប៉ុន្តែបុរសបន្តិច ប៉ុនអាប្រុស ខ្ញុំអត់ស្គាល់ដែរ ។

**ចាន់:** អញ្ចឹងមានន័យថា យ៉ា ណឹងមានប្រពន្ធម្តងហើយ? ប្រពន្ធមុនឈ្មោះអីទៅ?

**សារ៉ាត:** មិនដឹងដែរណា មិនដឹងដែរណា ស្លាប់មិនដឹង អីមិនដឹង ។

**ចាន់:** ចុះមិចអីដឹងថាកូនប្រពន្ធ មុនឈ្មោះ **រ៉ំ**?

**សារ៉ាត:** ក៏ខ្ញុំទៅដេកពេទ្យភ្នំពេញណឹង ហើយប្អូនខ្ញុំក៏វាប្រាប់ដែរ ហើយវាមកជូនមានចំណុកចំណីដែលវាមកជូនខ្ញុំនៅមន្ទីរភ្នំពេញ ។

**ចាន់:** មន្ទីរពេទ្យពេញនៅកន្លែងណាទៅអី?

**សារ៉ាត:** មន្ទីរពេទ្យរុស្សី ហើយអាកូនជាមួយប្អូនខ្ញុំនឹងវាបុរសទាំងពីរ តែពីរនាក់នោះទេ ។

**ចាន់:** ពេលជួប យ៉ា ម្តង១ យ៉ា ដែលមាននិយាយរឿងអីរឿងបដិវត្តប្រាប់អីទេ ?

**សារ៉ាត:** អត់ទេ គាត់អត់និយាយអីទៅ ក៏ខ្ញុំអត់បានយកមកកត់មុនដែរ លឺថា សំបុត្រស្នាមដែលផ្ញើមកដល់ក្នុងនេះ គាត់ជំរុញ បញ្ហាការងារ ទិតទំអនុវត្តន៏ពេលណាមានសំបុត្រ ស្នាមម្តងមកវៀងមកសួរសុខទុក្ខ ដល់ពេលយើងទៅជួបអញ្ចឹងថាយើងវ៉ាងទៅលេង ទៅធម្មតា គ្មានការនិយាយអីដែរ ។ ខ្ញុំក៏នៅកន្លែងផ្សេងដែរណានៅក្នុងតំបន់ ក្នុងភូមិភាគ ណីងណា ។

**ចារ៉ា:** ប៉ុន្តែ **យ៉ា** ហ្នឹងមានចម្លើយសារភាពនៅទួលស្លែង អញ្ចឹងបានន័យថាពួកខ្មែរក្រហមបានចាប់ ប៉ុន្តែហេតុអីបានជំនាន់ណឹងអត់មានបានចាប់អ៊ំអញ្ចឹង?

**សារ៉ាត:** មិនដឹងដែរ ខ្ញុំនៅ ខ្ញុំមិនមែននៅជាប់គ្នា អូមិនមែននៅជាមួយគ្នា នៅដោយឡែកគ្នា គាត់ក៏នៅក្រចេះ នៅភ្នំពេញ ខ្ញុំនៅរតនគិរីយើង ការងារពុំដែលទៅរួមគ្នាទេ ។

**នាន:** អញ្ចឹងអ៊ំមានអីទៀតទេរឿងហ្នឹង ប្រពន្ធ **យ៉ា**?

**សារ៉ាត:** អត់មានផ្ញើអីទៀតទេ ។

**នាន:** ចប់ត្រឹមណឹង?

**សារ៉ាត:** បាទ

**ចារ៉ា:** ចុះកាល...

**សារ៉ាត:** សុទ្ធតែកូនចៅរបស់គាត់នៅ ប៉ុនកាលចាប់គាត់ណឹង ប្រពន្ធនៅទេវ៉ាផ្ញើសំបុត្រផ្ញើមកខ្ញុំដែរ ។

**ចារ៉ា:** ប្រពន្ធ **យ៉ា** ណឹងហ្ន៎?

**សារ៉ាត:** បាទ ថាខ្ញុំចង់ទៅរតន មណ្ឌលគិរីអញ្ចឹងណា ប៉ុន្តែខ្ញុំក៏មិនហ៊ាននិយាយដែរ ខ្លាចគេដែរ ដឹងស្រាប់ហើយសម័យនោះ ទោះបីបងប្អូនក៏ដោយ ។ យើងមិនហ៊ាននិយាយអោយ ប៉ះពាល់ បានទេ ប៉ះអ្នកណាកាំភ្លើងអ្នកនោះទៅ។ ដល់ក្រោយមកនេះ ឮថាគេចាប់ក្នាបណ្តើរ ហើយគេវ៉ៃចោលទៅ ។

**ចារ៉ា:** ចាប់អ្នកណាគេអ៊ំ?

**សារ៉ាត:** ចាប់ប្អូនខ្ញុំ ប្រពន្ធ **យ៉ា** ។

**ចារ៉ា:** អញ្ចឹង ចាប់នៅឯណា?

**សារ៉ាត:** មិនដឹងនៅកន្លែងណា ខ្ញុំអត់បានស្គាល់គេផងដែរ ។

**ចារ៉ា:** ចុះកូន?

**សារ៉ាត:** កូនក៏អត់ដឹងដែរ ។

ចាន់: អញ្ចឹងហេតុអីបានពួកប៉ុល ពត ជំនាន់ប៉ុល ពត មានការសម្លាប់មនុស្ស? បើតាមយោបល់អ៊ំផ្ទាល់?

សាវ៉ាត: ខ្ញុំមិនដឹងដែរ សំខាន់គឺថា មានការចោទលើវៀត ណាមថាខ្សែវៀតណាម បញ្ហាណឹងហើយ ។

ចាន់: ហេតុអីបានចោទថាវៀតណាម មិនចោទថៃខ្លះទៅ?

សាវ៉ាត: មិនដឹងដែរ ថាវៀតណាម កា.ហ្វេ.បេ ។

ចាន់: តែការពិតអញ្ចឹងដែរអត់?

សាវ៉ាត: វា (សើច) ការពិតអញ្ចឹងហើយ ប្រាប់ថាដៃជើងវៀតណាម ។

ចាន់: ខ្ញុំចង់សួរថាការពិតដែលគេចោទថាជាដៃជើងវៀតណាម ជាកា.ហ្វេ.បេណឹង មនុស្សដែលគេចោទណឹងអញ្ចឹងមែនហ៎?

សាវ៉ាត: មិនដឹងដែរ ខ្ញុំក៏មិនសូវដឹងដែរ គេពួសម្លាប់ៗណឹងណា ដូចជាខ្ញុំផ្ទាល់នេះអត់ទេ ប៉ុន្តែកាលមុនក៏ខ្ញុំបានរៀបរាប់មកហើយណា បានសហការជាមួយវៀតណាមបង្កើត.... ក្រោយមកគេក៏ដាច់ក្រោយពេលដាច់ណឹងទេ អាដែនរំដោះទូទាំងប្រទេសបានហើយគេក៏ដាច់ បានថារឿងព្រំដែនកាលពីពេលនោះមកទេ អាណឹងបានតឹងតែងមែនទែន មានការចោទប្រកាន់ថា ដៃជើងវៀតណាម ... វៀតណាម ។

ចាន់: តែចោទ អ៊ី សមាជិករបស់ពួក ប៉ុល ពត ណឹងហ៎ ហីចោទប្រជាជនទូទៅដែរ?

សាវ៉ាត: វាមានដែរ ក្នុងសមាជិកក៏មានដែរ អ្នកធ្វើការផារណឹងណា វាត្រូវប្រជាជនក៏មានដែរ ......

ចាន់: អ៊ំអាចនិយាយទៀតបានទេ ទៅមុខទៀត?

សាវ៉ាត: វាអស់ត្រឹមណឹងហើយ ។

ចាន់: ក្រែងលអ៊ំនឹកឃើញរឿងអីទៅអ៊ំចង់និយាយទៀត?

សាវ៉ាត: បើនិយាយទៅវាដដែលៗ (សើច) ។

នាន: តែបើអ៊ំអាចរាប់រៀបពីរឿងទិដ្ឋភាពនៅភ្នំក្រោលបានទេ អាកន្លែងអាគារមួយជាន់នោះខាងក្រោមគេធ្វើអី ខាងលើគេធ្វើអី?

សាវ៉ាត: គេសង់អាគារណឹងហេ ។

នាន: បាទ!

សាវ៉ាត: ប្រ៉កបន្ទុំសី ។

នាន: ហើយគេសង់ពីឆ្នាំណាមក?

**សារ៉ាត:** សង់ មិនសូវចំណាំដែរ ប៉ុន្តែនិយាយស្មានៗតើ វាខ្ទង់៧៩ណឹងឯង ។

**ឆាន:** គេសង់ដើម្បីធ្វើអីដែរ?

**សារ៉ាត:** គេសង់ ដំបូងណឹងសង់ប្រុងធ្វើសាលា សម្រាប់បង្រៀនកម្មាភិបាលណឹង ។

**ឆាន:** ហើយមានប៉ុន្មានបន្ទប់ដែរនៅអាគារណឹង?

**សារ៉ាត:** អាគារនៅលើណឹង ថ្នាក់លើណឹង ជាន់លើណឹង វា១០បន្ទប់ដែរ ។

**ឆាន:** ហើយជាន់ក្រោម?

**សារ៉ាត:** មួយចំហៀងខាង មួយចំហៀង ៥បន្ទប់ៗ គេទុកប្រឡោះកណ្ដាលអញ្ចឹង ហើយខាងក្រោមណឹងគេដាក់ អត់មានបន្ទប់ទេ សុទ្ធតែលាតទាំងអស់ បាំងជុំវិញទាំងអស់ ពេលណាមានការរៀនសូត្រទៅ គេរៀនដាក់តុ រៀននៅក្រោម ពេលណាប្រជុំ អូពេលណាសំរាកពីលើ តាមបន្ទប់ៗ មួយបន្ទប់២គ្រែ ២នាក់ ម្នាក់១គ្រែៗ ក្នុងបន្ទប់ រួចមានរ៉ង់ដាជុំវិញ រ៉ង់ដាណឹងប្រហែលជាមួយម៉ែត្រប៉ុណ្ណឹង ប៉ុនទទឹងវា ជុំវិញណា ផ្លូវចូលទៅមួយ ។

**ឆាន:** ហើយដល់ពេលណាបានជាគេចាប់អ្នកដែលមានកំហុសយកទៅដាក់លើកន្លែងនោះ?

**សារ៉ាត:** អ៊ឺ ៧៧ណឹងហើយ..... សម្រាកសាលា ....ក្រៅពីណឹងក៏មានខ្លះដែរ កន្លែងខ្លះ កាលណឹងមិនរើសមុខទេ ចិនក៏ដោយ ស្អីក៏ដោយ ។

**ឆាន:** ហើយជាន់ខាងក្រោមសំរាប់ដាក់អ្នកទោសតាមរបៀបណា?

**សារ៉ាត:** ប្រភេទទី២ យកមកឃុំឃាំង ផ្ដល់ហេតុផល ខាងលើទី១ ប្រភេទទី១ ។

**ចារ៉ា:** ប្រភេទទី១ណឹង ប្រភេទកំទេចតែម្ដង?

**សារ៉ាត:** ប្រភេទកំទេច កំទេចអស់ ។

**ចារ៉ា:** គិតទៅការកំទេចណឹង តាមកំទេចគ្នាជាប់?

**សារ៉ាត:** អត់ទេ យកចូលពីណឹងមកដាក់ឡានរឹងទៅ ។

**ឆាន:** ហើយដល់ពេលក្រោមបញ្ជាកំទេចអ្នកណាជាអ្នកបញ្ជាឲ្យអ្នកយកទៅកំទេច?

**សារ៉ាត:** ........... ឈ្មោះ **សារុន** ......ពីណាធំលើគាត់ ។

**ចារ៉ា:** តែគាត់ **សារុន**នឹងសំរេចអីស្រេចចិត្តយ៉ាងម៉េច?

**សារ៉ាត:** មិនដឹងដែរ ។

**ចារ៉ា:** អាចមាន **សារុន** អីបញ្ជាពីលើកទៀត?

**សារ៉ាត:** អាចមានដែរ កាលណឹងកាលគាត់កាន់កងពលគឺថា.........សាន ។

**ចារ៉ា:** ឥសាន?

**សារ៉ាត:** កងពលឥសាន .....

**ចារ៉ា:** កងពលលេខប៉ុន្មាន?

**សារ៉ាត:** ......

**ឆាន:** ដល់ពេលអ្នកទោសជាប់អាជាន់ខាងក្រោម និយាយពីរបបហូបចុក ការធ្វើការគេឲ្យធ្វើរបៀបយ៉ាងម៉េចដែរ?

**សារ៉ាត:** ការហូបចុកមានតែសម្លល្ពៅ ហើយនៅក្នុងសម្លមានសាច់ ២ ៣ដុំ បើថាត្រីមានតែ២ ៣ដុំ តែប៉ុណ្ណឹងឯងក្នុងមួយចានៗ ។

**ឆាន:** ហើយមានបាយមានបបរទេ?

**សារ៉ាត:** បាយ មានបាយ ។

**ឆាន:** របៀបរបបឲ្យអ្នកទោសធ្វើការ?

**សារ៉ាត:** .... ទៅជាប់នៅទីណឹងមួយខែ ។

**ឆាន:** អត់មានឲ្យធ្វើការអីទេ?

**សារ៉ាត:** អត់ទេ ប៉ុន្តែវាជាង ២០ថ្ងៃហើយម្តងនេះ គេរំលែកជាពីរ មួយចំនួនគេដឹកទៅក្រោម មួយចំនួនតិចទេទៅក្រោម ។

**ឆាន:** នៅក្រោមចេញតាមទ្វារមុខ ឬទ្វារក្រោយ?

**សារ៉ាត:** យកចេញតាមទ្វារមុខ ។

**ចារ៉ា:** ទៅក្រោមណឹងទៅណាអ៊ំ?

**សារ៉ាត:** ទៅក្រោមមិនដឹងទៅណាទេ កាលណឹងអាទ្វារវាំនៅខាងកើតដល់បើកឡានទៅវាទៅខាងលិចទៅអញ្ចឹង ។

**ចារ៉ា:** បើតាមអ៊ំដឹងទៅខាងលិចណឹងទៅក្របេះ?

**សារ៉ាត:** បាទ ព្រោះផ្លូវណឹងចាក់ទៅក្របេះ ។

**ចារ៉ា:** ចេញពីផ្លូវភ្នំក្រោលណឹងអ្ហីចាក់ទៅក្របេះ?

**សារ៉ាត:** ភ្នំក្រោល ព្រោះថាប្អូនថ្លៃខ្ញុំម្នាក់ដែរ ប៉ុន្តែសល់ដល់សព្វថ្ងៃនៅកំពង់ចាម ។

**ចារ៉ា:** ប្អូនថ្លៃអ៊ំ?

**សារ៉ាត:** បាទ!

**ចារ៉ា:** ដឹកចេញទៅណា?

**សារ៉ាត:** ដឹកចេញទៅដែរ ។

**ចារ៉ា:** ហេតុអីបានរួចខ្លួន?

**សារ៉ាត:** មិនដឹង វាមិនមែនកូនកំណើតរបស់ **ទាំ ភួន** យកកូនម៉ែទៅចិញ្ចឹមទាំនៅជាមួយអញ្ចឹងណា ។

**ធាន:** ឈ្មោះអីដែរ?

**សារ៉ាត:** ឈ្មោះ **អនសា**??? នៅកំពង់ចាមសព្វថ្ងៃ ។

**ចារ៉ា:** នៅក្នុងស្រុកអីភូមិអីអឹ?

**សារ៉ាត:** មិនដឹងភូមិអី មីនេះវាទៅម្ដង កាលមុនវាធ្វើសំដែងខាងសិល្បៈខេត្តកំពង់ចាម កាលណាពេលវាមកអត់ដែលជួបម៉ែទេ មកនៅស៊ីងក្រែង ប៉ុន្មានខែត្រឡប់ទៅវិញ បីបងវាកាលប៉ែត ប៉ុន្មានវាទៅ វាម្ដងកំពង់ចាម ។

**ចារ៉ា:** នៅខេត្តណឹងតែម្ដង?

**សារ៉ាត:** ខេត្ត ធ្វើសិល្បៈខេត្តដំបូង ប៉ុន្តែឥឡូវចេញហើយ ។

**ចារ៉ា:** នៅក្នុងឆ្នាំណាកាលធ្វើសិល្បៈខេត្ត?

**សារ៉ាត:** ៨២-៨៣ ។

**ចារ៉ា:** ឈ្មោះ **អនសារ** អញ្ចឹងតែម្ដង?

**សារ៉ាត:** ឈ្មោះ **អនសារ** ។

**ចារ៉ា:** អត់មានដូរឈ្មោះទេ?

**សារ៉ាត:** **សុភាព** ។

**ចារ៉ា:** ឈ្មោះ **សុភាព** ទៀត?

**សារ៉ាត:** បាទ ប្ដីខ្មែរ ។

**ធាន:** អញ្ចឹងអ៊ំនៅក្នុងគុកណឹងគេប្រើខ្នោះដែក ឬខ្នោះឈើ?

**សារ៉ាត:** ពួកដាន់លើខ្នោះឈើ ។

**ធាន:** ហើយដាន់ក្រោម?

**សារ៉ាត:** អត់ទេ អាណឹងវាចងជើង និងចងស្លាបសេក ។

**ធាន:** ហើយខ្នោះឈើគេធ្វើរបៀបម៉េច?

**សារ៉ាត:** ឈើ ៩ ខ ៥ ណឹង គេយកមកអារលាក់បញ្ចូលជើងមនុស្ស គន្លាក់កជើងលាក់ៗ ហើយដាក់ប្រវិលទៅហើយដាក់អាមួយស៊ូកពីលើគេមានកន្លែងបោះស្មៀតគេទៀត ។

**ធានៈ** អ៊ំបានឃើញផ្ទាល់ទេ?

**សារ៉ាត:** បាទ ឃើញផ្ទាល់ ។

**ធានៈ** ពេលដែលអ៊ំជាប់នៅក្នុងកន្លែងហ្នឹង តើអ៊ំមានដែលឃើញពួកវាយកអ្នកទោសទៅសួរចម្លើយទេ?

**សារ៉ាត:** សួរដែរ សួរទាំងអស់ ទាំងខ្ញុំអីណឹង គេយកទៅសួរ ។

**ធានៈ** សួរអ៊ំ សួរតាមវិធីណាទៅ? វិធីសួរចម្លើយ?

**សារ៉ាត:** វាចង់ភ្លេចដែរ យូរហើយ ។

**ចារ៉ា:** មានវ៉ៃដំអីទេ?

**សារ៉ាត:** អត់ទេ អត់មានវ៉ៃទេ ។

**ចារ៉ា:** នៅជាន់ខាងលើពេលយកទៅសួរចម្លើយ?

**សារ៉ាត:** អាណឹងអត់ដឹងដែរ ព្រោះវាអត់ឃើញសូម្បីវាចុះចេញទៅក៏វាបិទទ្វារមិនអោយឃើញ បិទទ្វារអស់ហើយ អត់អោយយើងឃើញទេ សូម្បីអ្នកដទៃយកទៅអត់ឃើញទេយកស្ពីគ្រាប់យកទៅដាក់នៅអា...... ។

**ចារ៉ា:** អរគុណអ៊ំច្រើន ពេលអ៊ំដឹងរឿងអីទៀតចាំអ៊ំនិយាយទៀតណាអ៊ំ?

## នេត សាវ៉ាត អានឯកសារចំលើយសារភាព
## របស់ ផាន យោន, ថ្ងៃទី ១៩-១២-៩៩

*សំគាល់: សំដីក្នុងវង់ក្រចក គឺជាសំដីផ្ទាល់របស់ នេត សាវ៉ាត*
*ដែលមិនមែនជាសំដីក្នុងចំលើយសារភាពរបស់ ផាន យោន*
*(គួច=ចាន់ គួច)*

**សាវ៉ាត:** *រកស៊ីទាក់ដីរីឆ្នាំ១៩៦៧ ខ្ញុំចូលបដិវត្តន៍ តាមរយៈបង**ហាម** លេខាតំបន់១០៥ ឥសាន។ មុនដំបូងខ្ញុំធ្វើជានិរសា ដឹកនាំស្បៀង របស់អង្គការ ។*

**ចាវ៉ា:** *ត្រូវ?*

**សាវ៉ាត:** *បាទ ត្រូវទាំងអស់អត់មានកូតទេប្រចាំនៅភូមិភាគឥសានដល់ឆ្នាំ១៩៦៨ បង**ហាម** ចាត់តាំងឲ្យខ្ញុំធ្វើជានិរសាជូនបង១កម្មាភិបាលវិញ តមកក្រោយ ក្រោមការដឹកនាំរបស់ ឈ្មោះ **គុយ ធុច** (អើត្រូវហើយ) ហៅ**ធឿន គាល** ពេលនៅជាមួយ **ឃួន** បានពីរថ្ងៃ **ឃួន** ចាប់អូសទាញខ្ញុំផ្នែកសំភារៈ **ឃួន** បានឲ្យមួកស្បែកខ្មៅខ្ញុំមួយ(ត្រូវហើយមើលទៅ) ហើយគាត់ប្រាប់ខ្ញុំថា មិត្តពាក់មួកនឹងសមហើយ ព្រោះមិត្តធ្វើហ្នដីរីផង(អត់ខុសទេ) ចាប់ពីនេះមកខ្ញុំស្រលាញ់គាត់ដោយយល់ថា បង **ឃួន** ចិត្តល្អនិងខ្ញុំ។ ចុង ១៩៦៨ ខ្ញុំនិងល្បង **ឃួន** មានការទុកចិត្តគ្នាខ្លាំងហើយ ។ ថ្ងៃមួយពេលខ្ញុំ កំពុងបរដីរីដឹកគាត់ ពីមណ្ឌលគិរីទៅ ក្រចេះ(ត្រូវហើយអត់ខុសទេ) បង **ឃួន** ក៏បានប្រជុំពីបញ្ហាធ្វើបដិវត្តលំបាក ស្មុគស្មាញ មិនសប្បាយដោយគ្មានស្រីស្រា បើមិនធ្វើបដិវត្តវិញ គឺវាសប្បាយតាំងពីស្រីស្រា ។ដល់ឆ្នាំ ១៩៦៩ បង **ឃួន** បានអប់រំខ្ញុំ ឈ្មោះ **ធី** ប្រធានមន្ទីរទទួលភ្ញៀវខត្តរបស់ **ឃួន** និងឈ្មោះ **សែន** ម្តងទៀតដោយ **ឃួន**លើកពីការលំបាកដដែលរួចគាត់ចាត់(ត្រូវ)តាំងឲ្យ ខ្ញុំធ្វើសកម្មភាពប្រឆាំងនិង បដិវត្តតែម្តង ។ បង **ឃួន** លើកថាមិត្ត **ជួន** បរដីរីត្រូវបំផ្លាញ សំភារៈតាមរបៀបបរដីរី ។ ឯ មិត្ត**ធី** និងមិត្ត**សែន** ត្រូវបំផ្លាញសំភារៈរបស់អង្គការ តាមការជាក់ស្តែងដែលមិត្តអាចធ្វើបាន។ ពេលចាត់តាំងហើយខ្ញុំនិងមិត្ត **ធី** និងឈ្មោះ **សែន** បានយកក្រណាត់២ គី ក្រវ៉ាត់ចោលក្នុងព្រៃអូរច្បារ ។*

**ចាវ៉ា:** *កន្លែងណាព្រៃខច្បារ?*

**សាវ៉ាត:** *ខច្បារ១ ព្រៃលើស្រែខ្ញុំណឹង ប៉ុន្តែមិនដឹងគេបោះនៅកន្លែងណាទេ ។*

**ចាវ៉ា:** *តែដឹងថានៅក្នុងព្រៃ ?*

**សារ៉ាត:** បាទ ប៉ុន្តែមិនដឹងគេក្រវាត់ចោលកន្លែងណា និងធ្វើឲ្យបែកថ្នាំពេទ្យអស់មួយចំនួន នៅពេលដែលខ្ញុំដឹកពីក្រចេះទៅឥសាន ។ ដើមឆ្នាំ១៩៧០ ខ្ញុំត្រូវដាច់ការទាក់ទងពីបង **ឃួន**(អីត្រូវ) ដោយគាត់ត្រូវផ្លាស់មកនៅភូមិភាគឧត្តរវិញ (អឺត្រូវហើយកាលនោះគេរំសាយនិរសាហើយណា) ។

**ចារ៉ា:** ឆ្នាំណា ឆ្នាំ១៩៧០?

**សារ៉ាត:** ៧០ ។

**ចារ៉ា:** គេរំសាយនិរសា រំលាយទាំងអំទៀត?

**សារ៉ាត:** (បាទរំលាយទាំងខ្ញុំ ខ្ញុំទទួលការងារសេដ្ឋកិច្ចនៅតំបន់១០៥ តា **ជួន** ខាងពាណិជ្ជកម្ម ប៉ុន្តែតា **ជួង**គេនៅពាមជីមៀត តា **ធុច** គាត់ទៅកាន់នៅភូមិភាគឧត្តរ បាទអាណឹងកាលនៅតា **ឃួន** ម៉្លេះ) ខ្ញុំត្រូវដាច់ការទាក់ទងពីបង **ឃួន** ដោយគាត់ត្រូវផ្លាស់មក ខាងភូមិភាគឧត្តរវិញមុនពេលផ្លាស់មកបង **ឃួន** ប្រាប់ខ្ញុំថា អ្នកត្រូវទាក់ទងធ្វើសកម្មភាពជា មួយមិត្ត **កង** ចុះ ។

**ចារ៉ា:** មិត្ត **កង** ធ្វើអីដែរ?

**សារ៉ាត:** មិត្ត **កង** នៅក្រចេះធ្វើលេខាតំបន់ ។

**ចារ៉ា:** លេខាតំបន់នៅក្រចេះ?

**សារ៉ាត:** តំបន់៥០៥ មិនដឹងជន **កង** មិនដឹងប៉ុន្តែគេនៅជាមួយគ្នាណឹងគេនៅក្រចេះ **កង** មាឌខ្ពស់ស្គម ។

**ចារ៉ា:** ខ្មៅ ឬស?

**សារ៉ាត:** (មិនជាប៉ុន្មានទេ ប្រហាក់ប្រហែលខ្ញុំដែរ....) ព្រោះខ្ញុំត្រូវបែកពីមិត្តហើយការងារអ៊ី បើចង់ទាក់ទងនឹងខ្ញុំទៅតាមរយៈមិត្ត **កង** ដែរ ។ ក្រោយពេលបង **ឃួន** ប្រាប់ហើយ ខ្ញុំត្រូវផ្លាស់មកកាន់ជាសមាជិកពាណិជ្ជកម្មតំបន់ ១០៥ ប្រចាំការនៅតំបន់៥០៥ដដែល ។

**ចារ៉ា:** កងហ្នឹងហើយហ្ន៎?

**សារ៉ាត:** ហ្នឹងហើយ តា **ជួន** គាត់ថាផ្លាស់ឲ្យខ្ញុំមកកាន់ជាសមាជិកពាណិជ្ជកម្មតំបន់១០៥ (គាត់ធ្វើជាសមាជិកមែន រួចតា **ស៊ុន ចន** ធ្វើប្រធានលេខា កាលណុងខ្ញុំធ្វើអនុលេខា) ។

**ឆាង:** អនុលេខា?

**សារ៉ាត:** (អនុលេខារបស់ តា**សួង**) តំបន់៥០៥ ដល់ខែ១១-១៩៧១ ខ្ញុំជាប់ទាក់ទងជាមួយ**មិត្ត កង** (អាណឹងហើយនៅក្រចេះ) នៅក្នុងខែ១ ១៩៧២ **មិត្ត កង** បានហៅខ្ញុំទៅប្រជុំ ក្រុងក្រចេះ អ្នកចូលរួមប្រជុំមានឈ្មោះ ១. **កង** លេខាតំបន់៥០៥ ២. **ខន** ប្រធានសន្តិសុខតំបន់

៥០៥ ៣. **សៃ** អនុប្រធានសន្តិសុខតំបន់៥០៥ ៤. ខ្ញុំឈ្មោះ **ដួន** (**សៃ** នេះសង្ស័យដែរ ប៉ុន្តែដូចជាឈ្មោះ **យឹម** (និយាយភាសាឡាវ)?

**ចាវ៉ា:** កំបុតជើងពូ? ពូវាកំបុតជើង?

**សារ៉ាត:** ដំបូងមិត្តកង់ប្រាប់ខ្ញុំអោយស្គាល់ឈ្មោះ **ខន** និងឈ្មោះ **សៃ** ជាខ្មែរសេ.អ៊ី.អា ។

**ចាវ៉ា:** នេះឈ្មោះ **សៃ** ទេអី?

**សារ៉ាត:** **សៃ** ទេ បន្ទាប់មកមិត្តកងដាក់ផែនការអោយអនុវត្តគឺ បំផ្លាញសំភារៈរបស់អង្គការទាក់ទងជាមួយលោកនៅវត្តក្រចេះអោយយន្តហោះមកទំលាក់(និយាយភាសាជនជាតិ...) ដាក់កំទេចស្ពានថ្ម នៅអូរដែកដូន និងដាក់ប្រជាជននៅម្តុំនោះ ។ ក្រោយពីទទួលផែនការហើយ នៅក្នុងខែ១-១៩៧២ ដដែលខ្ញុំបានធ្វើអោយខូចឡានចិនអស់១គ្រឿង និងបង្ហូរអំបិលចេញ ពីក្នុងឡានអស់៥០០គីឡូ ចំណែកមិត្ត **កង** បានទៅទាក់ទងលោកនៅវត្តក្រចេះ ។

**ចាវ៉ា:** អឹមានស្គាល់ទេលោកឈ្មោះអី?

**សារ៉ាត:** (អត់ស្គាល់ទេ លោកនៅក្រចេះ) ដែលខ្ញុំមិនចាំឈ្មោះ ។

**ចាវ៉ា:** អូ អ្នកនិយាយអត់ចាំ ចុះទំរាំអ្នកអានទៀត?

**សារ៉ាត:** បាទ អត់ចាំឈ្មោះតាមរយៈលោកនេះ យន្តហោះក៏មកទំលាក់ខ្ទិចស្ពានពីរ (អត់ចាំទេកាលណោះមានមែនគេចោទថាលោកណុងថា គិញគាត់គង់នៅក្រចេះ) នៅអូរដែកដូង ។

**ចាវ៉ា:** ស្គាល់ទេអី អូរដែកដូង?

**សារ៉ាត:** (អត់ស្គាល់ទេ មិនដឹងនៅខាងណាក្រចេះ?) នៅអូរដែកដូនណឹងស្លាប់ប្រជាជនអស់មួយចំនួន ។ ខែ១០-១៩៧៣ ខ្ញុំត្រូវបងប្អូនហៅខ្ញុំអោយទៅជួបនៅចំការកៅស៊ូគីឡូលេខ១០ ខេត្តកំពង់ចាម ការជួបគ្នានៅពេលនោះ បង **ឃួន** បានប្រកាសបញ្ចូលខ្ញុំជាសេ.អ៊ី.អា ។

**ចាវ៉ា:** មិនមែនទេអ្ហ?

**សារ៉ាត:** ប៉ុន្តែអត់ដឹង ខ្ញុំអត់ដឹង អត់ដឹងសោះ ។

**ចាវ៉ា:** សេ.អ៊ី.អា ហ្នឹង?

**សារ៉ាត:** (បាទ តា **ឃួន** ហៅទៅប្រកាសចូលសេ.អ៊ី.អា) ក្រោយពីចូលសេ.អ៊ី.អា ហើយខ្ញុំក៏ត្រឡប់មកកន្លែងវិញ (និយាយភាសាជនជាតិ) ។

**ចាវ៉ា:** បណ្តុះបណ្តាលតា **ឃន** ណឹង?

**សារ៉ាត:** (បណ្តុះបណ្តាលតា **ឃន**) ដល់ខែ១២-១៩៧៣ **មិត្ត កង** បានហៅខ្ញុំឈ្មោះ **ខន** ឈ្មោះសៃ ទៅប្រជុំនៅក្រុងក្រចេះខ្ទឹមសារ ១. កសាងកម្លាំងសេ.អ៊ី.អា ២. បំផ្លាញសំភារៈរបស់អង្គការ

បន្តទៀត (អត់ដឹងឈ្មោះអីគេទេ (សើច) អត់ដឹងផែនការរបស់ គេ) ៣. បំផុសប្រជាជនឲ្យឃើញការស្មុគស្មាញក្នុងការធ្វើសង្គ្រាម ហើយបំផុសប្រជាជនអោយបន្ថយការដាំដុះ និងកុំអោយជួយដល់បដិវត្តបាន ។ ៤. រៀបចំអន្តរដើម្បីលួចយកទៅអោយយួនឈ្មោះ **អឹក** ជាខ្សែរយៈរបស់ឈ្មោះ **កង** និងខ្ញុំ ពេលទទួលផែន ការហើយ គឺចាប់ពីខែ១ ៧៤ ដល់ខែ៥ ១៩៧៤ ខ្ញុំកសាងកម្លាំងបាន១០នាក់ មានឈ្មោះ ១. **ស៊ុន ថន** ប្រធានពាណិជ្ជ កម្មតំបន់ ១០៥ ។

**ចាវ៉ាៈ** អីស្គាល់ **ស៊ុន ថន** ទេ?

**សាវ៉ាតៈ** (ថីមិនស្គាល់ **ស៊ុន ថន** អាណឹងគេទៅហើយ ៤០នាក់ដែរ ប៉ុន្តែអា **ស៊ុន ថន** អត់ទេខាងប្រពន្ធគេទេ **ស៊ុន ថន** អ្នកដទៃទេ ខ្ញុំអត់ទេ) ២. ថា សមាជិកពាណិជ្ជកម្ម តំបន់១០៥ ។

**ចាវ៉ាៈ** ស្គាល់ថាទេអី?

**សាវ៉ាតៈ** (ស្គាល់) ៣-**ញ៉ុន** អនុកស្តុការយោធាតំបន់ ១០៥បច្ចុប្បន្នរត់ទៅយួនហើយ(មែន) ។

**ចាវ៉ាៈ** ឥឡូវនៅយួន? មានពូជំណឹងទេ?

**សាវ៉ាតៈ** ថាត្រឡប់មកវិញដែរ មកវិញមកធ្វើនគរបាលនៅក្រចេះ គេវ៉ៃស្លាក់ ងាប់បាត់ហើយ

**ចាវ៉ាៈ** អញ្ចឹង?

**សាវ៉ាតៈ** បាទ! ៤. **ឆ្លួន** ប្រធានទទួលស្រែ នៅក-១៦ (ត្រូវ) ។

**ចាវ៉ាៈ** នៅណា ក-១៦?

**សាវ៉ាតៈ** ក-១៦ (សើច)

**ចាវ៉ាៈ** ភ្នំក្រោលហ្នឹង?

**សាវ៉ាតៈ** បាទ ជិតភ្នំក្រោលណឹងហើយ ទំនប់.....។

**ចាវ៉ាៈ** ក-១៦?

**សាវ៉ាតៈ** ទំនប់អូច្បារ ។

**ចាវ៉ាៈ** អូទំនប់អូច្បារ មន្ទីររបស់......?

**សាវ៉ាតៈ** **តាំ ភួន** ។

**ចាវ៉ាៈ** បច្ចុប្បន្នងាប់ហើយ ។

**សាវ៉ាតៈ** មើលៗ អី **នឿន** ក-១៦ បច្ចុប្បន្នងាប់ហើយណានៅពេលដែលរត់ទៅដីយួន(ត្រូវអត់ខុសទេ) ៥. **ឡាង** (អូត្រូវ)ប្រធានចិញ្ចឹមគោ ក្របីនៅ ក-១៦ បច្ចុប្បន្នគាត់ទៅយួនហើយ ៦.**ឡាំ** សមាជិកចិញ្ចឹមគោ និងក្របីនៅក-១៦ ។

**តូច:** (ភាសាលាវ) ។

**ហាវ៉ា:** បច្ចុប្បន្នរស់នៅដីយួនហើយ?

**សាវ៉ាត:** ដីយួនហើយ ។

**ហាវ៉ា:** **ឡាំ** ស្គាល់ទេអី?

**សាវ៉ាត:** ស្គាល់ **ប៊ុន** កងការពារ ។

**ហាវ៉ា:** កងការពារប៉ូលីសខេត្តណា? ខេត្តមណ្ឌលគិរីណឹង?

**សាវ៉ាត:** កងការពារអា **ខាំ ភូន** អនុលេខាតំបន់១០៥ ៨. **ផែន** (និយាយឡាវថា: អ្នកណាផែន) ផែន យុទ្ធជនណឹង ។

**ហាវ៉ា:** យុទ្ធជនការពារ?

**សាវ៉ាត:** អូ **ផែន** យុទ្ធជន **ផែន** ស្លាប់ហើយ ។

**តូច:** តាំងពី.... ។

**សាវ៉ាត:** **ខាំ ភូន** ផែន យុទ្ធជន បើមិនៗ ផែន ណឹងមិនចេះតែហៅគណបក្សពួកនេះ

**តូច:** អៅ៎ ចុះបើគេកងការពារតា **ខាំ ភូន**?

**សាវ៉ាត:** កងការពារតា **ខាំ ភូន** ។

**សាវ៉ាត:** តាំងពីតំបន់ ១០៥ **វ៉ាន** ណឹងកូន តាហម (ភាសាលាវ) ទទួលខុសត្រូវឡាន (ភាសា លាវ) .......... ។

**ហាវ៉ា:** ជាប់គុកជាមួយអីដែរ វ៉ាន ណឹង?

**សាវ៉ាត:** បាទ (ភាសាលាវ) ទទួលខុសត្រូវឡាន(និយាយពីបើកឡាន ប៊ុនគេចាត់តាំងទទួលខុសត្រូវឡាន ណឹងវា....) នៅមន្ទីរតំបន់១០៥ (ភាសាលាវ) ស៊ីយុទ្ធជន បើកឡាននៅមន្ទីរ **ស៊ីកូនតាខា** ។

**តូច:** ស៊ីកូនតា **ខា** បើកឡានឲ្យតា ហម ។

**សាវ៉ាត:** បើកឡាននៅមន្ទីរតំបន់១០៥ ។

**តូច:** ចាប់ថ្ងៃជាមួយយើង ចាប់យកមក យើងមកហើយយើងក៏ចាប់ស៊ីជាមួយគ្នាដាច់ ។

**សាវ៉ាត:** ជាមួយគ្នាទាំងអស់ (សើច) ។

**ហាវ៉ា:** បើកឡាននៅភ្នំក្រោលដែរ?

**តូច:** ដាក់ជាមួយពួកខ្ញុំណឹង ម្នាក់ណឹងទើបបើកឡាន ។

**សាវ៉ាត:** ពេលកសាង ហើយខ្ញុំបាន ។

**ឌុច:** បើកឡានគេចាប់អ្នកមកជាមួយគ្នាដែរណើង ដល់ចាប់អស់ហើយ ក៏ចាប់អាតៃកុងឡានមកដាក់ទៀត ចាប់អាតៃកុងឡានដែលដឹកគេមក ។

**សារ៉ាត:** ខ្ញុំបានដាក់ភារកិច្ចអោយពួកនេះបំផ្លាញសំភារៈតាមមុខសញ្ញាដែលខ្លួនទទួលខុសត្រូវ គឺអ្នកកាន់ឡានត្រូវបំផ្លាញឡាន អ្នកកាន់គោក្របីបំផ្លាញគោក្របី តាមការចាត់តាំងខាងលើនេះ កំឡាំងរបស់ខ្ញុំតាំងអស់បានបំផ្លាញអស់២គ្រឿង និងគោងាប់អស់មួយចំនួន ១១ ១៩៧៤ ខ្ញុំបានអោយឈ្មោះថា ទៅដឹកក្រណាត់ និងអំបិលនៅអូរ៉ាំងអោយភាគបូព៌ា ។

**ចារ៉ា,ឆាន:** ក្រណាត់អោយភាគបូព៌ា ?

**សារ៉ាត:** អោយភាគបូព៌ា មុនពេលចេញទៅខ្ញុំបានប្រាប់ មិត្ត៧ ៧ ពេលដាក់ក្រណាត់ ។

**ចារ៉ា:** ទំព័រទី៥ ចុះលេខទំព័រ ?

**សារ៉ាត:** ពេលដាក់ក្រណាត់ និងអំបិលមកវិញធ្វើយ៉ាងម៉េច បង ៧ ឯងដាក់ក្រណាត់ផ្ទាល់ ។

**ចារ៉ា:** បាទ ដាក់ក្រណាត់ផ្ទាល់ និងតួឡាន ?

**សារ៉ាត:** និងតួឡាន ឯអំបិលត្រូវដាក់ពីលើ អូ! ពីលើក្រណាត់ ។

**ចារ៉ា:** ពីលើក្រណាត់ ?

**សារ៉ាត:** ឯអំបិលត្រូវដាក់ពីលើក្រណាត់ឯណោះ ធ្វើនេះដើម្បីអោយ...

**ចារ៉ា:** អោយដឹកអំបិល ?

**សារ៉ាត:** អោយដឹកអំបិល អូ! អោយទឹកអំបិល ។

**ចារ៉ា:** អោយទឹកអំបិលហ្ន៎?

**សារ៉ាត:** អូ! ចូលប៉ះក្រណាត់ខូចសាច់ក្រណាត់ (អាណើងបានមានសាភចរវៀន) ។

**ចារ៉ា:** មានសាភចរវៀន ។

**សារ៉ាត:** បាទ វាថាខ្មាំងបំផ្លាញ (សើច) ។

**ឌុច:** កម្មវិធីណីងណា ។

**សារ៉ាត:** (អ៊ីកម្មវិធី) ក្រោយពីការណែនាំរួច បង ៧ បានធ្វើអោយទឹកអំបិលហូរដាក់ក្រណាត់នៅ លើឡានខូចអស់២កី ។

**សារ៉ាត:** ២០កី ខែ១១ ឆ្នាំ១៩៩... អូ ១៩៧៩ ។

**ចារ៉ា:** មិត្ត កង បាន

**ឆាន:** បិតសិបបួន ។

**សារ៉ាត:** ៧៨ **មិត្ត កង** បានហៅខ្ញុំទៅប្រជុំនៅក្របេះទៀត ពេលនោះខ្ញុំឃើញបង **ខាំ ភូន** ទៅប្រជុំដែរ **មិត្ត កង** និយាយថា មិត្ត **ខាំ ភូន**ៗ ឯងត្រូវធ្វើការទាក់ទងជាមួយមិត្ត ខន និងមិត្ត**សៃ** អោយជាប់ ប្រុសពីរនាក់នេះជាខ្សែ C.I.A របស់យើងដែរ ឯមិត្ត **ជួន** ក៏..

**ចារ៉ា:** ក៏មិត្តត្រូវតែទាក់ទង ?

**សារ៉ាត:** ក៏មិត្តត្រូវតែទាក់ទងដែរ តែ ជួន ។

**ចារ៉ា:** តែ ជួន ?

**សារ៉ាត:** តែ ជួន ។

**ចារ៉ា:** វាងាយ ?

**សារ៉ាត:** ជួន វាងាយ ។

**ចារ៉ា:** ក្នុងការទាក់ទងទេ ?

**សារ៉ាត:** ក្នុងការទាក់ទងទេៗណា ប្រការបដិវត្តធ្វើនៅតំបន់តែមួយ បន្ទាប់មក**កង** និយាយទៀតថា ផែនការរបស់យើងនៅពេលនេះ គឺកសាងកំលាំងស្នូលសំរាប់ដឹកនាំធ្វើសកម្មភាពថែមទៀត ។ ចំណែកមិត្ត **ខាំ ភូន** ឯងនៅតំបន់១០៥ ត្រូវបំផ្លាញអោយស្របតាមការចាត់តាំងរបស់បក្ស ។ ពេលទទួលផែនការហើយ ខ្ញុំបានបំផ្លាញអំបិល គឺទុកអោយ អំបិលទុកឲ្យ ត្រូវទឹក ភ្លៀងរលាយអស់ ៥០០គីឡូ ក្រៅពីនេះខ្ញុំបានចាត់ បានចាក់ទំលាយសាំងនៅក្នុងធុងអោយធ្លាយអស់១៥០លីត្រទៀត ដល់ខែ១ ឆ្នាំ១៩៧៥ **មិត្ត កង** បានហៅខ្ញុំទៅ ប្រជុំនៅក្នុង នៅក្រុងក្របេះ អ្នកចូលរួមប្រជុំ ។ មានឈ្មោះ១- **កង** អនុលេខាតំបន់៥០៥ ២. ឈ្មោះ **ខន** មុនសន្តិសុខបច្ចុប្បន្ននៅធ្វើឥដ្ឋនៅភូមិថ្មក្រែ ។

**ចារ៉ា:** ស្គាល់ទេអី?

**សារ៉ាត:** អត់ទេ ៣- **សៃ** មុនសន្តិសុខធ្វើស្រែនៅសាយជ្រះ តំបន់ ៥០៥ (អត់ស្គាល់ដែរ) ៤ខ្ញុំឈ្មោះ **ជួន** ។

**ចារ៉ា:** ទំព័រទី៦ លួម៉េះណឹង អ្នកណឹងសារភាពអេណា **ជួន** ណឹងសារភាពទេណា ។

**សារ៉ាត:** បាទ **មិត្ត កង** និយាយថា សភាពការណ៍ឥឡូវអង្គការជិតវាយចូលក្រុងភ្នំពេញហើយ ដូច្នេះបើវាយបែកភ្នំពេញ មិត្តទាំងអស់ត្រូវចុះ ត្រូវប្រមូល ។ ទៅប្រមូលថ្នាំពេទ្យ ក្រណាត់និងសំភារៈផ្សេងៗទៀតគឺប្រមូលយកទុកអោយបានច្រើនដើម្បីយើងទៀត (អញ្ចឹងហើយណា) ។ ដើម្បីយើងត្រៀមទុកសំរាប់ធ្វើសង្គ្រាមជាមួយបដិវត្តទៅថ្ងៃមុនពេលទទួលផែនការនេះ ហើយខ្ញុំបានយកផែនការនេះទៅផ្សាយអោយឈ្មោះ**ថា** និង **ស៊ុន ថន, ញ៉ុន, ធៀន, ឡាង, ឡាំ,**

**ប៊ុន, វ៉ែង, វ៉ាន, ស៊ី, វ៉ុន** ដឹងតែផែនការនេះ ខ្ញុំមិនបានយកទៅអនុវត្តទេ។ ព្រោះនៅថ្ងៃរំដោះភ្នំពេញនេះ ខ្ញុំត្រូវគ្រាប់បែកៗបាក់ បាក់ស្នងជើងម្ខាងៗដេកដេកពេទ្យអស់ពេល១ឆ្នាំ ទើបជើងខ្ញុំដើរបានគួរសម ។

**ចាន់:** អញ្ចឹងៗ អ៊ុំ **ខាំ ភួន** ណឹង អូ! **ផាន ឃាន** ណឹងហៅ **ជួន** ណឹងបាក់ជើង? បុក ហ៎?

**សារ៉ាត:** (ខ្ញុំក៏មិនសូវចំណាំដែរ) ។

**តូច:** អញ្ចឹងបានគេហៅ **ង៉ក់ ធុះ** ។

**ចាន់:** មានហៅគា **ង៉ក់** ទៀត ?

**សារ៉ាត:** មែនៗហើយ នៅឆ្នាំ១៩៧៦ ខ្ញុំធ្វើការទាក់ទងជាមួយបង **ខាំ ភួន** និងតំបន់១០៥វិញ ខែ ២ ១៩៧៦ ។

**ចាន់:** មន្ទីរគាត់ហ៎?

**សារ៉ាត:** (មន្ទីរ **ខាំ ភួន** ណឹង) ។

**ចាន់:** ចុះមុនថាបន្ទាយ **ហម** ?

**សារ៉ាត:** (អត់ទេ ក-១៦ បន្ទាយ **ខាំ ភួន**) ។

**ចាន់:** អញ្ចឹង!

**សារ៉ាត:** (ក-១៧ មន្ទីរ ហម) ។

**សារ៉ាត:** នៅក្នុងមន្ទីរពាណិជ្ជកម្មតំបន់១០៥អ្នកចូលរួមប្រជុំមានឈ្មោះ១-**ឈិន ថន** ប្រធានពាណិជ្ជកម្មតំបន់១០៥ ២ ឡាប់ ។

**ចាន់:** **ឡាប់** ណឹងអ្នកណា?

**សារ៉ាត:** អនុប្រធាន អាណឹងហើយត្រូវមីងប្រពន្ធខ្ញុំ ។

**ចាន់:** មីងរបស់ប្រពន្ធអ៊ំ? នៅរស់ទេរាល់ថ្ងៃ?

**សារ៉ាត:** ស្លាប់ហើយ ។

**ចាន់:** ស្លាប់ៗដោយសារអី?

**សារ៉ាត:** ហ៎ !

**ចាន់:** ស្លាប់ដោយសារអីដឹងទេ?

**សារ៉ាត:** ស្លាប់គេសម្លាប់ណឹងណា ។

**ចាន់:** ពួក ប៉ុល ពត សម្លាប់?

**សារ៉ាត:** បាទ!

**ចារ៉ា:** ដឹងឆ្នាំទេ?

**សារ៉ាត:** ឆ្នាំ៦៦ អូ ៧៦ ណឹង ។

**ចារ៉ា:** ឆ្នាំ៧៦?

**សារ៉ាត:** បាទ!

**ចារ៉ា:** សម្លាប់ ?

**សារ៉ាត:** ៧៦, ៧៧ ណឹងហើយ ។

**ចារ៉ា:** សម្លាប់នៅឯណាអ៊ំ?

**សារ៉ាត:** នៅភ្នំក្រោល ។

**ចារ៉ា:** នៅភ្នំក្រោល?

**សារ៉ាត:** បាទ!

**ចារ៉ា:** អ៊ំឃើញទេ ហីអ៊ំដឹង?

**សារ៉ាត:** គ្រាន់តែដឹងទេ អត់ឃើញផ្ទាល់ភ្នែក ។

**ចារ៉ា:** ប៉ុន្តែដឹង ប៉ុល ពត សម្លាប់នៅភ្នំក្រោលណឹង?

**សារ៉ាត:** បាទ!

**ចារ៉ា:** ដឹង អ៊ំដឹងតាមរយៈអីគេដែរ បានអ៊ំដឹង?

**សារ៉ាត:** តាមរយៈគេឯងណឹងណា ។

**ចារ៉ា:** គេឯងនិយាយ?

**សារ៉ាត:** បាទ មុនចាប់គាត់ណឹង បានក្រោមមកចាប់ពួកខ្ញុំ ខុសគ្នាប្រហែល ៤,៥ ថ្ងៃ **ឡាប់**អនុប្រធានពាណិជ្ជកម្មតំបន់១០៥ នារីៗ គេដាក់នារី អញ្ចឹងហេ ។

**ចារ៉ា:** បាទ!

**សារ៉ាត:** **ឲា** សមាជិកពាណិជ្ជកម្មតំបន់១០៥ ៤. ខ្ញុំឈ្មោះ **ជួន** (ត្រូវហើយចំលើយនេះ) ។

**ចារ៉ា:** ចម្លើយណាត្រូវ?

**សារ៉ាត:** ប៉ុនខ្ញុំដើរទៅ ខ្ញុំឃើញម្តង ។

**ចារ៉ា:** ឃើញអ្នកណា?

**សារ៉ាត:** ឃើញគេប្រជុំ ។

ចាក់: ប្អូននាក់គេហ្នឹង?

សារ៉ាត: បាទ ហើយគេឃើញ ខ្ញុំគេក៏ឈប់និយាយទៅ ។

ចាក់: កាលប្រជុំប្អូននាក់ **ស៊ុន ថន ឡាប់ ថា** ហើយនិង **ជួន** ណើងហ្នុំ ?

សារ៉ាត: ណើងហើយ ។

ចាក់: ប្រជុំនៅណាអ៊ី?

សារ៉ាត: នៅ ក-១៦ ?

ចាក់: បាទ!

សារ៉ាត: អឺ!

ចាក់: ក-១៦ នៅណា នៅភ្នំក្រោលដែរ?

សារ៉ាត: នៅអូរច្បារ ទំនប់អូរច្បារ ។

ចាក់: នៅតំនប់អូរច្បារ កន្លែងស្រែអ៊ីណើងហេ៎?

សារ៉ាត: អត់ទេ ទំនប់អូរច្បារ ឯកោះញែកណើង ។

ចាក់: កោះញែក?

សារ៉ាត: **ទាំ ភួន** លើកឡើងថា ការប្រជុំនេះគឺខ្ញុំលើកផែនការសម្រាប់អោយមិត្ត ទាំងអស់ធ្វើសកម្មភាព បំផ្លាញសំការៈរបស់បក្សក្នុងផែនការបំផ្លាញសំការៈរបស់បក្សនេះ ស្មើមិត្តធ្វើទៅតាមកន្លែងដាក់ ស្តែងរៀងៗខ្លួន **ទាំ ភួន** និយាយបញ្ជាក់ថា បញ្ជាក់ ឈ្មោះ **ថា** ចំណែកមុខសញ្ញារបស់ខ្ញុំទុក អោយខ្ញុំបំផុសប្រជាជនអោយ ប្រចាំ អូអោយប្រឆាំងមាគ៌ា កសាងប្រទេសរបស់បក្ស ។

ចាក់: មាគ៌ាកសាងប្រទេសម៉េចទៅអ៊ី?

សារ៉ាត: មាគ៌ាកសាងប្រទេស (សើច) ដូចជាការកសាងប្រទេសជាតិយើង តើកសាង...

ចាក់: ប៉ុន្តែមានមាគ៌ាមកទេ?

សារ៉ាត: មានៗ

ចាក់: មានមាគ៌ា មានគោលនយោបាយដាក់ចុះមកទេ?

សារ៉ាត: បាទមានៗ

ចាក់: អ៊ីធ្លាប់រៀន ធ្លាប់ជួបទេ?

សារ៉ាត: បាទ ធ្វើទំនប់ជីកប្រឡាយ ធ្វើផ្ទះ ធ្វើសំបែងអញ្ចឹងហើយណា ។

ចាក់: អូរអាណើងមាគ៌ាកសាងប្រទេសជាតិយើង?

**សារ៉ាត:** បាទ កសាង ធ្វើទំនប់ ធ្វើប្រឡាយ ធ្វើស្រែ ធ្វើចំការណឹងណា ដល់បង្កបង្កើតផលណឹងកសិកម្ម ពាក្យថាកសាង ។

**សារ៉ាត:** ទុកអោយខ្ញុំបំផុសប្រជាជនអោយប្រឆាំងមាគ៌ាកសាងប្រទេសរបស់បក្ស ផ្នែកខាងមិត្ត**ស៊ុន ថន** ទទួលខាងចែកចាយសំភារៈធ្វើយ៉ាងណាចែកចាយប្រជាជនកុំអោយគ្រប់គ្រាន់ ចប ប៉ែល ដែល ចែកប្រជាជនកុំអោយគ្រប់គ្រាន់ដែរ ដើម្បីអោយស្ទះដល់ការបង្កបង្កើនផលរបស់អង្គការ ។ ៦ ខាងមិត្ត **ជួន** ត្រូវធ្វើសកម្មភាពអោយឲ្យស្ទះក្នុងការដឹកជញ្ជូនសំភារៈគឺ ដឹកអោយយឺតក្រៅពី នេះ ដើរបំផ្លាញសំភារៈតាមស្របច្បាប់ គេទទួលផែនការនេះហើយខ្ញុំបាន ទៅហៅឈ្មោះ **វ៉ាន** និង **ស៊ី វ៉ុន** និង **ឡៀន, ឡាំ, ឡាង, ញ៉ុន, ដែង** ត្រូវប្រជុំ ក-១៦ដដែល ។ ខ្ញុំបាន ណែនាំទាំងអស់គ្នានេះថា ស្នើឲ្យមិត្តទាំងអស់ធ្វើ សកម្មភាពបន្តទៀត ធ្វើទៅតាមទីកន្លែងនិង តាមសំភារៈដែលខ្លួនមាន ដូចជាអ្នកឃ្វាលគោ ក្របី ត្រូវបង្អត់ស្មៅ ។

**ឋារ៉ា:** ឲ្យស្គម?

**សារ៉ាត:** ឲ្យស្គម និងឈានទៅងាប់ ។

**ឋារ៉ា:** ឈានទៅងាប់?

**សារ៉ាត:** ខាងម៉ាស៊ីន ។

**ឋារ៉ា:** បូមទឹក?

**សារ៉ាត:** បូមទឹកធ្វើឲ្យខូចញឹកញាប់ដើម្បីអត់ទឹកបញ្ចូលស្រែ និងផ្នែកអ្នកបើកឡានៗខូចល្មមៗអារម្មណ៍ ទៀត អារម្មណ៍ទៀតពេលខ្ញុំណែនាំហើយនៅក្នុងខែ២ ១៩៧៦ ដដែលនៅខាងមិត្តអី មិត្ត **ឡាំ** និងមិត្ត **ឡាង** បានបង្អត់ធ្វើអោយគោ ក្របី ស្គមប្រើការមិនកើតអស់មួយចំនួនងាប់អស់ ៨ ក្បាល ។

**ធាន:** អញ្ចឹងងាប់ទៅអីដែលឃើញទេអ៎ី?

**សារ៉ាត:** (មិនបានឃើញដែរ ងាប់អស់៨ក្បាលយូរវាមិនចាំដែរណា) មុខសញ្ញាបើកឡានមានអ្នក **វ៉ាន** និង អ្នកស៊ី (ឈ្មោះណឹងដឹងអស់) ។

**ឋារ៉ា:** ដឹងទាំងអស់អ៎ីហ៎?

**សារ៉ាត:** (បាទ) បានធ្វើអោយខូចម៉ាស៊ីនអស់២គ្រឿង ដោយឡែកផ្នែកខាងមិត្ត **ឡៀន** និង **វ៉ុន** ធ្វើឲ្យ ខូចម៉ាស៊ីនបូមទឹកជាញឹកញាប់ ខែ៨ ១៩៧៦ មិត្ត **ខាំ ភួន** បានហៅខ្ញុំ និងឈ្មោះ **ញ៉ុន** ទៅ ជួបគាត់នៅមន្ទីរ ក-១៦(ត្រូវហើយ) ។

**ឋារ៉ា:** ត្រូវទៀត?

**សារ៉ាត:** ពេលនោះប្រពន្ធ **ខាំ ភួន** ឈ្មោះ ឡាត់ ក៏នៅជាមួយគ្នានេះដែរ មិត្ត **ខាំ ភួន** និយាយនិង ប្រាប់ខ្ញុំឲ្យដឹងថា ខ្ញុំស្នើឲ្យមិត្ត **ញួន** និង ម៉ែអា **ខាំឡាប់**?

**ចារ៉ា:** ម៉ែអា ខាំ?

**សារ៉ាត:** បាទ!

**ចារ៉ា:** ឈ្មោះ **ឡាប់** នឹងហេ៎?

**សារ៉ាត:** បាទ **ឡាប់** គឺឈ្មោះ **ឡាប់** នៅធ្វើសកម្មភាពក្នុងមន្ទីរពិសេសដឹកនាំមិត្តយើងខាង ខាង គាត់ដែរ កុំអោយគាត់ៗដេរខោ អូ! កុំអោយកាត់ខោ ។

**ចារ៉ា:** កុំអោយកាត់ដេរខោអាវ ?

**សារ៉ាត:** កុំអោយកាត់ដេរខោអាវ បានលឿនពេក (សើច) ..... ធ្វើនេះដើម្បីអោយស្ទះដំណើរបដិវត្ត ព្រោះឥឡូវអង្គភាពកំពុងតែត្រូវការ ចង់បានខោអាវ ជាប់ជង អូ! ឆាប់ជង ឯខាងមិត្ត **ជួន** ក៏ ធ្វើសកម្មភាពអោយខ្លាំងដែរ ដល់បច្ចុប្បន្នអង្គការតំបន់អោយមិត្តដឹកម៉ាស៊ីនបូមទឹកពីក្រចេះមក មណ្ឌលគិរីសម្រាប់យកមកបូមទឹកដាក់ស្រែ ដោយស្រែឥឡូវអត់មានទឹកទេ តាមសកម្មភាពការ នេះ ស្នើមិត្តកុំ កុំដឹកនាំហ្ន? កុំដឹក....

**ចារ៉ា:** កុំដឹកម៉ាស៊ីនបូមអោយសោះ?

**សារ៉ាត:** កុំដឹកម៉ាស៊ីនមកអោយសោះ ហើយមិត្តត្រូវដោះស្រាយជាមួយអង្គការតំបន់ថា រវល់ដឹកសំភារៈ ផ្សេងៗទៀតជាច្រើនៗ ខ្ញុំស្នើទៅវិញថាតាមការលើកៗនេះ វាស្របទៅតាមផែនការរបស់ អង្គការហើយ ពេល**ខាំ ភួន** ណែនាំហើយ ខ្ញុំបានទៅណែនាំមិត្ត មិត្តអីគេ?

**ចារ៉ា:** អ៊ុំ មិត្ត...?

**សារ៉ាត:** **សួន** ។

**ចារ៉ា:** បាទ!

**សារ៉ាត:** តើអ្នកណាមិត្ត **សួន**? ជាអ្នកបើកឡាន ។

**ចារ៉ា:** ជាអ្នកបើកឡាន ?

**សារ៉ាត:** អូ! មិត្ត **សួន** ណឹងហើយ ។

**ចារ៉ា:** មិត្ត **សួន** ណាអ៊ំ?

**សារ៉ាត:** នៅជំរំឥឡូវ ។

**ចារ៉ា:** នៅជំរំ?

**សារ៉ាត:** បាទ ជំរំ ៤-៣ ។

**ចារ៉ា:** អ៊ី អឹស្គាល់ណាអញ្ចឹង ?

**សារ៉ាត:** បាទ ឲ្យៗ ។

**ចារ៉ា:** ឲ្យពន្យាពេល?

**សារ៉ាត:** ឲ្យពន្យាពេល ក្នុងការដឹកម៉ាស៊ីននេះ គឺខ្ញុំ និង **សួន** ទុកឲ្យយូរពេលកន្លែងខ្លះស្រូវស្រាល ។

**ចារ៉ា:** ឆ្ងាយ?

**សារ៉ាត:** អូស្រូវឆ្ងាយៗពីទឹកត្រូវស្អក (អ៊ឺ ត្រូវហើយ ឆ្នាំណឹងត្រូវអញ្ចឹងមែន) ស្អកដោយអត់ទឹកស្រែប្រាំង ក៏អត់មានទឹកដាក់ស្រែដែរ ដល់ពេលមានភ្លៀងធ្លាក់មក ទើបខ្ញុំអោយ**សួន** ដឹកម៉ាស៊ីនមកបូមទឹកដាក់ស្រែ តែសកម្មភាពវា វាហួស ។

**ចារ៉ា:** ហួសទៅហើយ តែសភាពការណ៍វាហួសទៅហើយ ?

**សារ៉ាត:** តែសភាពការណ៍វាហួសទៅហើយ ធ្វើអោយស្រូវស្អកអស់ ។

**ចារ៉ា:** ខ្ទង់....

**សារ៉ាត:** ខ្ទង់...

**ចារ៉ា:** ១០ហិកតា ?

**សារ៉ាត:** ១០ហិកតា ។

**ចារ៉ា:** អីច្រើនម្ល៉េះអ៊ំ?

**សារ៉ាត:** (ច្រើនណាស់អើយ ស៊ីឆ្នាំណឹងវាស្អកមែនទែនហើយទូទៅមិនធម្មតាទេ) ។

**ចារ៉ា:** នៅណាអ៊ំ?

**សារ៉ាត:** (ក្នុងវង្វង់កោះញែកយើងទាំងអស់ ។)

**ចារ៉ា:** អញ្ចឹង បាទ ·

**សារ៉ាត:** (សុទ្ធតែចង្អុលមេឃទាំងអស់ណឹង អត់មានគ្រាប់) ខែ៩ ១៩៧៧ អង្គការតំបន់បានចាត់តាំងខ្ញុំអោយទៅទាក់ទងជាមួយពាណិជ្ជកម្ម ភូមិភាគកណ្តាល ដើម្បីយកយកដីរទៅដូរសេះ ទៅដូរយកសេះមកចិញ្ចឹមវិញ ។

**ចារ៉ា:** ចង់បានសេះធ្វើអីអ៊ំ?

**សារ៉ាត:** (សើច) ......

**ចារ៉ា:** ពេលនោះ ?

**សារ៉ាត:** ពេលនោះ ខ្ញុំបានធ្វើដំណើរតាមកាណូតមកជាមួយឈ្មោះ **ថាវ** ។

**ចារ៉ា:** នរណាគេ **ថាវ**?

**សារ៉ាត:** ចង់ភ្លេចហើយ **ថាវ** អត់មានទេឈ្មោះ **ថាវ** ខ្ញុំទៅដល់មន្ទីរពាណិជ្ជកម្ម **ថាវ** ។

**សារ៉ាត:** ភូមិភាគកណ្តាល ខ្ញុំបានជួបជាមួយឈ្មោះ **ជ័យ** ប្រធានពាណិជ្ជកម្មលើកទី១នេះ ខ្ញុំនិង ឈ្មោះ **ជ័យ** បានសំរេចដូរដីរ៍១០ក្បាលជាមួយនឹងសេះ ៣០ក្បាល។ ក្រៅពីឡើងទាក់ទងគ្នារឿងដូរៗ សត្វ ហើយ (ភាសាលាវ) អូៗ **ជ័យ** ក៏មានការទាក់ទងជាមួយខ្ញុំខាង ។

**ចារ៉ា:** ទំព័រទី៣៤?

**សារ៉ាត:** ខាងសំភារៈក្រៅផ្លូវៗការ ដែលអង្គការចាត់តាំងឈ្មោះ **ជ័យ** សួរខ្ញុំថា បងជួន ឯងមាន ប្រហុកហូបឬទេ? ខ្ញុំឆ្លើយថាអត់មាន តែមានបន្តិចបន្តួច **ជ័យ** បន្តថា បើគ្មានប្រហុកទេខ្ញុំឲ្យ បងឯងយកទៅហូបមួយគោនចុះ ពេលសម្រេចរឿងដូរខាត់ហើយ ខ្ញុំក៏ត្រឡប់មក កន្លែងវិញ ដោយយកប្រហុកមួយគោនមកផង។ កន្ទះខែក្រោយមកទៀតនៅក្នុងខែ៦ ៧៧ ដដែលខ្ញុំបាន ទៅជួបឈ្មោះ **ជ័យ** ម្តងទៀត ដើម្បីសំរេចថ្ងៃយកដីរ៍ និងសេះទៅជួប **ជួន** គ្នា នៅក្រចេះ គឺ ត្រូវដូរនៅថ្ងៃ១៥ ខែ៦ ៧៧ ក្រៅពីការងារអង្គការខ្ញុំក៏បានសួរឈ្មោះ **ជ័យ** ថា មិត្ត **ជ័យ** មាន។

**ចារ៉ា:** ពីស្តុង ?

**សារ៉ាត:** មានពីស្តុង ម៉ូតូទេសូមមួយមក ?

**ចារ៉ា:** **ជ័យ** អ្នកណាគេ **ជ័យ**?

**សារ៉ាត:** (អត់ស្គាល់ទេ **ថា**នៅភូមិភាគកណ្តាល) មិត្ត **ជ័យ** ឆ្លើយថា ពីស្តុង អត់មានទេ បើអត់អី ប្រើទេបងឯងយកម៉ូតូហុងដា៩០ មួយ ទៅប្រើតែម្តងទៅ ។ ខ្ញុំថា បើមិត្ត**ជ័យ** ឯងអោយ អញ្ចឹង ស្រួលហើយ លើកទី២អញ្ចឹងហើយហ្ន៎ ។

**ចារ៉ា:** បាទ!

**សារ៉ាត:** លើកទី២នេះ **ជ័យ** បានអោយខ្ញុំ ។

**ចារ៉ា:** ហុងដា?

**សារ៉ាត:** ហុងដា ៩០មួយគ្រឿង និងត្រីងៀតមួយគោន ទៀត ហើយមិត្ត **ជ័យ** ប្រាប់ខ្ញុំថា យើង ចាប់ពី ថ្ងៃនេះទៅត្រូវទាក់ទងគ្នាអោយជាប់ ខ្ញុំឆ្លើយថាបាទ ដល់ចុងខែ៦ ៧៧ ខ្ញុំទៅទទួល សំភារៈនៅភ្នំពេញតាមផ្លូវទឹកទន្លេមេគង្គ ពេលត្រឡប់ពីភ្នំពេញវិញ ខ្ញុំបានឡើងទៅជួបមិត្ត **ជ័យ** ម្តងទៀត (អុញនៅណា មិត្ត **ជ័យ** ណឹង?)

**ចាក់:** អ៊ំអត់ដែលស្គាល់សោះហ្នឹង?

**សារ៉ាត:** អត់ទេ ម្តងទៀតនៅពាណិជ្ជកម្ម ភាគកណ្តាល (អញ្ចឹងហេ?)

**ចាក់:** បាទ !

**សារ៉ាត:** ពាណិជ្ជកម្ម ?

**ចាក់:** ភាគកណ្តាល ។

**សារ៉ាត:** ភាគកណ្តាល ។

**ចាក់:** ក្រុង ?

**សារ៉ាត:** ក្រុងកំពង់ចាមអូ!

**សារ៉ាត:** ខ្ញុំអត់អីទេ **ជ័យ** បន្តទៀតថា បើនិយាយពីខាងខ្ញុំវិញប្រជាជនហូបកន្ទក(អានេះគា **ជ័យ** និយាយ) ហូបកន្ទកហើមខ្លួនអស់ហើយ ហើយក្នុងសភាពខុះខាតនេះខ្ញុំកើតស្អុកស្អាញក្នុងសតិ-អារម្មណ៍ណាស់ ពិសេសតំបន់៤១ មានការខុះខាតជាងគេ ខ្ញុំសួរថា ពីណាគេនៅតំបន់៤១**ជ័យ** ថាពីមុនមានឈ្មោះ **ស្រេង** ។

**ចាក់:** ស្គាល់ទេ អ៊ំ **ស្រេង**?

**សារ៉ាត:** អត់ទេ ។

**ចាក់:** ទំព័រទី១០ ?

**សារ៉ាត:** ពីមុនមានឈ្មោះ **ស្រេង** អ្នកក្តាប់តំបន់៤១នេះ ឥឡូវនេះខ្ញុំកាន់តែស្អុកស្អាញដោយមិនទាន់ឯកភាពជាមួយបក្ស ខ្ញុំប្រាប់មិត្ត **ជ័យ** វិញថា ប្រជាជនខាងខ្ញុំមិនសូវខុះខាតទេ តែឥឡូវកំពុងស្អុកស្អាញពីបញ្ហាសម្រុកធ្វើស្រែទាំងយប់ទាំងថ្ងៃ ហើយនៅក្នុងក្រសួងពាណិជ្ជកម្មរបស់ខ្ញុំក៏មានការស្អុកស្អាញដែរ ។ ក្នុងការស្អុកស្អាញនេះ ដោយនៅពាណិជ្ជកម្ម ១០៥មានខ្មាំងធ្វើសកម្មភាព ខ្ញុំនិយាយដល់កន្លែងនេះ **ជ័យ** ក៏ប្រាប់ខ្ញុំតិចៗថា នៅខាងខ្ញុំក៏អញ្ចឹងដែរ គឺមានឈ្មោះ **ស្រេង** ក្បត់បានជាប្រជាជនមានការខុះខាត តែចំពោះសភាពខុះខាតនេះ ខ្ញុំក៏ពេញចិត្តដែរ ។

**ចាក់:** ម៉េចពេញចិត្តដែរវិញ?

**សារ៉ាត:** (ណឹងហើយអញ្ចឹងហើយណា ពេញចិត្តដែរ) ចាំមើលខ្ញុំធ្វើការជំនួស **ស្រេង** វិញ(**ជ័យ**និយាយអញ្ចឹង)ធ្វើការជំនួស **ស្រេង** វិញមើលវាយ៉ាម៉េចទៅវិញ ខ្ញុំសួរ**ជ័យ** ថា ក្នុងការជំនួសនេះតើជំនួសយ៉ាងណា? **ជ័យ** ឆ្លើយខ្សឹបៗថា ខ្ញុំជំនួសក្នុងការងារ ភូមិភាគឥឡូវខ្ញុំ សួរបង **ជួន** ឯងតើបងឯងដែលស្គាល់ **ស្រេង** ទេ? ខ្ញុំថាស្គាល់ឈ្មោះ **ស្រេង** (គេស្គាល់គ្នា) បន្ទាប់មក **ជ័យ**

បេះតែនិយាយសារចុះសារឡើងថា ខ្ញុំជំនួស **ស្រេង** ហើយក្នុងការធ្វើការងារសព្វថ្ងៃនេះសំដីនេះខ្ញុំយល់ខ្លះៗ ខ្ញុំក៏និយាយទៅ **ជ័យ** វិញថា ការងារខ្ញុំធ្វើសព្វថ្ងៃក៏ដូច **ជ័យ**ឯងដែរ ។ **ជ័យ** បញ្ជាក់ថា បង **ជួន** ឯងធ្វើអ្វី? ខ្ញុំដាច់ចិត្តឆ្លើយដោយទុកចិត្ត **ជ័យ** ថាខ្ញុំមានសកម្មភាពប្រឆាំងបក្សដែរ ពេលដឹងថាខ្ញុំ ប្រឆាំងបក្សដូចគាត់ **ជ័យ** សើចញឹមៗហើយប្រាប់ខ្ញុំថា ខ្ញុំក៏ដូចបងខ្ញុំធ្វើសកម្មភាពជាមួយឈ្មោះ **ស្រេង** យូរមកហើយ ហើយបើអស់**ស្រេង** នៅខ្ញុំទៀតក្រោយ ដឹងថាក្បត់ ដូចគ្នាហើយ ខ្ញុំសួរទៅមិត្ត **ជ័យ** ថា ខ្សែខាងមិត្តមានអ្នកណាទៀតទាំងខាងលើទាំងខាងក្រោម **ជ័យ** ប្រាប់ថា ខ្សែលើរបស់ខ្ញុំគឺ **ឃួន** និង **ស្រេង** ចុះពី **ស្រេង** គឺខ្ញុំហើយ ខ្សែបន្ទាប់ខ្ញុំទៅទៀតមាន ឈ្មោះ **អ៊ី ជា** ។

**ឆាន:** **អ៊ី ជា** អ៊ំស្គាល់គាត់ទេ?

**សារ៉ាត:** (អត់ទេ) ឈ្មោះ **អ៊ី ជា** ទំព័រទី១១ អនុរបស់ខ្ញុំប្រចាំនៅមន្ទីរចាត់ការរបស់ពាណិជ្ជកម្មភាគកណ្តាល ខ្ញុំត្រូសួរឈ្មោះ **ឃួន** ខ្ញុំក៏ប្រាប់ **ជ័យ** ថា ខ្ញុំកាលពីឆ្នាំ១៩៦៨ នៅជាមួយ **ឃួន** ដែរហើយ **ឃួន** នេះហើយ អប់រំខ្ញុំអោយធ្វើសកម្មភាពនោះ **ជ័យ** ឆ្លើយយ៉ាង រហ័សមកខ្ញុំវិញថាបើអញ្ចឹងវាមិនដូចគ្នាទៅហើយ ក្បាលម៉ាស៊ីនតែមួយ វារឹតតែឯកភាពគ្នាទៅទៀតហើយខ្ញុំសួរទៅមិត្ត **ជ័យ** ថា ផែនការនៅខាង **ជ័យ** ឯងអនុវត្តយ៉ាងម៉េច **ជ័យ** ថាចំពោះផែនការខាងខ្ញុំគឺមានផែនការកំទេចបក្សកុម្មុយនិស្តកម្ពុជា ឯកំឡាំងសំរាប់ផែនការនេះខាងខ្ញុំបាត់ម្ចាស់ការចង់អស់ហើយ កំឡាំងដែលជួយវាយគឺទាក់ទងទៅខាងកំឡាំង សៀម តាមខ្សែទាក់ទងចាស់របស់ឈ្មោះ**ស្រេង** ចំពោះខ្សែទាក់ទងទៅសៀមនេះ ស្រេចលើខ្ញុំមានតែខ្ញុំក្តាប់ផែនការទាក់ទងសៀមបានក្រៅពីនេះ អន្តការចាប់អស់ហើយ **ជ័យ** សួរខ្ញុំវិញថា ផែនការខាងបងឯងធ្វើយ៉ាងម៉េចដែរ? ខ្ញុំថា ផែនការខាងខ្ញុំគឺធ្វើស្របតាមភារកិច្ច ។ ផែនការសំខាន់គឺរៀបចំកម្លាំងរត់ទៅយួន មានបង **ខាំ ភួន**អ្នកដឹកនាំ ក្រៅ ពីនេះមានខ្ញុំ និង **ស៊ុន ថន** ។

**ឆាន:** ស្គាល់ទេ?

**សារ៉ាត:** (បាទស្គាល់!) **ជ័យ** សួរខ្ញុំទៀតថា ចំពោះផែនការខ្ញុំនេះបង**ជួន** ឯងមានកម្លាំងខ្លះគ្រាន់ចូលរួមទេ ខ្ញុំថា ខ្ញុំគ្មានកំឡាំងច្រើនទេ មានត្រឹមតែធ្វើសកម្មភាពនៅកន្លែងតែប៉ុណ្ណោះ **ជ័យ** ថាបើគ្មានកម្លាំងទេ ផែនការខាងខ្ញុំទុកខ្ញុំដោះស្រាយវាយហើយ ហើយខាងបងឯងធ្វើផែនការខាងនោះចុះ តែទិសផែនការខាងខ្ញុំចាប់ធ្វើនៅក្នុងខែ៨ ឬខែ៩ ឆ្នាំ១៩៧៧ហើយ ។ ការពិភាក្សាគ្នាបានតែប៉ុណ្ណឹង **ជ័យ** បញ្ជាក់ថា ពេលបងត្រឡប់ទៅវិញត្រូវមក ទាក់ទងគ្នាមួយសារទៀតនៅខែ៧-១៩៧៧ ដើម្បីនិយាយអំពីផែនការកំទេចបក្សនេះ ។ និយាយគ្នាហើយ ខ្ញុំក៏ត្រឡប់មកកន្លែង

វិញ ។ ពេលមកដល់កន្លែង ខ្ញុំបានទៅរាយការណ៍អោយ **វ៉ាំ ភួន** ដឹងនៅមន្ទីរ ក-១៦ ថានៅភូមិភាគឧត្តរ ឥឡូវឈ្មោះ **ស្រេង** ត្រូវអង្គការ ចាប់ហើយ ។

**ធាន:** អ៊ីដែលស្គាល់ឈ្មោះ **ស្រេង** ទេ?

**សារ៉ាត:** (អត់ អត់ស្គាល់) អង្គការចាប់ហើយ អ្នកដែលបន្តសកម្មភាពនៅភូមិភាគឧត្តរ ឥឡូវនេះគឺ មានឈ្មោះ **ជ័យ** ប្រធានពាណិជ្ជកម្ម ។ **វ៉ាំ ភួន** សួរខ្ញុំថា ពួក **ជ័យ** គេទាក់ទងខ្សែទៅខាងណា? ខ្ញុំឆ្លើយថា **ជ័យ** មានការទាក់ទងទៅខាងសៀម (ខាងថៃ) ខាងសៀម ព្រោះគេមានខ្សែទាក់ទងចាស់ពីមុនមក គឺខ្សែចាស់របស់ឈ្មោះ**ស្រេង** ចំពោះខ្សែទៅណា សៀមនេះឈ្មោះ គេអត់ប្រាប់ខ្ញុំទេ ។ **វ៉ាំ ភួន** សួរបញ្ជាក់ខ្ញុំថា ក្នុងការទាក់ទងនេះមិត្ត **ជ័យ** គេមានកំឡាំងច្រើនទេ ហើយផែនការរបស់គេបំរុងធ្វើយ៉ាងម៉េចខ្លះ? ខ្ញុំឆ្លើយថា ផែនការខាងគេគឺលើកកំទេចបក្សកុម្មុយនិស្តនៅខែ៨ ឬ ខែ៩-៧៧នេះ ។ ឯ**ជ័យ** ក៏គេ សួរកម្លាំងរបស់យើងដែរ ដើម្បីរួមជាមួយគេ តែខ្ញុំថាកំឡាំងរបស់យើងតិចពេក ចូលរួមមិនបាន **ជ័យ** ក៏គេថា អោយយើងធ្វើខាងនេះចុះ ផែនការខាងគេចាំគេធ្វើក៏បានតែដល់ ថ្ងៃ២៥-៧-១៩៧៧ មិត្ត **ជ័យ** អោយខ្ញុំទៅជួបជាមួយគាត់ទៀតដើម្បីក្តាប់សភាពផែនការនេះ**វ៉ាំ ភួន** ឆ្លើយថា អ៊ីទៅចុះដើម្បីក្តាប់សភាព-ការណ៍យកមករៀបចំធ្វើនៅកន្លែងយើង ។ ក្រោយពីជួប **វ៉ាំ ភួន** ហើយដល់ខែ៧-៧៧ខ្ញុំមកជួប **ជ័យ** ទៀត តែមិនជួបមិនដឹង **ជ័យ** ទៅឯ ណា ខ្ញុំក៏ត្រឡប់មកកន្លែងវិញ ការទាក់ទងជាមួយ **ជ័យ** នេះត្រូវដាច់ត្អារហូត ថ្ងៃ១៥-៩- ៧៧ មិត្ត **វ៉ាំ ភួន** បានសរសេរសំបុត្រផ្ញើតាមឈ្មោះ **អន់ គយ** ។

**ធាន:** ស្គាល់ទេ?

**សារ៉ាត:** (អត់ស្គាល់ទេ) **អន់ គយ** ដើម្បីឲ្យខ្ញុំ ។

**ធាន:** **អន់ គយ** ។

**សារ៉ាត:** ដើម្បីអោយខ្ញុំចូលរួមប្រជុំនៅមន្ទីរ ក-១៦ (អូ អន់ គយ អាអ្នកបើកឡានណឹងហើយមើលទៅ) ។

**ធាន:** អ៊ីស្គាល់ទេ?

**សារ៉ាត:** (ស្គាល់កាលណឹងវានៅខាងពាណិជ្ជកម្ម) ចូលរួមប្រជុំនៅមន្ទីរក-១៦ ការប្រជុំនៅថ្ងៃ១៨-៩-១៩៧៧ អ្នកចូលរួមប្រជុំមានឈ្មោះ :

១. **ស៊ុន ជន** ប្រធានពាណិជ្ជកម្ម តំបន់១០៥ ។

២. ថា ។

**ឆាន:** ណើនធ្លាប់ស្គាល់ទេ?

**សារ៉ាត:** (បាទ ស្គាល់)

២. **ថា** (ឡាវ) សមាជិកពាណិជ្ជកម្មតំបន់១០៥

៣. **ឡាប់** (ឡាវ) ប្រពន្ធ **ខាំ ភូន** (ត្រូវ ហើយ)

៤. **នូ** (ឡាវ) ប្រធានអ្នកទេសាទ (ត្រូវហើយ)

**ឆាន:** នៅកន្លែងណា?

**សារ៉ាត:** (នៅកន្លែងដំរីដាច់ខ្លួនមកនៅស្រែជ្រៃ) ប្រធានទេសាទត្រីនៅទន្លេស្រែកពករបស់ពាណិជ្ជកម្ម តំបន់ ១០៥ ។

៥. **សុដាន**

**ចារ៉ា:** **សុដាន** ហៅ **ចក់** ស្គាល់ទេ? ប្រពន្ធឈ្មោះ **នូ**?

**សារ៉ាត:** (អូ ប្រពន្ធ **នូ** នេះខ្ញុំភ្លេចឈ្មោះគាត់មុននេះ **សុដាន**) ។

**ចារ៉ា:** **នូ** ណា?

**សារ៉ាត:** (**នូ** នៅស្រែជ្រៃ) ។

**ចារ៉ា:** នៅស្រែជ្រៃ?

**សារ៉ាត:** បាទ ពួកសមាហរណកម្ម ។

**ចារ៉ា:** ណើន?

**សារ៉ាត:** បាទ!

**ចារ៉ា:** ក្រែងឈ្មោះ ខុសគ្នាទេអី **នូ** ផ្សេងទេ?

**សារ៉ាត:** អត់តែ ប្រពន្ធគាត់ **សុដាន** ពីមុនឈ្មោះយាយនេះណានៅផ្ទះបង **ស៊ីនួន** ខ្ញុំភ្លេចប្រពន្ធ ឈ្មោះ **នូ** ប្រធានមន្ទីរទេសាទនៅទន្លេស្រែពក

៦. នីក (ប្រធានភូមិកោះម្រើលយើងឥឡូវនេះ)

**ចារ៉ា:** ឥឡូវណើន?

**សារ៉ាត:** បាទ

**ចារ៉ា:** នីក ណើន ប្រធានភូមិកោះម្រើល ?

**សារ៉ាត:** ឥឡូវណា ។

**ចារ៉ា:** បាទ ឥឡូវណើន?

សារ៉ាត: បាទ

ហ៊ា: គាត់ជនជាតិក្នុងត្រូវទេ?

សារ៉ាត: ក្នុង ត្រូវប្រធានមន្ទីរ ក-១៦

ហ៊ា: ពីមុន ?

សារ៉ាត: បាទ

៧. ចន្ទ្រី ក្នុង សមាជិកគណៈមន្ទីរ ក-១៦ (ឥឡូវគេថានៅ កែវ ស៊ីម៉ា)

៨. ផន ខ្មែរ ប្រធានយុទ្ធនារី នៅមន្ទីរ ក-១៦ (អូ ផន ឥឡូវគាត់នៅខេត្តណឹង) ។

ហ៊ា: នៅខេត្ត?

សារ៉ាត: មានស្គាល់ដែរ ផន ហ្នឹង? គាត់ធ្វើខាងគ្រូ ផន គុណគា ស្រី

សារ៉ាត: ណឹងហើយ (សើច) ប៉ុន្តែ ខ្ញុំដឹង គាត់នៅជាមួយគ្នា យុទ្ធនារីនោះត្រូវហើយ នៅមន្ទីរ ក-១៦

៩. បាន់ (អូ បាន់ ទំពួន ត្រូវហើយ ស្លាប់ហើយ) ។

ហ៊ា: ស្លាប់ហើយ?

សារ៉ាត: (បាទ ស្លាប់មកពីព្រៃ ទៅស្លាប់នៅទីណា) ទទួលខុសត្រូវផ្នែកស្រែ ក-១៦ (ត្រូវ)

១០. ប្រពន្ធឈ្មោះ នីក ខ្ញុំមិនចាំឈ្មោះទេ នាទីមេក្រុមនារី (អូ គានីក) ។

ហ៊ា: ប្រពន្ធគាត់?

សារ៉ាត: ណឹងហើយ ។

ហ៊ា: ឈ្មោះអី? បើតាមអំដឹងឈ្មោះអី ប្រពន្ធ នីក ?

សារ៉ាត: ខ្ញុំអត់ដឹងដែរ (និយាយភាសាជនជាតិ) នៅក្នុងមន្ទីរ ក-១៦ ក្នុង

១១. សង អនុប្រធានមន្ទីរ ក-៣៧ ជនជាតិលាវ(ត្រង់ណា ក-៣៧ ?)

១២. **សួន** ប្រធានដឹកជញ្ជូន (អូ នៅស្រែជ្រៃ) របស់ពាណិជ្ជកម្ម តំបន់១០៥ ក្នុង

១៣. ហន គណៈមន្ទីរ ក-១៦ ជនជាតិចារាយ

ហ៊ា: ស្គាល់ទេអ៊ំ ហន?

សារ៉ាត: ស្គាល់

ហ៊ា: នៅរស់ទេ ហន? នៅឯណា?

សារ៉ាត: ឥឡូវមិនដឹងនៅឯណា ទៅរតនគិរីវិញហើយ មិនដឹង ឬ មួយក៏យ៉ាងម៉េច ឬក៏នៅអន្លង់ ។

ចាក់: នៅអន្ទ្រង?

សារ៉ាត: កាលមុនគេដកទៅអន្ទ្រង ។

ចាក់: អន្ទ្រងស្ថិតនៅភូមិណា ឃុំណា?

សារ៉ាត: នៅព្រំដែនក្រចេះ មណ្ឌលគិរីយើងណឹង ។

១៤. ខាំ ភី ជនជាតិទំពួន ប្រធានមន្ទីរ ក-៣៧ នៅរ៉យ

ចាក់: នៅរ៉យ?

សារ៉ាត: បាទ

ចាក់: មន្ទីររបស់អ្នកណាគេ?

សារ៉ាត: មន្ទីរ ស៊ុន ថន

ចាក់: ស៊ុន ថន ប្រធាន? ស៊ុន ថន ប្រធានមន្ទីរក-៣៧?

សារ៉ាត: ស៊ុន ថន គេប្រធានពាណិជ្ជកម្ម

១៥. ញ៉ន (ភ្នង) អនុកស្តុភារតំបន់១០៥ (ត្រូវហើយ)

១៦. កង (ឡាវ) ប្រធានបច្ចេកទេសខាងសិប្បកម្ម (អូ អាណឹងបងខ្ញុំតើ)

ចាក់: កង ហ្នឹង?

សារ៉ាត: បាទ

ចាក់: មែន កង មួយទៀតទេអញ្ចឹង?

សារ៉ាត: មែន ក្រុងក្រចេះទេ គាត់ធ្វើខាងសិប្បកម្ម ធ្វើរហាត់ក្បាល់រវៃ ធ្វេញឈើអីណឹង គាត់អ្នកបច្ចេកទេសធ្វើណឹង ។

ចាក់: បងរបស់អ៊ឹ?

សារ៉ាត: បាទ! បងបង្កើត

ចាក់: ឥឡូវ?

សារ៉ាត: ស្លាប់ហើយ ។

ចាក់: ស្លាប់នៅឯណា?

សារ៉ាត: ស្លាប់នៅស្រែសង្គម ។

ចាក់: ស្លាប់នៅជំនាន់ណា?

សារ៉ាត: ជំនាន់ណឹង

**ចៅរ៉ា:** ដំនាន់ឥឡូវណឹង?

**សារ៉ាត:** បាទ កាលកៅប៉ុន្មាន កៅបួយ ៩៣, ៩៤ ទៅ ។

១៧. ខ្ញុំឈ្មោះ ទូន មិត្ត **ខាំ ភូន** និយាយនៅពេលប្រជុំនោះថា ការប្រជុំនេះ យើងប្រជុំខ្សែរយៈរបស់យើងទាំងអស់ ផែនការដែលខ្ញុំលើកឡើងនៅពេលនេះ គឺស្នើមិត្តទាំងអស់រៀបចំអាវុធ នៅតាមកន្លែងរបស់មិត្តរៀងៗខ្លួន យកមកទុកនៅកន្លែងខ្ញុំនៅមន្ទីរ ក-១៦ ព្រោះមិត្តទាំងអស់សុទ្ធតែមានអាវុធ នៅតាមកន្លែងស្រាប់ ។ កាំភ្លើងនេះពេលប្រមូលបានហើយ ចាំខ្ញុំចាត់ចែងឈ្មោះ ដែង ជានិរសាររបស់ខ្ញុំ ជាអ្នកការពារក្នុងការប្រមូលអាវុធនេះ គឺខ្ញុំ សំរាប់មិត្តអោយដឹងថា យើងមានផែនការរត់ទៅប្រទេសយួន ព្រោះសភាពការណ៍បដិវត្តកម្ពុជា បច្ចុប្បន្នមានការតឹងតែងណាស់ សំខាន់ធ្វើការគ្មានពេលឈប់ឈរ **ខាំ ភូន** និយាយទៀតថា ផែនការរត់នេះ ខ្ញុំសំរេចអោយឈ្មោះមិត្ត ញ៉ុន និង ប៊ុន ឡឿន, ឡាង, ឡាំ ដឹកនាំកំឡាំង ១២នាក់ទៀត រត់ទៅដីយួន ព្រោះ ៥នាក់នេះ ដើងចាស់អាចម្ចាស់ការបានលើភូមិសាស្ត្រតាមផ្លូវរត់ គឺព្រៃ និងភ្នំធំៗ ផ្លូវដែលរត់ទៅដីយួន និងខ្សែសំរាប់ទាក់ទងនៅតាមផ្លូវគឺ រត់តាមផ្លូវភូមិស្រែព្រះ ឃុំស្រែព្រះ ក្នុងស្រុកកែវសីម៉ា ដើរតាមផ្លូវនេះមានបងរបស់ ញ៉ុន ឈ្មោះ **សារុន** ។

**ចៅរ៉ា:** អញ្ចឹង **សារុន** ដែលអ៊ីនិយាយណឹង?

**សារ៉ាត:** (អត់ទេ មិនមែនទេ **សារុន** ផ្សេង) **សារុន** ប្រធានមន្ទីរស្រុកកែវសីម៉ា (ខ្ញុំអត់ដឹងទេ **សារុន**នេះ) ជាខ្សែរយៈសំរាប់ ទាក់ទងចូលទៅប្រទេសយួន ។ កំឡាំងដែលត្រូវរត់ជាមួយ ៥នាក់នេះ គឺឈ្មោះ ហល, វ៉ុន, ដេត, ឃនយុទ្ធជន, ផហ៊ូ ចំនួន ៧នាក់ទៀត ខ្ញុំភ្លេចឈ្មោះទៅ ។ ហើយ ពេលរត់ ទៅនេះខ្ញុំ ភូន បញ្ជាក់ថា (បែប **ខាំ ភូន**) ណឹងហើយ បញ្ជាក់ថា រត់ចេញពីតំបន់១០៥ ផ្លូវចុះទៅក្រចេះ ហើយមានផ្លូវបំបែកទៅដល់ស្រុកកែវសីម៉ា ប្រហែល ៥គីឡូ រយៈពេល ដែលត្រូវរត់ គឺខ្ញុំដាក់ទិសអោយមិត្ត ញ៉ុន និង៤នាក់ទៀត រត់ទៅ ៣ថ្ងៃ អោយបានចូល ទៅដល់ដីយួន ពេលណាទៅដល់ដីយួន ទៅចូលទាក់ទងជាមួយយួន ឈ្មោះ បាគង់ លេខា តំបន់លោក និញ ត្រាយនិញ បើជួបហើយត្រូវរាយការណ៍អោយ បាគង់ ដឹងថា កំ ឡាំងរបស់យើងដែលរត់មកនេះចំនួន ១៧នាក់ និងអាវុធ ១៩ដើម ។ ឯផែនការ និងសភាព ការណ៍នៅកម្ពុជាក៏ត្រូវរាយការណ៍អោយយួន ដឹងដែរ គឺរាយការណ៍ថា នៅចំផ្លូវលេខ១៤ មានកំឡាំងទ័ពតំបន់លេខ ៥០៥ នៅការពារជាប់ដីយួនតែម្តង ចំណែកកងពល ៩២០ នៅតាម ផ្លូវនេះដែរ តែនៅចូលទៅក្នុងដីកម្ពុជាបន្តិចទៅ ហើយ ក្រៅពីនេះក៏ត្រូវរាយការណ៍អោយ យួនដឹងពីកន្លែងដែលកងទ័ពកម្ពុជាមុន ។

**សារ៉ាត:** បន្ទាយបារាំងឈ្មោះកោះធាយប្រាខេ តាមផ្លូវចន្លោះស្រុកស្នួលនិងស្រុកកែវស៊ីម៉ា ។

**ចារ៉ា:** ត្រូវទេអី ?

**សារ៉ាត:** (បាទត្រូវហើយ) ពេលរាយការណ៏ហើយត្រូវអោយយួនវាយចូលមកយកដីកម្ពុជាតាមផ្លូវ ២ ដែលខ្ញុំប្រាប់ខាងលើ ។ បើវាយទ័ពកម្ពុជាបានខ្លះហើយ យើងទាំងអស់គ្នាត្រូវបំផុសប្រជាជននៅស្រុកកែវស៊ីម៉ាអោយរត់ចូលដីយួន ហើយបើទ័ពយួនវាយចូលមកដល់ណាមិត្ត **ញ៉ុន**ត្រូវមករាយការណ៏អោយខ្ញុំដឹងផងដើម្បីខ្ញុំនឹង រៀបកំឡាំងរបស់យើងដែលនៅទីនោះអោយរត់ទៅជាមួយ ។ ចំពោះទិសកំណត់ដែលយើងត្រូវ សុំសំណូមពរអោយគេវាយចូលមកដីកម្ពុជាឲ្យស្របតាមការបំផុសពីខាងក្នុងនេះ គឺវាយនៅក្នុងខែ ១០ឬ ១១ ឆ្នាំ ១៩៧៧ ខាងមុខនេះបន្ទាប់ពីលើកផែនការសំរាប់ទាក់ទងយួនហើយមិត្ត**ខាំ ភួន** គាត់ក៏បានលើបញ្ជាក់អំពីយុទ្ធវិធីមុនពេលរត់ទៅវិញថា ពេលដែលត្រូវមិត្ត **ញ៉ុន**ឯង **ឡាំ** មិត្តយើងរត់ទៅនេះ គឺនៅក្នុងថ្ងៃ ២២.០៩.១៩៧៧ មុនពេលរត់ទៅ**ញ៉ុន**ឯងត្រូវអោយមិត្ត**ប៊ុន**និងមិត្ត**ផវ ហ៊ួ**បើកឡានអាកាត់ៗ ចិន(ត្រូវហើយ) ។

**ចារ៉ា:** ត្រូវដែរអី ?

**សារ៉ាត:** បាទ

**ចារ៉ា:** ជំនាន់ហ្នឹងប្រើតែឡានកាត់ៗចិនហ៎ ?

**សារ៉ាត:** (បាទ កាត់ៗចិន១គ្រឿងទៅ អាណឹងទៅជាប់ផុងកណ្តាលផ្លូវចោលដែរ ។)

**ចារ៉ា:** ជាប់នៅផុក ?

**សារ៉ាត:** (បាទ) នឹងសំបុត្រអនុញាតិមួយច្បាប់ថាទៅបើសំភារៈនៅពាណិជ្ជកម្មដើម្បីយកទៅចែកយោធាជាប្រញាប់ (មានមែន) ។

**ចារ៉ា:** ដាក់អីគេអី ?

**សារ៉ាត:** សំភារៈហ្នឹង ។

**ចារ៉ា:** អាពេលជាប់ផុង ជាប់ភុកហ្នឹង ?

**សារ៉ាត:** អាណឹងគេថាមានសំបុត្រអនុញាតិច្បាប់អោយទៅបើកសំភារៈឲ្យយោធាពាណិជកម្មដើម្បីយកទៅចែកយោធាជាប្រញាប់ (គេមានដាក់ទៅខ្លះដែរ) ។

**ចារ៉ា:** មានដាក់ ?

**សារ៉ាត:** (បាទមានកំភ្លេបាទ) ពេលនោះមិត្ត**ប៊ុន** ក៏ត្រូវឆ្មៀតចូលទៅកន្លែងខ្ញុំ ហើយខ្ញុំយកកាំភ្លើង ១៩ ដើមមកជាមួយផង ។ បើមានសភាពការណ៏មិនស្រួលទៅប្រាប់គេខាងអីខាំ **ភួន** ត្រូវការ

សំភារៈពិសេសនេះ សំរាប់ទៅធ្វើការនៅរតនៈគីរី ។ ឯកំឡាំងក្រៅពីមិត្ត **ប៊ុន** នេះមន្ទីរ ក១៦ គ្រប់ហើយ ដាច់ខាតត្រូវតែចេញតាមឡាន១គ្រឿងនេះ អោយផុតពីតំបន់ ១០៥ នៅម៉ោង ១២យប់ (ត្រូវហើយ) ។

**ចាំ:** មានឡានចេញមែនអី ?

**សារ៉ាត:** (បាទ ១២)យប់បើឡានត្រូវខូចកន្លែងណាចោលកន្លែងនោះចុះ (ត្រូវហើយ)ក្រោយពីប្រជុំដាក់ ផែនការហើយនៅថ្ងៃទី ២២ ខែ០៩ ឆ្នាំ១៩៧៧ មិត្ត**ឆាំ ភួន** បានមកប្រាប់ខ្ញុំនិងមិត្ត **ស៊ុន ៨ន** និងមិត្ត**ថា**ថាៈ នៅពេលយប់ម៉ោងប្រហែល ៧ ថ្ងៃនេះត្រូវហៅកំលាំងនៅក្នុងមន្ទីររបស់យើងទាំងអស់ត្រូវប្រជុំរួម ហើយនៅក្នុងការប្រជុំពន្យាពេលអោយបានយូរដើម្បីអោយមិត្ត **ទៀន ប៊ុន** ចូលមកយកកាំភ្លើងនៅកន្លែងខ្ញុំបានស្រួល ។ បើមិនធ្វើអញ្ចឹងទេច្បាស់ជាពួកនោះចូលយកកាំភ្លើងកន្លែងខ្ញុំមិនបានទេ ។

**ចាំ:** ត្រូវទេអី ?

**សារ៉ាត:** (បាទ ត្រូវហើយ) ចំណែកខាងក្រៅខ្ញុំអោយមិត្ត **វែង** យាមចាំក្តាប់សភាពការណ៍មនុស្សចេញចូលហើយ ។ ពេលទទួលការណែនាំហើយនៅម៉ោង ៧យប់ ថ្ងៃ ២២.០៩.១៩៧៧ ខ្ញុំនិង **ស៊ុន ៨ន, ថា, វ៉ុន,** ហៅកំឡាំងនៅក្នុងមន្ទីរក១៦ ប្រជុំទាំងអស់ក្នុងការប្រជុំនេះគឺលើកពីការងារ បដិវត្តន៏អោយតែគ្រប់ម៉ោង និងអាលពួក ១៧នេះប្រើពេលយកអាវុធបាន (ព្រោះពេលនោះផែនការគេដកអាវុធទាំងអស់) ។

**ចាំ:** អញ្ចឹង ?

**សារ៉ាត:** បាទ មិនថាកម្មាភិបាលមិនថាយុទ្ធជនអីទេ ប្រមូលដាក់ឃ្លាំងទាំងអស់ ។

**ចាំ:** ប្រមូលកាំភ្លើងដាក់ឃ្លាំងទាំងអស់ ?

**សារ៉ាត:** បាទ ព្រោះវាមានសភាពការណ៏ ។

**ចាំ:** សភាពការណ៏អីគេអី ?

**សារ៉ាត:** សភាពការណ៏អញ្ចឹងហើយណា ។

**ចាំ:** អាពេលថាក្បត់វាណឹង ? ចោទទៅវិញទៅមកណឹង ?

**សារ៉ាត:** បាទ ណឹងហើយចោទទៅវិញទៅមក ។

**ចាំ:** ចាប់គេដកអាវុធតែម្តង ? អ្នកណាចេញបញ្ជាអោយដកអាវុធដកអី ?

**សារ៉ាត:** ហម

**ចាំ:** ហម ?

**ចាន់:** ហម ?

**សារ៉ាន:** (បាទ ដកអាវុធទាំងអស់ប៉ុន្តែ **ខាំ ភួន** ប្រហែលគេមានអាវុធលាក់ទុកដើម្បីអោយកំឡាំងគេផ្សេងទៀតយក) (សើច)ដល់ម៉ោង ១១យប់ ឈ្មោះ **ដែង**បានកេះខ្ញុំឈ្មោះ **ប៊ុន** ឈ្មោះ **ស៊ុន ថន** និង ឈ្មោះ**ថា** ចេញពីក្នុងអង្គប្រជុំរួចចេញមកជួបគ្នានៅក្រៅ ។ **ដែក** និយាយប្រាប់ខ្ញុំថា អាវុធ ១៩ ដើមយកចេញទៅបាត់អស់ហើយ ឥឡូវយកអាវុធ១៩ ដើមដាក់ទូកឆ្លងទៅជិះឡានទៅថ្មល់ ជាតិហ្នឹងពេល ១៧ នាក់នេះចេញផុតទៅ ខ្ញុំក៏និយាយអង្គប្រជុំអោយមកកាន់កន្លែងណាវិញ អស់នៅម៉ោង ១២យប់ ។

**ចាន់:** ជិនាទ់ណឹងធ្វើតែយប់ៗតែម្តងអី ?

**សារ៉ាន:** (បាទ ប៉ុន្តែអានេះក៏អត់បានឃើញ) ខ្ញុំនិងមិត្ត**ខាំ ភួន** នារី **ឡាប់** ខ្ញុំបំផុសថា ឈ្មោះ **ញ៉ឹន** រត់ទៅចងករបាត់ទៅហើយ ស្នើអោយបងប្អូនទាំងអស់ជួយរកជង គង់តែគេដឹងថាបាត់ខ្លួន(គេស្នើរអីបើកឡានទៅទាំងដុលតែម្តង) (សើច) ។

**ចាន់:** បើកឡានទៅ ?

**សារ៉ាន:** (បើកឡានទៅតែម្តងទៅទាំងដុល) បាត់ខ្លួនដូច្នេះពួកខ្ញុំត្រូវតែបំផុសពាក្យនេះស្កាត់អោយ បានមុន ២ថ្ងៃ ក្រោយមកឮថាអង្គការចាប់បាននឹង បាញ់សាបអស់១៣នាក់ ដូចនេះកំឡាំង ដែលរត់ទៅដីយួនបានចំនួនតែ ៨នាក់ទេ ពួកនេះចេញទៅបាត់រហូតមិនដែលមកទាក់ទងឬ រាយការណ៍តាមរយៈអ្នកណាមកអោយដឹងដល់បច្ចុប្បន្នតែម្តង ។ ក្រោយពីសភាពការណ៍នេះកើតឡើងហើយ អង្គការបានចាត់តាំងវា ត្រូវជា**គុណ**របស់**ខាំ ភួន**ផ្ទាល់អោយដើររកចាប់ពួក ១៧នាក់ ដែលរត់ទៅស្រុកយួននោះ តែផែនការរបស់អង្គការឈ្មោះ**ខាំ** មិនបានអនុវត្តន៏ (ត្រូវ) ហើយក៏បែរធ្វើជាសកម្មភាពប្រឆាំងវិញ អង្គការក៏សំរេចចាប់**ខាំ** នៅខែ ១០.១៩៧៧ ដដែលបងឡាំងបានដកខ្ញុំចេញពីក្រចេះអោយទៅជួយស្តាប់សភាពការណ៍នៅពាណិជ្ជកម្ម ។ ពេលនោះខ្ញុំក៏បានជួបជាមួយឈ្មោះ **ស៊ុន ថន** និង **ខាំ ភួន** នៅមន្ទីរពាណិជ្ជកម្មនៅតំបន់១០៥ មិត្ត**ខាំ ភួន** ប្រាប់ខ្ញុំថា ឥឡូវខ្ញុំមិនបានដឹកនាំមិត្តប្រជុំដាក់ផែនការទេ ព្រោះតាមមើលអង្គការជិតដកខ្ញុំទៅភ្នំពេញដូច្នេះលើការដឹកនាំប្រជុំធ្វើសកម្មភាពស្រេចលើ(ទំព័រ១៨) **ស៊ុន ថន ជួន**ឯងទៅចុះ ខ្ញុំឆ្លើយថាបើអង្គការត្រូវការ ហើយមិត្តទៅចុះចាំខ្ញុំដឹកនាំប្រជុំសកម្មភាពប្រឆាំងបដិវត្តន៏បន្តទៅទៀត ។ **ខាំ ភួន**បន្តទៀតថា រឿងអង្គការបំរុងនឹងដកខ្ញុំនេះច្បាស់ជាចាប់ខ្ញុំហើយ ដោយរឿងយើងលើកមុនត្រូវបែកការណ៏ពេលណាចន្លោះល្អខ្ញុំ ច្បាស់ជាវៃបង**ឡាំ**ហើយ ។

**ចាន់:** បង**ឡាំង** ណឹង **ហម** ណឹង ?

**សារ៉ាត:** (ហ្នឹងហើយ **ហម**) ហ្នឹងច្បាស់ជាវៃបង**ឡាំង**ហើយ ព្រោះរឿង**គុណ**ខ្ញុំក៏មកពីគាត់ហើយរឿងយើង បែកការណ៍នេះក៏បែកការណ៍ពីបង**ឡាំង**ដែរ បើវាយបង**ឡាំង**បានរឿងយើងបែបជិតខ្ទះដែរ ។ ក្រោយពីពិភាក្សាគ្នាហើយដល់ថ្ងៃ ២៦.១០.៧៧ អង្គការបានយក**ទាំ ភួន** មកភ្នំពេញ ពេលមកដល់ភ្នំពេញ ខ្ញុំដឹងដំណឹងថា**ទាំ ភួន**វាយបង**ឡាំង**ស្លាប់នៅថ្ងៃ ២៦.១០ ១៩៧៧ នៅនឹង មន្ទីរពាណិជ្ជកម្មតំបន់ ១០៥ ប្រចាំនៅភ្នំពេញ ដល់ថ្ងៃ ២៣.១១.១៩៧៧ អង្គការចាប់ខ្ញុំមក ទីនេះតែម្តង ។

**ចារ៉ា:** នេះអ្នកសួរឈ្មោះ **ឡាត់** ?

**សារ៉ាត:** ធ្វើនៅថ្ងៃ ២៨.១១.១៩៧៧ អ្នកសួរឡាត់(ដឹងធ្វើស្អីឡាត់) អ្នកសារភាព**ដួន** (មានដិតមេដៃទៀតអស់ហើយ ) ។

**ចារ៉ា:** អានេះខាងក្រោយជាបញ្ជីស្រង់អ្នកដែលចូលរួម ។

**សារ៉ាត:** ១៩នាក់ ។

**ចារ៉ា:** ៣៧ នាក់ ?

**សារ៉ាត:** **កង** អនុប្រធានតំបន់ ៥០៥ ។

**ចារ៉ា:** **កង** ពូថានៅក្រចេះដែលថាអ៊ីស្គាល់ណឹង ?

**សារ៉ាត:** បាទ ខ្ញុំស្គាល់ ។

**ចារ៉ា:** ឥឡូវស្លាប់ឬនៅ ?

**សារ៉ាត:** គេថាស្លាប់ដែរ ប៉ុន្តែពូដឹងណឹងគេណា ។

**ចារ៉ា:** បាទ !

**សារ៉ាត:** **ទាំ ភួន** អនុលេខាតំបន់ ១០៥ (ស្លាប់) ប៉ុន្តែអានេះគេអត់ដាក់ស្លាប់ ។

**ចារ៉ា:** អត់ស្គាលទេ **ខន** ?

**សារ៉ាត:** បាទ **សៃ** ក៏អត់ស្គាល់ដែរ ។

**ចារ៉ា:** **ស៊ិន ថន** ?

**សារ៉ាត:** តំបន់ ៥០៥ **ស៊ិន ថន**ស្គាល់ប្រធានពាណិជ្ជកម្មតំបន់ ១០៥ ។

**ចារ៉ា:** ឥឡូវនៅរស់នៅទេ **ស៊ិន ថន** ?

**សារ៉ាត:** ស្លាប់ ។

**ចារ៉ា:** ស្លាប់ ?

**សារ៉ាត:** បាទ

**ហារ៉ា:** ផា ?

**សារ៉ាត:** ៦-**ផា** សមាជិកពាណិជ្ជកម្មតំបន់ ១០៥ស្លាប់ ។

៧-**វែង** យុទ្ធជនការពារ នៅរស់សព្វថ្ងៃនេះទេ នៅស្រែសង្គម ។

**ហារ៉ា:** នៅស្រែសង្គម ? ឈ្មោះ**វែង** ?

**សារ៉ាត:** បាទ! ៨-**វ៉ាន់** ទទួលខុសត្រូវខាងឡានមន្ទីរតំបន់ ១០៥ស្លាប់ហើយ ។

៩-**ស៊ី** យុទ្ធជនបើកឡាន (និយាយភាសាជនជាតិ) តំបន់ ១០៥ ។

១០- **ឡាប់** អនុប្រធានពាណិជ្ជកម្មតំបន់ ១០៥ ។

១១- **ទូ** ប្រធានគេសាទត្រីនៅទន្លេស្រែពក ពាណិជ្ជកម្មតំបន់ ១០៥ ។

១២- **ស៊ូដាន** ប្រពន្ធឈ្មោះ **ទូ** (សើច) ខ្ញុំភ្លេចឈ្មោះគាត់ទៅមិនដឹងមន្ទីរនេសាទពាណិជ្ជកម្មតំបន់ .....។

១៣- **ចាន់ដើ** សមាជិកគណៈមន្ទីរក១៦ (កាលមុនគាត់ធ្វើគណៈស្រុកកែវស៊ីម៉ា) ។

**ហារ៉ា:** នរណាគេអី ?

**សារ៉ាត:** **តាចាន់ដើ**

**ហារ៉ា:** ចាន់ដើរហ្នឹង ?

**សារ៉ាត:** បាទ (សើច) នៅគណៈមន្ទីរ

១៥- **ថន** ប្រធានយុទ្ធនារីនៅមន្ទីរ ក១៧ ។

**ហារ៉ា:** នៅរស់ដែរ ?

**សារ៉ាត:** នៅ

**ហារ៉ា:** នៅឯណា ?

**សារ៉ាត:** នៅពាណិជ្ជកម្មខេត្ត ។ ថាធ្វើគ្រូ ។

**ហារ៉ា:** នៅខេត្តតែម្តង ?

**សារ៉ាត:** បាទ នៅមណ្ឌលគីរី ។

**នាង:** ស្រីឬប្រុស **ថន**ហ្នឹង ?

**សារ៉ាត:** ស្រី

១៦-**តាន់** ទទួលខុសត្រូវផ្នែកស្រែ ក១៦ ។

១៧-ប្រពន្ធ ឈ្មោះ**និក** មិនចាំឈ្មោះ (និយាយឡាវ) ដល់ណាហើយមិញ ?

ឌាភ: ដល់ **សន** !

សារ៉ាត: ១៨- **សន** អនុប្រធានមន្ទីរក-៣៧ (និយាយឡាវ) (ប៉ុន្តែខ្ញុំអត់ច្បាស់ដែរ ខ្ញុំអត់ស្គាល់ដែរប្រហែលណឹងហើយ) ។

១៩- **សឿន** ប្រធានដឹកជញ្ជូនរបស់ពាណិជ្ជកម្មតំបន់ ១០៥ ។

ឌាភ: នៅជំរកខ្លែងធ្វើស្រែ ស្រែជ្រៃ ?

សារ៉ាត: ២០- **ហន** គណៈមន្ទីរក១៦ (ឥឡូវនៅអន្លង់ក្រួច?) (និយាយឡាវ) ។

ឌាភ: ទៅរតនៈគីរី នៅខេត្តប្ញ ?

សារ៉ាត: នៅជនបទ

២១- **ខាំភី** ប្រធានមន្ទីរក៣៧ (និយាយឡាវ) ។

ឌាភ: **ស៊ុន ថន** ឈ្មោះនៅហ្នឹងអី ?

សារ៉ាត: ណឹងហើយ ។

ឌាភ: នៅឯណា ក៣៧ ?

សារ៉ាត: នៅរយ៉ ស្រុកកោះញែក

២២-**កន** ប្រធានបច្ចេកទេសខាងសិប្បកម្មតំបន់ ១០៥ ។ (ត្រូវ)

២៣-**ធី** (និយាយឡាវ) ប្រធានមន្ទីរទទួលភ្ញៀវនៅភាគឧត្តរ កាលឃួន នៅ ។

២៤-**សែន** ពីមុនជានិរសារអគ្គការ ។

ឌាភ: ស្គាល់ទេសែន ?

សារ៉ាត: (អត់ស្គាល់ទេ ប៉ុន្តែរឿងព្រាវៗ មិនច្បាស់ទេ) កំឡាំងរត់ទៅឃួន

២៥-**ញ៉ុន** អនុកស្តុការយោធាតំបន់ ១០៥ ។

២៦-**នឿន** ប្រធានស្រែក១៦ ។

២៧-**ឡាន** ប្រធានចិញ្ចឹមគោក្របីនៅមន្ទីរក១៦ (សុទ្ធតែត្រូវទាំងអស់) ។

២៨-**ឡាំ** សមាជិកផ្នែកគោក្របីមន្ទីរក១៦ ។

២៩- **ប៊ុន** កងការពាររបស់**ខាំ ភួន** ។

ឌាភ: ងាប់ហើយ ?

សារ៉ាត: ងាប់ហើយៈ

៣០- **ហល** យុទ្ធជនម៉ាស៊ីនភ្លើងរបស់ពាណិជ្ជកម្មតំបន់ ១០៥ ។

៣១-**វ៉ុន** ជាអ្នកធ្វើអាគុយ ១០៥ ។

៣២-ដេត

ចាវ៉ា: នៅរស់ដែរអី ?

សារ៉ាត: នៅគោះម៉ើល យុទ្ធជនធ្វើបាយទឹក ។

ចាវ៉ា: អោយខាំ ភួន ?

សារ៉ាត: អោយខាំ ភួន

៣៣-ខន យុទ្ធជនកាត់ដេរ ពាណិជ្ជកម្មតំបន់ ១០៥ ។

ចាវ៉ា: ខន អត់ស្គាល់ទេ ?

សារ៉ាត: អត់ស្គាល់ទេ

៣៤-ផហ៊ួ យុទ្ធជនបើកឡាន ពាណិជ្ជកម្មគេយកទៅវៃចោល ។

ចាវ៉ា: គេយកទៅវៃចោលដែរ ?

សារ៉ាត: ៣៥-ជ័យ ប្រធានពាណិជ្ជកម្មភាគឧត្តរ ។

៣៦-អ៊ី អនុប្រធានជ័យ ចាត់ការនៅពាណិជ្ជកម្ម (អត់ស្គាល់ទេ ) ។

៣៧-ឃួន ប្រធានពាណិជ្ជកម្មរដ្ឋ បញ្ជាក់កំឡាំងនៅតំបន់ ១០៥ មិនច្បាស់ជាចាប់ឬនៅទេ អស់ហើយ ។

ចាវ៉ា: អស់ត្រឹមណឹងអី...អ្នកមានឯកសារនេះមានឈ្មោះអីហ្នឹងមែនឬក៏អត់ទេនេះ ?

សារ៉ាត: ឈ្មោះខ្ញុំ ?

ចាវ៉ា: នេះដែលគេស្រង់ចុងក្រោយ ? នេះ សារ៉ាត លាវពីមុនអគ្គការចាប់មុនអគ្គការចាប់ប្រធានក្រុមពេទ្យរបស់មន្ទីរក១៧ តំបន់ ១០៥ សារ៉ាត ហ្នឹងអី ឬមិនមែន ?

សារ៉ាត: បាទ ។

ចាវ៉ា: អញ្ចឹង ? មានទាក់ទងប្រវត្តិជាមួយឈ្មោះស៊ុំ ខាំភួន ។

សារ៉ាត: ស៊ុំ ខាំភួន ?

ចាវ៉ា: បាទ! ប្រហែលជាមាននៅក្នុងចំលើយណឹងបានគេស្រង់ឈ្មោះមនុស្សដែលគេស្រង់សុទ្ធតែគេធ្លាប់ទាក់ទងជាមួយអឹងអញ្ចឹងទៅណានិយាយ ?

សារ៉ាត: វាមិនសូវប៉ុន្មានទេអាណឹងនោះ ។

ចាវ៉ា: អញ្ចឹង ?

សារ៉ាត: ខាំ ភួនមុនអគ្គការចាប់ប្រធានមន្ទីរក១៧ របស់តំបន់ ១០៥ត្រូវហើយដេត ក្នុង ។

**ចាន់:** ដេតយ៉ាងម៉េច ?

**សារ៉ាត:** បាទ ជិតមិញក្នុង អាដេតធ្មើស្រែអតីតធ្មើស្រែបច្ចុប្បន្នប្រធានក្រុមមន្ទីរ ក១៧ ។ អំពីកំលាំងក្បត់ស្រង់ចេញពីប្រវត្តិកក **យឹម** ។

១-**យ៉េត**អតីតជំទប់ជាប្រធានភូមិស្រែធំឃុំ ស្រែធំស្រុកច្បារតំបន់ ១០៥ ។

**ចាន់:** អាណឹងស្គាល់ទេអំ ?

**សារ៉ាត:** អត់ស្គាល់ទេ

២-**មិ** មេឃុំជាប្រធានឃុំស្រែធំងាប់ អង្គការកំទេច(អត់ស្គាល់ដែរ) ។

៣- **ប្រជ្រើយក្រេប** អតីតស្មៀនឃុំជាសមាជិកឃុំស្រែធំងាប់អង្គការកំទេច ។

៤- **ពកៀនសិទ្ធ** ក្នុងនៅភូមិស្រែធំអង្គការកំទេចហើយ ។

**ចាន់:** អំហេតុអ្វីបានស្រែធំសំលាប់ច្រើន ? ស្រែធំហ្នឹងវាទាក់ទងយ៉ាងម៉េចបានជាមួយពួកណុង ?

**សារ៉ាត:** ពួកណុងទាក់ទងជាមួយរដ្ឋការចាស់ (សើច) ។

**ចាន់:** ភាគច្រើន ?

**សារ៉ាត:** (និយាយឡាវ) ៥- **ឡុង យឹម** ខ្មែរនៅភូមិស្រែធំ អង្គការកំទេចហើយ ។

៦- **គាល** ក្នុងឈ្លបសហករណ៏នៅឃុំស្រែធំ ងាប់ឆ្នាំ ១៩៧៦ ។

៧- **ញ៉ុង** នៅសហករណ៏មន្ទីរ អូបញ្ញែ ៧៧ងាប់ ។

៨- **គ្អើញ** ក្នុង អតីតមេភូមិ បច្ចុប្បន្នប្រជាជនសហករណ៏មិគ ឃុំស្រែធំ ស្រុកច្បារ ។

១០- **ឡុងឈាម** ខ្មែរ ។

**ចាន់:** ខ្មែងទុកអាហ្នឹងធ្មើអីទេ ?

**សារ៉ាត:** អ្នកភូមិសេរីកា ភូមិសេរីការឃុំខ្នាច ស្រុកក្រចេះតំបន់ក្រចេះ បច្ចុប្បន្នក្លាប់មិនបាន ។

១១- **ជិន** ខ្មែរ បច្ចុប្បន្ន មេក្រុមសហករណ៏ឃុំស្រែធំ ស្រុកច្បារតំបន់ ១០៥ ។

១២- **យ៉ុន** ក្នុងអត់ដឹង ។

១៣- **ទឹក** ក្នុងតំបន់សហករណ៏ញីញែ ឃុំស្រែធំស្រុកច្បារ ។

១៤- **ស្រ៊ុន**

១៥- **អន់ ណយ** កាន់កុមារនៅសហករណ៏ឃុំស្រែធំ ។

១៦- **វង់ វ៉ន** ចៅហ្វាយស្រុកច្បារ ខេត្តមណ្ឌលគិរី **វង់ វ៉ន**ហ្នឹងមេទ័ពក្លាប់ម៉ាប៉ាត់តា-**យ៉ុង**នៅកោះញែក ។

**ចាន់:** ស្លាប់ឬ នៅ ?

**សារ៉ាត:** ស្លាប់ហើយ បើថា**មើយភួន** នៅស្រុកច្បារ កាលមុនមើល**ឃួនសក្តិ** ៣ ក្តាប់ស្រុកច្បារកាល ៧០ ។

១៧- **ស៊ិន** កូនកាត់ខ្មែរក្នុង អតីតទាហាន ៨ឆ្នាំជាឈ្លបសេដ្ឋកិច្ច ឃុំស្រែធំឆ្នាំ ១៩៧៤ អង្គការដកយកទៅដាក់ឃុំអន្ទឹក ស្រុកក្តាប់មិនបាទបច្ចុប្បន្នមិនដឹង ។

១៨- **គ្រោង** ក្នុង ប៉ូលីស៥ ឆ្នាំ ដូច **ស៊ីន**ដែរ (អត់ស្គាល់ទេ) ។

**ចារ៉ា:** ង៉ុន នេះស្គាល់ទេ ?

**សារ៉ាត:** ៥ន ខ្មែរបច្ចុប្បន្នឈ្លបសហករណ៍ស្រែធំអត់ស្គាល់ទេ ។

**ចារ៉ា:** ចុះង៉ុន ?

**សារ៉ាត:** ៥ន ខ្មែរបច្ចុប្បន្នស្លាប់ សហករណ៍ស្រែធំស្រុកច្បារតំបន់១០៥ អូ! **ង៉ុន**ក្នុងប្រធានសហ-ករណ៍ ។

**ចារ៉ា:** នៅរស់ដែរ ?

**សារ៉ាត:** (គេថាស្លាប់បាត់ហើយ) នៅសហករណ៍ស្រែធំ, **ឈៀក** សមាជិកឃុំឈ្លប ។

**ចារ៉ា:** បេន ?

**សារ៉ាត:** **បេន** ខ្មែរប្រជាជនសហករណ៍ឃុំស្រែធំ ស្រុកច្បារតំបន់ ១០៥, **សារឹម** ខ្មែរដែរ អតីតគ្រូបង្រៀន បច្ចុប្បន្នដូច **បេន** ដែរ ។

**ចារ៉ា:** ឆ្នាំ ៧៣អង្គការកំទេចចោល ?

**សារ៉ាត:** កំទេចចោល ប៉ុន្តែមនច្បាស់ឈ្មោះគេ អូមិនច្បាស់មុខគេទេ **សុវណ្ណ** ។

**ចារ៉ា:** **សុវណ្ណ** ទាហានអាស៊ីដង់សែហ្ស ?

**សារ៉ាត:** (និយាយឡាវ) ។

**ចារ៉ា:** **ក្រាម** ក្នុងបច្ចុប្បន្ននៅក្រុម.......ស្រែធំ

**សារ៉ាត:** មេឃុំស្រែធំ កំទេចតែម្តង ។

**សារ៉ាត:** សហករណ៍**មី** ឃុំស្រែធំ ណង ខ្មែរ ។

**ចារ៉ា:** **លាង** ?

**សារ៉ាត:** **លាង** បច្ចុប្បន្ននៅសហករណ៍ឃុំយោអ៊ូន ១០៥ ។

**ចារ៉ា:** **សាត** ?

**សារ៉ាត:** **សាត** ខ្មែរបច្ចុប្បន្ននៅសហករណ៍ឃុំត្រាច ។

**ចារ៉ា:** អ្នកទាំងអស់នៅក្នុងចំលើយរបស់ **កក់ ឃីម** មើលនៅក្នុងចំលើយ ក្អេងអ៊ីនេះ ?

**សារ៉ាត:** ក្អេងអ៊ី ហុន ។

**ចារ៉ា:** ហន ?

**សារ៉ាត:** ហនប្រធានមន្ទីរសុខាភិបាល **ចន** ។

**ចារ៉ា:** **ចន** នៅខាងក្រោម ?

**សារ៉ាត:** បច្ចុប្បន្នយ៉ាងម៉េច ?

**ចារ៉ា:** បច្ចុប្បន្នចាប់ចងនិយាយបច្ចុប្បន្ននៅក្នុងសម័យប៉ុល ពតដែរ ?

**សារ៉ាត:** **ចន** សេដ្ឋកិច្ចច្បារនាទីមេក្រុម ។

**ចារ៉ា:** នៅរស់ទេចនហ្នឹង ?

**សារ៉ាត:** កំទេច វៃចោលហើយចនហ្នឹង(គេចាប់ដាក់ជាមួយយើងដែរចនហ្នឹង) មុនយើងបន្តិច (ចាប់មុនយើងប៉ុន្តែថា យកទៅដាក់កន្លែងយើងទេក្រោយមក) ណឹងហើយគេដាក់ឈ្មោះ...មន្ទីរតា**លេង** ។

**ចារ៉ា:** នៅភ្នំក្រោលណឹង ?

**សារ៉ាត:** បាទ នៅជិតគ្នាណឹង **គឹមឡាយ**, **គ្រើម** បច្ចុប្បន្នមេពួកយោធាស្រុកច្បារគឺង មេក្រុមយុទ្ធជន ស្រុកច្បារចាប់យើងបច្ចុប្បន្នប្រជាជនច្បារ ។

**ចារ៉ា:** **ទោយ** ធ្មើរអីនេះ យុទ្ធជនស្រុកច្បារ ?

**សារ៉ាត:** មែនទេ ។

**ចារ៉ា:** មែនទេអញ្ចឹង ?

**សារ៉ាត:** **ទោយ** ផ្សេងទេ ។

**សារ៉ាត:** **ពែរ** ស្រុកច្បារ ។

**ចារ៉ា:** យេង ?

**សារ៉ាត:** យេង ស្រុកច្បារដែរចាប់ **ឆើប** ។

**ចារ៉ា:** ឈើប ?

**សារ៉ាត:** ឈើប មេពួកស្រុកច្បារ ពេទ្យសង្គម ។

**ចារ៉ា:** មឿន ពេទ្យសង្គមរបស់ទាហាន ?

**សារ៉ាត:** មឿន (នរណាគេអត់ស្គាល់ទេ) ។

**ចារ៉ា:** **ភ័ត់ គិច** អ៊ំទៅ ?

**សារ៉ាត:** វ៉ាត់ប្រជាជន ។

**ចារ៉ា:** សហករណ៍**គុញ** ?

**សារ៉ាត:** ស្រុកច្បារ គុញ ស្រុកច្បារ ។

**ចារ៉ា:** ក្រគ់ ?

**សារ៉ាត:** ដាក់នៅការដ្ឋានតំបន់រំដោះ, **ជ្រែន** ។

**ចារ៉ា:** ជ្រែម ?

**សារ៉ាត:** មេពួកដាំបន្លែនៅសហករណ៍ គុញស្រុកច្បារ ។

**ចារ៉ា:** **វ៉ុង** ?

**សារ៉ាត:** វ៉ុង អតីតទាហានបច្ចុប្បន្នប្រជាជនស្រុកច្បារ ១០៥ **ឈួន បារាំង** ។

**ចារ៉ា:** ឈួន បារាំងបច្ចុប្បន្នដកទៅបរិស្ថានតំបន់ ១០៥ បរិស្ថាននៅកន្លែងណា តំបន់ ១០៥ ?

**តូច:** បរិស្ថានហ្នឹងគេដាក់តាំងពីកាលីករហូតមកដល់ពាមជីមៀតគេហៅឪពុកភាក់ តែឈ្មោះមិនដឹង ឈ្មោះអីអតីតទាហានបច្ចុប្បន្នដកទៅការដ្ឋាន ១០៥ **ចឺ**អតីតធ្វើជីវពល បច្ចុប្បន្ននៅសហ-ករណ៍កាអ៊ូន ស្រុកច្បារ **ដូវ** បច្ចុប្បន្នប្រធានក្រុមកុមារនៅសហករណ៍កាអ៊ូន ។

**ចារ៉ា:** ច្រូន ?

**សារ៉ាត:** អតីតទាហានបារាំងបច្ចុប្បន្ននៅការដ្ឋាន ១០៥ **ញែង**, អូតាញែង ។

**ចារ៉ា:** ប្រជាជន ?

**សារ៉ាត:** ប្រជាជនសហករណ៍ ស្រែធំ ស្រុកច្បារ (វ៉ាខុសត្រង់ណឹងទៀត), ជ្រើកប្រជាជនសហករណ៍ស្រែធំ បច្ចុប្បន្នចាប់ ។

**ចារ៉ា:** ឈន ?

**សារ៉ាត:** **ឈន**ដូចគ្នា ។

**ចារ៉ា:** ឈេត ?

**សារ៉ាត:** **ឈេត** បច្ចុប្បន្នអ្នកមើលគោនៅស្រែធំ ស្រុកច្បារ ១០៥, **ប្រាវ** អ្នកថែរក្សានគ័ល រនាស់, **គ្លើក** ប្រជាជនសហករណ៍ស្រែធំចាប់ ។

**ចារ៉ា:** គេង ?

**សារ៉ាត:** **គេង** ប្រជាជនសហករណ៍ចាប់ ។

**ចារ៉ា:** ម៉េចបានជាសំបូរចាប់ម្លេះ ?

**សារ៉ាត:** ម៉ារី បច្ចុប្បន្ននៅមន្ទីរស្រុកច្បារតំបន់ ១០៥ ។

**ឆារ៉ា:** គ្វីល, ម៉ារីស្គាល់ ?

**សារ៉ាត:** អត់ទេ អត់ដឹងខ្មែរ ដឹងឡាវអត់មានដាក់ ។

**ឆារ៉ា:** អត់ដាក់ជនជាតិ ?

**សារ៉ាត:** ឈ្មោះនេះប្រហែលភ្នង ។

**ឆារ៉ា:** ពីលីល ?

**សារ៉ាត:** ញ៉ាវ បច្ចុប្បន្នសេដ្ឋកិច្ចមើលគោនៅសហករណ៏ត្រាច ស្រុកច្បារ ។

**ឆារ៉ា:** ផុន ?

**សារ៉ាត:** ផុន នៅរោងជាងធ្វើដាល ។

**ឆារ៉ា:** ស្គាល់អ៊ំទេ ?

**សារ៉ាត:** អត់ស្គាល់ទេ ។

**ឆារ៉ា:** ជួយយុទ្ធជនយោធាស្រុកច្បារពុក ?

**សារ៉ាត:** ពុក មេពួកសេដ្ឋកិច្ចសហករណ៏ត្រាច ស្រុកច្បារ ។

**ឆារ៉ា:** ដើម ?

**សារ៉ាត:** ដើម អតីតទាហានបីនាក់នៅក្នុងសហករណ៏ ។

**ឆាន:** និយាយមែនទែនអាណឹងថា យោធាបំរុង កន្លែងណាដែលប្រុងវៃគ្នាខ្លាំងគេយកទៅសាប់តែម្តង ពួកហ្នឹង ?

**សារ៉ាត:** ណឹងហើយ ។

**ឆារ៉ា:** ជឿន ?

**សារ៉ាត:** ជឿន អតីតសិស្សបច្ចុប្បន្ន ស្រុកច្បារ ។

**ឆារ៉ា:** សុផាន់ ?

**សារ៉ាត:** សុភាន់ បច្ចុប្បន្ន

**ឆារ៉ា:** ឡើងទៅយោធាតំបន់ ១០៥ វរសេនាតូចទី ១, មុំ ?

**សារ៉ាត:** មុំ ។

**ឆាន:** មុំបច្ចុប្បន្នយោធាតំបន់ ១០៥ ?

**ឆារ៉ា:** យ៉ន ?

**សារ៉ាត:** **យ៉ន** យុទ្ធជនយោធាស្រុកច្បារ ។

**ចារ៉ា:** អត់ស្គាល់ទេណ៎ ពួកហ្នឹង ?

**សារ៉ាត:** អត់ទេ អត់ស្គាល់ទេ ។

**ចារ៉ា:** សុទ្ធតែជនជាតិ ?

**សារ៉ាត:** សុទ្ធតែជនជាតិ អ្នកសារភាពហត្ថលេខា**ក្លង អ៊ី** ជីងជនជាតិអី ក្លង អ៊ី ។

**ឆាន:** ចប់ត្រឹមតែប៉ុណ្ណេះ?

**សារ៉ាត:** ចប់ (សើច) ។

**ចារ៉ា:** **ក្លង អ៊ី**ជាក្លង ? ចំលើយរបស់អ្វី ? **ដាន ឈាន, ឡាយ ក្លីងឡាយ ក្លីង** ណឹងប្រហែលជាខ្មែរ តែដាក់ក្លង(និយាយឡាវ) ?

**សារ៉ាត:** (និយាយឡាវ) ។

**ចារ៉ា:** នៅក្នុងចំលើយឡាយ ក្លីងមានឈ្មោះប្រហែលជាអាចស្គាល់ ?

**សារ៉ាត:** គាពងឈ្មោះដែលពាក់ពន្ធ័ក្នុងប្រវត្តិ**ឡាយ ក្លីង, ជីន** យុទ្ធនារីនៅសិល្បៈស្រុកតំបន់ ១០៥ ។

**ចារ៉ា:** មានឈ្មោះ**ជីន** ទេមីង ?

មីង: (និយាយឡាវ) ។

**សារ៉ាត:** (និយាយឡាវ) ។

**ចារ៉ា:** **សៀវ** ?

**សារ៉ាត:** **សៀវ** ។

**ចារ៉ា:** គណៈដឹកនាំសិល្បៈ ១០៥ចាប់ ?

**សារ៉ាត:** **ផែង អនុម, អោក** ។

**ចារ៉ា:** **អោក** ?

**សារ៉ាត:** មេក្រុមសិល្បៈ ។

**ចារ៉ា:** សុទ្ធតែចាប់ ?

**សារ៉ាត:** **ហ៊ូ** អនុ, **ណា** យុទ្ធនារី ក-១១, **ស៊ិន** ប្រជាជនមន្ទីរក-២១ ចាប់**សារិន** តំបន់ ១០៥, **សារិន** ពាណិជ្ជកម្ម, **វុន** យុទ្ធជន ដែលគ្នាមិនដឹង ។

**ចារ៉ា:** **ឌឿន, វឿ** ?

**សារ៉ាត:** **ខឿន** យុទ្ធជន ៧៥ ដកទៅមន្ទីរស្រុកច្បារ, **ឡាង** ប្រុសមេក្រុមនៅមន្ទីរ ក-៣៧ (និយាយឡាវ), **ឡាំ** អនុក្រុម, **សុខន** បច្ចុប្បន្នយុទ្ធជនមន្ទីរក-៣៧ដែរ, **ខឿន** (និយាយឡាវ) ។

**ចាក់:** នៅរស់ទេ ?

**តូច:** ទៅតាំងពី ៧៩ ។

ដាក់: **វុធ** ?

**សារ៉ាត:** ចាប់ ។

**ចាក់:** **រិន** ?

**សារ៉ាត:** **រិន** ចាប់ ។

**ចាក់:** **គីម, ហួរ** ។

**សារ៉ាត:** ហួរប្រធានកាត់ដេរ ។

**ចាក់:** កាត់ដេរមន្ទីរក-១៦ ?

**សារ៉ាត:** អូ! នៅរស់ ។

**ចាក់:** នៅរស់ដែរ ?

**សារ៉ាត:** មន្ទីរក-១៦នៅ...

**ចាក់:** នៅឯណាឥឡូវ ?

**សារ៉ាត:** ចាំមួយស្រុករបស់ខ្ញុំ ។

**ចាក់:** នៅស្រែសង្គម ?

**សារ៉ាត:** បាទ!

**ចាក់:** **ហួរ** ហ្នឹង ?

**សារ៉ាត:** បាទ !

**តូច:** គាត់ហ្នឹងរស់នៅជាមួយតា **ទាំ ភូន** ។

**សារ៉ាត:** ប្រធានកាត់ដេរមន្ទីរ ក-១៦ ពួរត់បាត់ ។ (រត់បាត់អី នៅស្រែសង្គម)

**ចាក់:** កាលពីជំនាន់ណឹងរត់បាត់ រួចទៅ បានទៅនៅស្រែសង្គម ?

**សារ៉ាត:** អាណឹងអត់រត់ទេ ។

**ចាក់:** អត់ទេ រឿងរត់បាត់ណឹងពេលគេចាប់ឈ្មោះនេះទៅណឹងដឹងរត់ ដឹងនៅគ្នាមិនដឹងដែរ ?

**សារ៉ាត:** ចាប់ជាមួយពួកខ្ញុំដែរ ។

**ចាន់:** **បុប្ផា** ?

**សាវ៉ាត:** **បុប្ផា** ។

**ចាន់:** ប្រពន្ធ**តាំភួន** ?

**សាវ៉ាត:** ហើយ ។

**ចាន់:** អត់ទេ វាមានឈ្មោះ ហៅក្រៅ**បុប្ផា** ?

**សាវ៉ាត:** អូ! ប្រពន្ធ**តាំភួន** (និយាយឡាវ) ។

**ចាន់:** **ខ្លួន** ?

**សាវ៉ាត:** អូ ខ្លួនយុទ្ធជនក-១៦ ដែរ (និយាយឡាវ) ។

**ចាន់:** នៅរស់ទេ ?

**សាវ៉ាត:** ស្លាប់ហើយ ។

**ចាន់:** តាំង ?

**សាវ៉ាត:** (និយាយឡាវ) និរសាគា **តាំភួន**ចាប់ ។

**ចាន់:** និរសាគា**តាំភួន** ?

**សាវ៉ាត:** បាទ, **ប៊ុន** ក៏និរសាដែរ ។

**ចាន់:** និរសាគា**តាំភួន**ដែរ ?

**សាវ៉ាត:** ណឹងហើយ និរសាគា**តាំភួន**ដែរ ចូលក្នុងមូលដ្ឋានមុន ។

**ចាន់:** សុទ្ធតែងាប់អស់ហើយ?

**សាវ៉ាត:** អត់ទេ **ដែង** នៅ, អូ **តាំង**នៅ ។

**ចាន់:** តាំងនៅឯណា?

**សាវ៉ាត:** នៅស្រែសង្គម ។

**ចាន់:** នៅស្រែសង្គមដែរ ?

**សាវ៉ាត:** បាទ!

**ចាន់:** ក្មួយរបស់អ៊ំ ?

**សាវ៉ាត:** បាទ!

**ចាន់:** **វិន**?

**សាវ៉ាត:** **វិន**នៅនេះ ។

**ដារ៉ា:** **នារី** ?

**សារ៉ាត:** យុទ្ធនារីក-១៦ (និយាយឡាវ) ។

**ដារ៉ា:** **យួនឌីក** ?

**សារ៉ាត:** យួន ។

**ដារ៉ា:** **ថាន់** ក៏យួន, **ទីន**នេះក៏យួន, **ខ្វាក** ចាប់ហើយ ?

**សារ៉ាត:** ខ្វាកចាប់ហើយ ។

**ដារ៉ា:** **ខ្វាក**ហ្នឹងនរណាគេ ?

**សារ៉ាត:** **ខ្វាក**ហ្នឹងយួនទេដឹង ខ្វាកហ្នឹង ។

**ដារ៉ា:** ជនជាតិស្មៀង ?

**សារ៉ាត:** **ញូន** និរសា**ខាំភូន** អាណឹងគេដាក់កស្តុភារ, **ខាំភូន**គណៈតំបន់ ១០៥ ។

**ដារ៉ា:** **ចាន់ ថន** គណៈតំបន់ ១០៥ ?

**សារ៉ាត:** **ស៊ុន ថន** ។

**ដារ៉ា:** **ស៊ុន ថន**ទេអី ?

**សារ៉ាត:** **ស៊ុន ថន**ហ្នឹងប្រធានលេខាក្រសួងសេដ្ឋកិច្ចតំបន់ ។

**ដារ៉ា:** នៅរស់ទេ ?

**សារ៉ាត:** ស្លាប់បាត់ហើយ ប៉ុន្មានឆ្នាំ ។

**ដារ៉ា:** អញ្ចឹងនៅក្នុងភូមិណឹង នៅស្រែសង្គមអីមានអ្នកនៅរស់ច្រើនដែរតើ៎ ? អ្នកជាប់ក្នុំក្រោល ?

**សារ៉ាត:** គាត់ឈ្មោះ **ឡាយ ក្លឹង** គេហៅ**ដុស** នៅភូមិស្រែសង្គមណឹង ។

**ដារ៉ា:** ចុះបើយើងសួរគេៗ ប្រាប់ទេ ?

**តូច:** គេប្រាប់ដូចអញ្ចឹង ប៉ុន្តែណែនាំគេយលគេឃើញមានឈ្មោះដូចឈ្មោះគាត់អញ្ចឹងគេដឹងអ្នកខ្លះណឹងសម័យនោះអ្នកខ្លះមិនដឹងអស់ទេព្រោះថានៅមន្ទីរនេះផ្សេង មន្ទីរនោះផ្សេងគេហៅថាមន្ទីរគេនោះ ហើយសហករណ៏នេះផ្សេងសហករណ៏នោះផ្សេងចេះតែស្គាល់គ្នាចេះតែទៅប្រាប់ ទៅដូចចំលើយគេណឹងត្រូវម៉េះៗ ចំលើយឆ្លើយថា ទាហានមិនដឹងចាប់មិនដឹងងាប់ មិនដឹងជនជាតិស្អី មិនអាចដាក់បានទេ ដឹងតែឈ្មោះ ប៉ុន្តែមិនអាចដឹងទាំងអស់បានដែរ អញ្ចឹងណាត្រូវរបស់គេហើយ ។

ដារ៉ា: អញ្ចឹងបានខ្ញុំចង់សំភាសន៏អោយបានច្រើនដល់ យើងយកទៅផ្គុំគ្នាទៅវាអាចជាសាច់រឿងមួយ

បានអូ! ប្រហែលជាទៅស្រែសន្គមហើយទៅអោយដល់តែម្តង ទៅរកឈ្មោះអស់ណឹងនៅទីនេះ ប្រហែលមានច្រើនទេ ?

**តូច:** មានច្រើនដែរ ។

ដារ៉ា: មានច្រើនដែរ ?

**តូច:** បាទ ដូចចំលើយៗ**ខាំភូន**ហើយណឹងគាត់លើកឡើងពីអ្នកដែលគាត់ស្គាល់នៃ នឹងប្រជាជននៅជាមួយគាត់ ។

ដារ៉ា: បាទ !

**តូច:** ដែលថាដូចគាត់ស្គាល់អីយើងមិនបានស្គាល់គ្នាអញ្ចឹងណា គាត់ដឹងថាប៉ុន្តែ.......

**សារ៉ាត:** គេចាប់ខ្ញុំមុនបានចាប់**ខាំភូន**ជាក្រោយ ។

**ដារ៉ា:** ចាប់អ៊ំមុន ?

**សារ៉ាត:** បាទ !

**ដារ៉ា:** ហើយចាប់**ខាំភូន**ជាក្រោយ ?

**សារ៉ាត:** បាទ! ណោះ**ខាំភូន**ណោះ ។

**តូច:** អឺ (និយាយឡាវ)

**សារ៉ាត:** (និយាយឡាវ)

**ដារ៉ា:** ដល់ពេលតែចាប់ច្រើនលេងតាំងខ្សែៗហ្នឹងណា ។

**តូច:** តាំងខ្សែ ។

ដារ៉ា: តែខ្សែពាល់តែខ្សែគៀកហ្មែអ៊ី ដូចអ៊ីថាចំណាត់លេខប៉ុន្មានត្រូវកំទេច ចំណាប់ណាត្រូវដាក់គុក ចំណាត់ណាត្រូវបញ្ជូនទៅការដ្ឋាន ។

**សារ៉ាត:** ហ្នឹងហើយ វាកន្លែងហ្នឹងវាពីរកន្លែងៗមួយគេហៅថាដូចឃើញថាសាលាគេថាជាគុក អញ្ចឹង ។

**ដារ៉ា:** បាទ !

**សារ៉ាត:** កន្លែង១ គុកផ្សេងនោះវាកន្លែងមន្ទីរលេងហ្នឹងណា ។

**ដារ៉ា:** បាទ !

**សារ៉ាត:** អាណឹងគេ ។

**តូច:** (និយាយឡាវ)

**សារ៉ាត:** ដាក់ៗក្នុងដីក៏វាជិះឡានតាមផ្លូវភ្នំកាលិកឃើញតែបាតជើងហ្នឹងឯងដែលដាក់ខ្នោះនោះខ្នោះឈើ ។

**ចាន់:** បាទ! ឃើញបាតជើងហ្នឹង ?

**សារ៉ាត:** អន្លុយនឹងដី គេ អាណឹងហើយអាប្អូនខ្ញុំដោះពីកន្លែងពួកខ្ញុំនឹងមកដាក់ខ្នោះណឹង២ខែទៀត បាន ដោះពីខ្នោះណឹងបានយកមកដាក់ការដ្ឋាន ។

**តូច:** បញ្ជូនមកក្រោយៗយើង ។

**សារ៉ាត:** មកដាក់..........អាណឹងសុទ្ធតែជុះកន្លែងហ្នឹង ។

**ចាន់:** ជុះនៅកន្លែងណឹង ?

**សារ៉ាត:** បាទជុះនៅកន្លែងហ្នឹង ប៉ុនជើងជាប់ខ្នោះទាំងអស់ ។

**ចាន់:** អញ្ចឹងអ្នកណាគេមកកើបមកអីទៅចុះ ?(សើច)

**ឆាន:** ចុះពូដាក់អីដាក់ជាក្រុម..... ហើយអ្នកណាអ្នកយកបោះចោល ?

**តូច:** អ្នកទោសគេដូចថា អ្នកណាវាងធូរតិច ឬក៏មិនធូរក៏ដោយគេដោះលែងអោយអ្នកនោះ ។ (និយាយឡាវ) ។

**សារ៉ាត:** ប៉ុន្តែខ្ញុំ.............ដានឃោនហ្នឹង មិនដឹងគេមានបំណងអញ្ចឹងទេ(និយាយឡាវ) ប៉ុនកាលជិតស្និត ជាមួយជួនកាលប្រាកដហើយអាណឹងវាមិនខុសទេតាមរយៈបន្តបន្ទាប់មករហូតទាល់តែ ។